# ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

## ពុទ្ធិកមហាវិទ្យាល័យបាលី-សំស្ក្រឹត និងភាសាបរទេស

សីល សមាធិ បញ្ញា

ប្រធានបទ

# ឆន្ទោជោតក

ដឹកនាំដោយសាស្ត្រាចារ្យ

**អែម ឧត្តម**

ស្រាវជ្រាវដោយ

១.សមណនិស្សិត **រឿន សុភា**    ២. សមណនិស្សិត **រ៉ូត ស៊ីរួន**

៣. សមណនិស្សិត **ផ្លាយ តុលី**    ៤.សមណនិស្សិត **ថៃ ថេត**

៥.សមណនិស្សិត **សាយ ចាក**

ឯកទេស **ភាសាបាលី**

សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី ១៣

ការពារនៅថ្ងៃសៅរ៍ ១០ កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ត្រូវនឹងថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២២

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
ពុទ្ធិកមហាវិទ្យាល័យបាលី-សំស្ក្រឹត និងភាសាបរទេស

ប្រធានបទ

# ឆន្ទោជាតក

ដឹកនាំដោយសាស្ត្រាចារ្យ
**អែម ឧត្តម**

ស្រាវជ្រាវដោយ

១.សមណនិស្សិត **ចៀន សុភា**
២.សមណនិស្សិត **វ៉ូត ស៊ីវួន**
៣.សមណនិស្សិត **ផ្លាយ តុលី**
៤.សមណនិស្សិត **ថៃ ថេត**
៥.សមណនិស្សិត **សាយ ចាក**

ឯកទេស **ភាសាបាលី**
សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី១៣

ការពារនៅថ្ងៃសៅរ៍ ១០កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២

# វិញ្ញាបនបត្រវាយតម្លៃ

## គណៈកម្មការវាយតម្លៃបញ្ជាក់ថា៖

១- សមណនិស្សិត **មឿន សុភា**
២- សមណនិស្សិត **វ៉ុត ស៊ីរួន**
៣- សមណនិស្សិត **ផ្លាយ តុលី**
៤- សមណនិស្សិត **ថៃ ថេត**
៥- សមណនិស្សិត **សាយ ចាក**

*បានការពារសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រលើប្រធានបទ* **ឆន្នោវាទជាតក** *ជាប់ជាស្ថាពរ នៅថ្ងៃសៅរ៍ ១០កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១២ ខែ មីនា ឆ្នាំ២០២២ ។*

### គណៈកម្មការវាយតម្លៃ

១- ព្រះបណ្ឌិត **ហ៊ី ហុង** ប្រធាន ..........
២- ព្រះបណ្ឌិត **សែម ឈុនលី** សមាជិក ..........
៣-ព្រះមហា **ច័ន្ទ ឧត្តម** សមាជិក ..........
៤- លោក **រ៉ុត សោរឌឿ** សមាជិក ..........

*ព្រះសាកលវិទ្យាធិការនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ឯកភាពយល់ព្រមលើប្រធានបទសារណា* **ឆន្នោវាទជាតក** *របស់សមណនិស្សិត-និស្សិត ដែលគណៈកម្មការវាយតម្លៃបានសម្រេចឲ្យជាប់ជាស្ថាពរ។*

*ថ្ងៃ.................ខែ..........ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥*

*រាជធានីភ្នំពេញ, ថ្ងៃទី..........ខែ..........ឆ្នាំ២០២២*

**ព្រះសាកលវិទ្យាធិការ**

សម្តេចព្រះមហាអរិយវង្ស
បណ្ឌិត **យី សុវណ្ណរតនា**

# ឧទ្ទិសកថា

ទូលបង្គំ ខ្ញុំព្រះករុណាអាត្មាភាព ជាសមណនិស្សិតនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ឆ្នាំទី៤ ជំនាន់ទី ១៣ នៃពុទ្ធិកមហាវិទ្យាល័យបាលី-សំស្ក្រឹត និងភាសាបរទេស សូមក្រាបថ្វាយបង្គំ និងសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុត និងសូមឧទ្ទិសស្នាដៃនេះថ្វាយប្រគេនជូនចំពោះ៖

អតីតសម្តេចព្រះសង្ឃរាជទាំងពីរគណៈ ដែលព្រះអង្គបានទទួលអនិច្ចធម្មទៅ ដោយបុព្វហេតុព្រះពុទ្ធសាសនា និងមាតុប្រទេស ហើយបានបន្សល់ទុកនូវស្នាព្រះហស្តដល់បច្ឆាជន។

ព្រះមហាក្សត្រខ្មែរគ្រប់ជំនាន់ ដែលបានកសាងប្រទេសជាតិ និងអរិយធម៌វប្បធម៌ដ៏សម្បូរបែបបន្សល់ទុកដល់ប្រជានុរាស្ត្រជំនាន់ក្រោយរហូតមកដល់សព្វថ្ងៃ។

ក្រុមជំនុំជម្រះព្រះត្រៃបិដក និងព្រះថេរានុថេរៈគ្រប់រូប ដែលបានបូជាកម្លាំងកាយចិត្តក្នុងបុព្វហេតុជាតិពុទ្ធសាសនា និងវិស័យពុទ្ធិកសិក្សាឱ្យបានគង់វង្សក្នុងកម្ពុជរដ្ឋយើងរហូតដល់ពេលនេះ។

អ្នកប្រាជ្ញខ្មែរគ្រប់សម័យកាល ដែលបានលះបង់កម្លាំងកាយ កម្លាំងចិត្តដោយបានកសាងស្នាដៃទុកដូចជាក្បួនច្បាប់អប់រំជាច្រើន សម្រាប់កុលបុត្រខ្មែរបានសិក្សារៀនសូត្យមកដល់បច្ចុប្បន្ននេះ។

ញាតិទាំងឡាយរបស់ទូលបង្គំ ដែលបានធ្វើកាលកិរិយាទៅ សូមឱ្យរួចចាកទុក្ខទោសគ្រប់យ៉ាងបានទៅកើតនៅទីឋានដ៏សមគួរដោយអំណាចនៃផលបុណ្យដែលកើតចេញពីស្នាដៃនេះ។

ទូលបង្គំ ខ្ញុំព្រះករុណា អាត្មាភាព សូមបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុសក្តិសិទ្ធិក្នុងលោកនេះជួយគ្រប់គ្រងរក្សា សម្តេច ព្រះតេជព្រះគុណ ទ្រង់ ឯកឧត្តម លោកជំទាវ បណ្ឌិត សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សាធុជនគ្រប់រូប បានបដិសន្ធិក្នុងសុគតិភពជាភិយ្យោភាពកុំបីខានឡើយ។

# សេចក្តីថ្លែងអំណរគុណ

ទូលព្រះបង្គំ ខ្ញុំព្រះករុណា អាត្មាភាពជាសមណនិស្សិតនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ឆ្នាំទី ៤ ជំនាន់ទី ១៣ សូមថ្លែងអំណរព្រះគុណនិងអរគុណជាអនេកប្បការប្រកបដោយកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះអ្នកមានគុណទាំងឡាយមានដូចជាៈ

លោកអ្នកមានគុណទាំងពីរ គឺមាតាបិតាដែលបានផ្តល់កំណើតដល់ទូលព្រះបង្គំ ខ្ញុំព្រះករុណា អាត្មាភាព ព្រមទាំងបានខិតខំបីបាច់ថែរក្សាទំនុកបម្រុងតាំងពីតូចរហូតដល់ធំ និងបានអប់រំទូន្មានប្រៀនប្រដៅឱ្យក្លាយជាមនុស្សល្អ មានប្រយោជន៍ មានគុណធម៌ ព្រមទាំងបានបញ្ជូនឱ្យសិក្សារហូតដល់ថ្នាក់បរិញ្ញាបត្រ។

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **នន្ទ ង៉ែត** សម្តេចព្រះមហាសង្ឃរាជគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា ដែលសម្តេចជាអង្គម្ចាស់បានយកព្រះទ័យទុកដាក់ក្នុងការលើកស្ទួយដល់វិស័យពុទ្ធិកសិក្សាឱ្យរីកចម្រើនរហូតមកដល់បច្ចុប្បន្ន។

ព្រះមហាវីរៈក្សត្រព្រះបរមរតនកោដ្ឋ **នរោត្តម សីហនុ** និងព្រះមហាក្សត្រិយានី **នរោត្តម មុនីនាថ សីហនុ** ទ្រង់យកព្រះទ័យទុកដាក់ ព្រមទាំងបានបង្កើតឱ្យមានពុទ្ធិកសាកលវិទ្យាល័យនេះ។

សម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់តែងយកព្រះទ័យទុកដាក់លើកស្ទួយវិស័យពុទ្ធិកសិក្សា ព្រមទាំងទ្រង់ជាអ្នកស្រឡាញ់រាប់អានព្រះពុទ្ធសាសនាយ៉ាងមុតមាំផង។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បានយកចិត្តទុកដាក់គ្រប់វិស័យសិក្សាទាំងអស់របស់បព្វជិត និងគ្រហស្ថ ធ្វើយ៉ាងណាឱ្យមានធនធានមនុស្សច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា។

ព្រះសាកលវិទ្យាធិការរង មានសម្តេចព្រះមហាអរិយវង្ស បណ្ឌិត **យី សុវណ្ណរតនា** សម្តេចបានទទួលបន្ទុកផ្ទាល់ ក្នុងពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជនេះ សម្តេចបានផ្តល់ឱកាសដល់ក្រុមទូលព្រះបង្គំ ឱ្យបានសិក្សារៀនសូត្រអស់រយៈកាល ៤ ឆ្នាំកន្លងមក និងតែងតែផ្តល់ចំណេះដឹងនិងដំបូន្មានល្អៗ ព្រមទាំងបទពិសោធន៍ក្នុងការសិក្សា ដល់សមណនិស្សិតនិងនិស្សិតគ្រប់រូប។ ដំបូន្មានទាំងអស់នេះហើយបានធ្វើឱ្យក្រុមទូលព្រះបង្គំមានកម្លាំងចិត្តរឹតតែខិតខំសិក្សាបន្តទៀត។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សម្តេច ព្រះតេជគុណ ឯកឧត្តម អស់លោក លោកស្រីជាព្រះសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកសិក្សាគ្រប់រូបនៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ដែលបានខិតខំយកអស់កម្លាំងកាយ និងចិត្តក្នុងការដឹកនាំគ្រប់គ្រងក្នុងពុទ្ធិកសិក្សានេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកគ្រូ **ឌុច សុវណ្ណមុនី** ជាសាស្ត្រាចារ្យ និងជាសមាជិកនៅក្នុងអនុគណៈកម្មការទទួលបន្ទុកឯកទេស ភាសាបាលី ផ្នែកក្រោយឧត្តមសិក្សានៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងលោកគ្រូ **ម្លូន សារុឌ្ឍី** ជាសាស្ត្រាចារ្យផ្នែកក្រោយឧត្តម

សិក្សានៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជនេះ ដែលលោកគ្រូទាំងពីររូបនេះ បានផ្តល់ឱកាសឱ្យក្រុមខ្ញុំព្រះករុណា អាត្មាភាពបានជួបធ្វើបទសម្ភាសន៍ដោយផ្ទាល់ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវលើប្រធានបទនៃសារណានេះ។

ជាពិសេសសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតដល់លោកគ្រូណែនាំ **អែម ឧត្តម** និងលោកគ្រូជំនួយការ **ឃាង សុភាព** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីពន្យល់ណែនាំក្នុងការសិក្សាស្រាវជ្រាវ ព្រមទាំងបានត្រួតពិនិត្យនិងរៀបចំកែលម្អនូវទម្រង់ផ្សេងៗ នៃសារណានេះរហូតដល់ចប់សព្វគ្រប់។

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតដល់សមាគមទ្រទ្រង់បាលី មានព្រះគ្រូ **បញ្ញាសីលមុនី ពេជ្រ សុវណ្ណា** (**វជិរបញ្ញោ**) ជាប្រធាន និងសមាជិក សមាជិកាទាំងអស់ ដែលបានជួយទំនុកបំរុងកន្លងមក ។

ជាអវសានកថា ទូលព្រះបង្គំ ខ្ញុំព្រះករុណា អាត្មាភាព សូមបួងសួងដល់គុណនៃព្រះរតនត្រ័យ និងវត្ថុសក្តិសិទ្ធក្នុងលោកតាមជួយថែរក្សា សម្តេច ព្រះតេជគុណ ទ្រង់ ឯកឧត្តម លោកជំទាវ បណ្ឌិត សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ អស់លោក លោកស្រី ព្រមទាំងពុទ្ធសាសនិកទាំងអស់ សូមឱ្យបានសមប្រកបជួបប្រទះតែនឹងពរ ៤ ប្រការគឺ **អាយុ វណ្ណៈ សុខ ពល** កុំបីអាក់ខានឡើយ។

សូមអរព្រះគុណ និងអរគុណ!

# សេចក្តីធានាអះអាង

អត្ថបទនៃសារណានេះ ជាអត្ថបទមួយដែលកើតមកពីសេចក្តីព្យាយាមប្រឹងប្រែង ធ្វើការសិក្សាស្រាវជ្រាវតាមបណ្ណាល័យផ្សេងៗ និងតាមគម្ពីរនានាដោយយកចិត្តទុកដាក់ ដើម្បីដកស្រង់ខ្លឹមសារសំខាន់ៗ ដែលទាក់ទងនឹងប្រធានបទ ទើបបានចងក្រងរៀបរៀងចេញជាសារណានេះឡើង។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា អាត្មាភាពទាំង ៥ រូបសូមធានាថា គ្រប់ខ្លឹមសារអត្ថបទនៃសារណាដែលបានដាក់ជូនដល់ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ដើម្បីបំពេញតាមលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រឯកទេសភាសាបាលីនេះគឺជាអត្ថបទដែលកើតចេញពីការខិតខំស្រាវជ្រាវរបស់ក្រុមទូលព្រះបង្គំ ខ្ញុំព្រះករុណា អាត្មាភាព ។ ដោយក្នុងសារណានេះគ្រាន់តែដកស្រង់ខ្លឹមសារសំខាន់ៗ ដែលពាក់ព័ន្ធ និងប្រធានបទនេះប៉ុណ្ណោះ។

ហេតុនេះក្រុមទូលព្រះបង្គំ ខ្ញុំព្រះករុណា អាត្មាភាព សូមធានាថា សារណានេះ ពិតជាពុំបានលួចចម្លងឯកសារស្នាដៃរបស់បុគ្គលណាម្នាក់ឡើយ។ ប្រសិនបើ សាលាពិនិត្យឃើញថា ខុសពីការពិតតាមការអះអាងខាងលើនេះមែន អត្ថបទនៃសារណានេះពុំមានលក្ខណៈគ្រប់គ្រាន់ដើម្បីឱ្យក្រុមទូលព្រះបង្គំ ខ្ញុំព្រះករុណា អាត្មាភាពទទួលបាននូវសញ្ញាបត្រឡើយ។

ថ្ងៃ.សុក្រ ២ រោច....ខែ.មាឃ.....ឆ្នាំឆ្លូវ ត្រីស័ក... ព.ស.២៥៦៥
រាជធានីភ្នំពេញ, ត្រូវនឹងថ្ងៃទី.១៨.......ខែ.កុម្ភៈ......ឆ្នាំ២០២២

**សមណនិស្សិតក្រុមទី១**

១-សមណនិស្សិត **មៀន សុភា** ..........

២-សមណនិស្សិត **វ៉ុត ស៊ីរួន** ..........

៣-សមណនិស្សិត **ផ្លាយ តុលី** ..........

៤-សមណនិស្សិត **ថៃ ថេត** ..........

៥-សមណនិស្សិត **សាយ ចាក** ..........

**បានឃើញ និងឯកភាព**

ថ្ងៃ.សៅរ៍ ៣ រោច...ខែ.មាឃ.......ឆ្នាំ ឆ្លូវ ត្រីស័ក....... ព.ស.២៥៦៥
រាជធានីភ្នំពេញ, ត្រូវនឹងថ្ងៃទី.១៩.......ខែ.កុម្ភៈ......ឆ្នាំ២០២២

សាស្ត្រាចារ្យដឹកនាំ និងហត្ថលេខា

សាស្ត្រាចារ្យ **អែម ឧត្តម** ..................

# អារម្ភកថា

ភាសាបាលី ជាភាសាដែលមានក្បួនច្បាប់ដ៏ល្អវិចិត្រយ៉ាងក្រៃលែង ព្រោះហេតុដូច្នេះហើយ បានជាព្រះពុទ្ធបរមគ្រូនៃយើង ព្រះអង្គជាអ្នកដល់នូវនិរុត្តិបដិសម្ភិទា ទ្រង់បានធ្វើភាសានេះឱ្យមានលក្ខណៈល្អវិចិត្រ ដោយព្រះធម្មទេសនារបស់ព្រះអង្គ ។

ការសំដែងធម៌របស់ព្រះអង្គ ដែលប្រកបដោយបជ្ជបទ (បទគាថា) និងចុណ្ណិយបទ (បទរាយ) ទាំងនោះ គឺជាបទដែលប្រកបដោយសព្ទ និងអត្ថច្បាស់លាស់។ ដូច្នេះហើយបានជាព្រះអរិយសាវ័កទាំងឡាយ ជាអ្នកដល់នូវនិរុត្តិបដិសម្ភិទា លោកព្យាយាមចែកវេយ្យាករណ៍ទៅតាមព្រះពុទ្ធវចនៈ សមដូចព្រះមហាកច្ចាយនត្ថេរៈពោលទុកខាងដើមនៃនាមកណ្ឌថា "**ជិនវចនយុត្តំ ហិ** សូត្រ វុត្តិនិងឧទាហរណ៍ត្រូវសមគួរចំពោះព្រះពុទ្ធវចនៈតែប៉ុណ្ណោះ" បានសេចក្ដីថា សទ្ទវិទូទាំងឡាយមិនត្រូវចែកនូវវេយ្យាករណ៍ឱ្យខុសចាកព្រះពុទ្ធដីកាឡើយ។ ព្រះធម្មទេសនាដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ គឺព្រះអង្គទ្រង់មិនបានកំណត់ថា គាថានេះមានឈ្មោះយ៉ាងនេះយ៉ាងនោះឡើយ គឺទ្រង់ត្រាស់សម្ដែងដោយសាមញ្ញលក្ខណៈ (លក្ខណៈទូទៅ) ថា "**គាថា**" តែម្ដង សមដូចព្រះសង្ឃរក្ខិតមហាសាមិពោលទុកក្នុងវុត្តោទយប្បករណ៍ថា

**អនន្តរោទិតំ ចញ្ញ-, មេតំ សាមញ្ញនាមតោ;**
**គាថាឥច្ចេវ និទ្ទិដ្ឋំ, មុនិន្ទវចនេ បន។**

វណ្ណវុត្តិឆន្ទ និងមត្តាវុត្តិឆន្ទ ជាឈ្មោះឆន្ទក្នុងសំស្ក្រឹត, ចំណែកក្នុងព្រះពុទ្ធវចនៈហៅដោយឈ្មោះសាមញ្ញថា គាថា មែនពិត។

គម្ពីរវុត្តោទយៈ ដែលរចនាឡើងដោយព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈ ដ្បិតតែលោករចនាឡើង ដោយពឹងផ្អែកលើគម្ពីរសំស្ក្រឹតឆន្ទទាំងឡាយ មានបិង្គលឆន្ទជាដើមក៏ដោយ ក៏លោកព្យាយាមប្រឹងចែក និងយកព្រះគាថាដែលព្រះពុទ្ធអង្គទ្រង់សម្ដែងមកចែក និងកំណត់ឈ្មោះដោយនាំយកឈ្មោះគាថា និងប្រភេទគាថា ចាកគម្ពីរឆន្ទសំស្ក្រឹតខ្លះៗមកប្រើតែប៉ុណ្ណោះ។

មែនពិត ក្នុងគម្ពីរវុត្តោទយប្បករណ៍ គឺលោកអ្នករចនាចែកប្រភេទគាថាជាពីរប្រភេទធំៗ គឺ**មត្តាវុត្តិ** មួយប្រភេទ និង **វណ្ណវុត្តិ** មួយប្រភេទ។ ចំណែកគម្ពីរវុត្តោទ័យ ដែលប្រែ និងរៀបរៀងដោយព្រះញាណ-បវរវិជ្ជា អែម ក្នុងសេចក្ដីប្រែក្នុងគម្ពីរនោះ លោកបានប្រែបទ **មត្តាវុត្តិ** នេះថា **មត្តាព្រឹត្តិ**, ហើយប្រែបទ **វណ្ណវុត្តិ** នេះថា **វណ្ណព្រឹត្តិ**។ ចំណែកវចនានុក្រមខ្មែរសម្ដេចព្រះសង្ឃរាជ ជោតញាណោ ជួន ណាត ពន្យល់ថា "**ព្រឹត្តិ** ជាពាក្យដែលក្លាយពីភាសាសំស្ក្រឹតថា **វ្ឫត្តិ** (**वृत्ति**) ស្មើនឹងពាក្យបាលីថា **វុត្តិ**"។ ហើយពាក្យថា **វុត្តិ** ប្រែថា **គាថា** ព្រោះពាក្យថា **គាថា** នេះ មានសព្ទដែលជាវេវចនៈនឹងគ្នាជាច្រើនដូចជា **សិលោកោ, វុត្តិ, បជ្ជំ, វុត្តំ** ។

ក្នុងប្រធានបទថា ឆន្ទោជោតកៈ នេះក្រុមសូមយកតែ **មត្តាវុត្តិ** ឬ**មត្តាគាថា** មកធ្វើការអធិប្បាយតែប៉ុណ្ណោះ ដើម្បីទទួលបានចំណេះដឹងថ្មីៗ និងដើម្បីអភិវឌ្ឍខ្លួនឱ្យក្លាយជាធនធានសំខាន់ ពីការសិក្សា

ស្រាវជ្រាវ ទើបក្រុមខ្ញុំបានសរសេរសារណាទាក់ទងនឹងការប្រព័ន្ធគាថានេះឡើង ដើម្បីជាប្រយោជន៍ដល់អ្នកសិក្សាជំនាន់ក្រោយ។ ទន្ទឹមនឹងនេះ ក៏សូមធ្វើការអធ្យាស្រ័យអភ័យអត់ទោស ពីសម្នាក់សម្តេចជាអង្គម្ចាស់គ្រប់ព្រះអង្គ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សមណនិស្សិត និងនិស្សិតមិត្តអ្នកសិក្សាគ្រប់រូបទុកជាមុនរាល់កំហុសឆ្គងដោយអចេតនាណាមួយពុំសមគួរ ក្រុមទូលព្រះបង្គំ ខ្ញុំព្រះករុណាអាត្មាភាព នឹងរង់ចាំទទួលជានិច្ចរាល់ការរិះគន់កែលម្អ ដើម្បីស្ថាបនាដោយក្តីសោមនស្ស។

ទូលព្រះបង្គំ ខ្ញុំព្រះករុណាអាត្មាភាពទាំង ៥ រូបសង្ឃឹមថា សារណានេះនឹងបានជាប្រយោជន៍ដល់មិត្រអ្នកអានគ្រប់រូប និងដើម្បីចូលរួមស្ថាបនាចំណេះដឹងដល់អ្នកសិក្សាទាំងឡាយ ឱ្យកាន់តែប្រសើរឡើង។

# មូលន័យសង្ខេប

ព្រះពុទ្ធសាសនាបានជ្រួតជ្រាបក្នុងប្រទេសកម្ពុជាអស់រយៈកាលជាយូរមកហើយ ប៉ុន្តែការយល់ដឹងរបស់បរិស័ទអ្នកប្រតិបត្តិតាមនៅមានកម្រិតនៅឡើយ។ ព្រះពុទ្ធសាសនា ដែលរីកចម្រើនទៅបានអាស្រ័យលើបរិស័ទបានសិក្សារៀនសូត្រនូវព្រះពុទ្ធវចនៈជាមុនសិន។ ការសិក្សាព្រះពុទ្ធវចនៈឱ្យបានយល់គ្រប់បទគ្រប់គាថាបាន ទាល់តែបានសិក្សាភាសាបាលី ឬមគធភាសា។ សព្វថ្ងៃនេះ មានប្រទេសជាច្រើនលើពិភពលោក ជាពិសេសប្រទេសដែលគោរពរាប់អានតាមលទ្ធិព្រះពុទ្ធសាសនា កំពុងចាប់អារម្មណ៍យ៉ាងខ្លាំងលើភាសាបាលី។ ម្យ៉ាងទៀតមិនត្រឹមតែប៉ុណ្ណោះ ថែមទាំងយកភាសានេះ មកធ្វើជាជំនួយក្នុងការសិក្សាស្រាវជ្រាវនូវព្រះពុទ្ធវចនៈដែលជាពាក្យបង្រៀនរបស់ព្រះពុទ្ធទៀតផង។

ទន្ទឹមគ្នានេះដែរ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ បានបើកបង្រៀនថ្នាក់មហាវិទ្យាល័យភាសាបាលី និងភាសាសំស្ក្រឹតក្នុងគោលបំណង ដើម្បីផ្តល់ចំណេះដឹងផ្នែកភាសាបាលី ឬមធភាសានេះឱ្យដល់សមណនិស្សិត-និស្សិតគ្រប់រូប ដែលចង់ចេះ ចង់ដឹងក្នុងភាសានេះ។

ដើម្បីឱ្យសមស្របទៅនឹងកម្មវិធីសិក្សា របស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ព្រឹទ្ធបុរសគ្រប់គ្រងផ្នែកភាសាបាលី និងភាសាសំស្ក្រឹត បានរៀបចំឱ្យសរសេរចងក្រងជាសារណា ដែលពាក់ព័ន្ធក្នុងភាសាបាលី លើប្រធានបទគឺ "**ឆន្ទោជោតកា**"។

នៅក្នុងសេចក្តីរបស់ "**ឆន្ទោជោតកា**" នេះបានធ្វើការសិក្សាស្រាវជ្រាវលើ ប្រែលោតប្រយោគ, បរិយាយមេសូត្រ បានដល់ ការពោលរៀបរាប់អំពីវិធីរចនាគាថាតាមមេសូត្រនៃគាថានោះៗ, រចនាប្លង់តែងគាថា គឺគូសប្លង់ឱ្យស្របតាមការបរិយាយខាងលើ, និងលើកអាគតដ្ឋាន បានដល់ឧទាហរណ៍ដែលមានពិតប្រាកដជាក់ស្តែងក្នុងគម្ពីរព្រះត្រៃបិដកជាដើម, និងអនុវត្តផ្ទាល់ គឺក្រុមបានអនុវត្តតែងគាថានោះៗទៅតាមឈ្មោះនិងតាមប្លង់ដែលបានបរិយាយមកពីខាងដើម, ចុងក្រោយស្រាវជ្រាវលើ គាទិសង្ខ្យានយៈ បានដល់ វិធីរកចំនួនគរុជាដើមក្នុងគាថាទូទៅបានទាំងអស់ ។

បែបរចនាគាថាផ្សេង ៗ ក្នុង "**ឆន្ទោជោតកា**" នេះ ដែលក្រុមបានធ្វើការស្រាវជ្រាវចងក្រងឡើងក្នុងគោលបំណងដើម្បីបានជាអនុសាសន៍ សម្រាប់អ្នកដែលចង់ចេះក្នុងផ្នែករចនាគាថានេះ ម្យ៉ាងទៀតដើម្បីបានជាប្រយោជន៍ដល់ក្រុមផង ដល់សង្គមជាតិផង ។

# អាទិសង្កេត

| អក្សរពេញ | អក្សរសង្ខេប |
| --- | --- |
| បឋមវិសមង្ឃាន | ប.វិ. |
| ទុតិយសមង្ឃាន | ទុ.ស. |
| តតិយវិសមង្ឃាន | ត.វិ. |
| ចតុត្ថសមង្ឃាន | ច.ស. |
| បញ្ចមវិសមង្ឃាន | បញ្ច.វិ. |
| ឆដ្ឋសមង្ឃាន | ឆ.ស. |
| សត្តមវិសមង្ឃាន | ស.វិ. |
| អដ្ឋមសមង្ឃាន | អ.ស. |
| ភគណៈ | ភ. |
| ជគណៈ | ជ. |
| សគណៈ | ស. |
| មគណៈ | ម. |
| នគណៈ | ន. |
| រគណៈ | រ. |
| យគណៈ | យ. |
| លហុ | ល. |
| គរុ | គ. |
| វិគ្គហៈ | វិ. |

# មាតិកា


ឧទ្ទិសកថា ....... I

សេចក្តីថ្លែងអំណរគុណ ....... II

សេចក្តីជានាអះអាង ....... IV

អារម្ភកថា ....... V

មូលន័យសង្ខេប ....... VII

អាទិសង្កេត ....... VIII

មាតិកា ....... IX

## ជំពូកទី១
## សេចក្តីផ្តើម

១.១-លំនាំបញ្ហានៃការស្រាវជ្រាវ ....... ១

១.២-គោលបំណងនៃការស្រាវជ្រាវ ....... ២

១.៣-ចំណោទបញ្ហានៃការស្រាវជ្រាវ ....... ២

១.៤-វិធីសាស្ត្រនៃការស្រាវជ្រាវ ....... ២

១.៤.១-ទិន្នន័យចម្បង ....... ២

១.៤.២-ទិន្នន័យបន្ទាប់បន្សំ ....... ៣

១.៥-ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ....... ៣

១.៦-សារប្រយោជន៍នៃការស្រាវជ្រាវ ....... ៣

១.៧-រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....... ៤

## ជំពូកទី២
## រំលឹកទ្រឹស្តី

២.១-និយមន័យ ....... ៥

២.១.១-ឆន្ទោជោតក ....... ៥

២.១.២-មត្តា ....... ៥

២.១.៣-គាថា ....... ៦

២.១.៤-មត្តាគាថា...... ៦
២.១.៥-លហុ...... ៦
២.១.៦-គរុ...... ៧
២.១.៧-គណ...... ៨
២.១.៨-ឆន្ទ...... ៨
២.២-គណសញ្ញា...... ៨
២.៣-ហេតុនាំឱ្យកើតគាថា...... ១០
២.៤-លក្ខណៈផ្សេងគ្នារវាងឆន្ទ និងគាថា...... ១០

## ជំពូកទី៣
## ប្រែលោតប្រយោគ និងបរិយាយមេសូត្រ

៣.១-ប្រែលោតប្រយោគ...... ១១
៣.១.១-គណនិយម...... ១១
៣.១.២-យតិនិយម...... ១១
៣.១.៣-អរិយាសាមញ្ញគាថា...... ១២
៣.១.៤-បថ្យាអរិយាគថា...... ១២
៣.១.៥-វិបុលាអរិយាគាថា...... ១២
៣.១.៦-ចបលាអរិយាគាថា...... ១៣
៣.១.៧-មុខចបលាអរិយាគាថា...... ១៣
៣.១.៨-ជឃនចបលាអរិយាគាថា...... ១៣
៣.១.៩-គីតិគាថា...... ១៤
៣.១.១០-ឧបគីតិគាថា...... ១៤
៣.១.១១-ឧគ្គីតិគាថា...... ១៤
៣.១.១២-អរិយាគីតិគាថា...... ១៥
៣.១.១៣-វេតាលីយគាថា...... ១៥
៣.១.១៤-ឱបច្ឆន្ទសកគាថា...... ១៦
៣.១.១៤-អាបាតលិកាគាថា...... ១៦
៣.១.១៦-ទក្ខិណន្តិកាគាថា...... ១៦

៣.១.១៧-ឧទិច្ចវុត្តិគាថា ........................................................................................... ១៦
៣.១.១៨-បច្ចវុត្តិគាថា ............................................................................................. ១៧
៣.១.១៩-បវត្តកគាថា ................................................................................................ ១៧
៣.១.២០-អបរន្តិកាគាថា ......................................................................................... ១៧
៣.១.២១-ចារុហាសិនីគាថា ..................................................................................... ១៧
៣.១.២២-អចលធិតិគាថា ........................................................................................ ១៨
៣.១.២៣-មត្តាសមកគាថា ....................................................................................... ១៨
៣.១.២៤-វិសិលោកគាថា ......................................................................................... ១៨
៣.១.២៥-វានវាសិកាគាថា ....................................................................................... ១៩
៣.១.២៦-ចិត្រាគាថា ............................................................................................... ១៩
៣.១.២៧-ឧបចិត្រាគាថា .......................................................................................... ១៩
៣.១.២៨-បាទាកុលកគាថា ....................................................................................... ១៩
៣.១.២៩-គាទិសង្ខ្យានយៈ ....................................................................................... ២០
៣.២-បរិយាយមេសូត្រ ............................................................................................. ២១
៣.២.១-គណនិយមៈ ................................................................................................ ២១
៣.២.២-យតិនិយមៈ ................................................................................................ ២៣
៣.២.៣-អរិយាសាញ្ញគាថា ..................................................................................... ២៤
៣.២.៤-បថ្យាអរិយាគាថា ........................................................................................ ២៤
៣.២.៥-វិបុលាអរិយាគាថា ...................................................................................... ២៥
៣.២.៦-ចបលាអរិយាគាថា ...................................................................................... ២៧
៣.២.៧-មុខចបលាអរិយាគាថា ................................................................................ ២៨
៣.២.៨-ជឃនចបលាអរិយាគាថា ............................................................................. ២៩
សរុបក្រុមអរិយាគាថា ៦ ប្រភេទគឺ ......................................................................... ៣១
៣.២.៩-គីតិគាថា .................................................................................................... ៣២
៣.២.១០-ឧបគីតិគាថា .............................................................................................. ៣៣
៣.២.១១-ឧគ្គីតិគាថា ................................................................................................ ៣៥
៣.២.១២-អរិយាគីតិគាថា .......................................................................................... ៣៦

សរុបក្រុមគីតិគាថា ៤ ប្រភេទគី ........ ៣៧
៣.២.១៣-វេតាលីយគាថា ........ ៣៨
៣.២.១៤-ឱបច្ឆន្ទសកគាថា ........ ៣៩
៣.២.១៥-អាបាតលិកាគាថា ........ ៤០
៣.២.១៦-ទក្ខិណន្តិកាគាថា ........ ៤១
៣.២.១៧-ឧទិច្ចវុត្តិគាថា ........ ៤២
៣.២.១៨-បច្ចវុត្តិគាថា ........ ៤៣
៣.២.១៩-បវត្តកគាថា ........ ៤៤
៣.២.២០-អបរន្តិកាគាថា ........ ៤៥
៣.២.២១-ចារុហាសិនីគាថា ........ ៤៦
សរុបក្រុមវេតាលីយគាថា ៩ ប្រភេទ ........ ៤៧
៣.២.២២-អចលធិតិគាថា ........ ៤៨
៣.២.២៣-មត្តាសមកគាថា ........ ៤៨
៣.២.២៤-វិសិលោកគាថា ........ ៤៩
៣.២.២៥-វានវាសិកាគាថា ........ ៤៩
៣.២.២៦-ចិត្រាគាថា ........ ៥០
៣.២.២៧-ឧបចិត្រាគាថា ........ ៥១
៣.២.២៨-បាទាកុលកគាថា ........ ៥១
សរុបក្រុមមត្តាសមកគាថា ៧ ប្រភេទ ........ ៥២
៣.២.២៩-គាទិសង្ខ្យានយៈ (វិធីរកចំនួនគរុជាដើម) ........ ៥៣

## ជំពូកទី៤
## បូជ៉រចនាមត្តាគាថា និង៉អាគតដ្ឋាន

៤.១-អរិយាគាថា ឬអរិយាសាមញ្ញគាថា ........ ៥៤
៤.១.១-ប្លង់រចនាអរិយាគាថា ........ ៥៤
៤.១.២-អាគតដ្ឋាន ........ ៥៤
៤.១.៣-អនុវត្ត ........ ៥៤
៤.២-បថ្យាអរិយាគាថា ........ ៥៥

៤.២.១-ប្លង់រចនាបថ្យាអរិយាគាថា ..................................................................................... ៥៥
៤.២.២-អាគតដ្ឋាន ..................................................................................... ៥៥
៤.២.៣-អនុវត្ត ..................................................................................... ៥៥
៤.៣-វិបុលាអរិយាគាថា ..................................................................................... ៥៦
៤.៣.១-ប្លង់រចនាវិបុលាអរិយាគាថា ..................................................................................... ៥៦
៤.៣.២-អាគតដ្ឋាន ..................................................................................... ៥៦
៤.៣.៣-អនុវត្ត ..................................................................................... ៥៦
៤.៤-ចបលាអរិយាគាថា ..................................................................................... ៥៧
៤.៤.១-ប្លង់រចនាចបលាអរិយាគាថា ..................................................................................... ៥៧
៤.៤.២-អាគតដ្ឋាន ..................................................................................... ៥៧
៤.៤.៣-អនុវត្ត ..................................................................................... ៥៧
៤.៥-មុខចបលាអរិយាគាថា ..................................................................................... ៥៨
៤.៥.១-ប្លង់រចនាមុខចបលាអរិយាគាថា ..................................................................................... ៥៨
៤.៥.២-អាគតដ្ឋាន ..................................................................................... ៥៨
៤.៥.៣-អនុវត្ត ..................................................................................... ៥៨
៤.៦-ជឃនចបលាអរិយាគាថា ..................................................................................... ៥៩
៤.៦.១-ប្លង់រចនាជឃនចបលាអរិយាគាថា ..................................................................................... ៥៩
៤.៦.២-អាគតដ្ឋាន ..................................................................................... ៥៩
៤.៦.៣-អនុវត្ត ..................................................................................... ៥៩
៤.៧-គីតិគាថា ..................................................................................... ៦០
៤.៧.១-ប្លង់រចនាគីតិគាថា ..................................................................................... ៦០
៤.៧.២-អាគតដ្ឋាន ..................................................................................... ៦០
៤.៧.៣-អនុវត្ត ..................................................................................... ៦០
៤.៨-ឧបគីតិគាថា ..................................................................................... ៦១
៤.៨.១-ប្លង់រចនាឧបគីតិគាថា ..................................................................................... ៦១
៤.៨.២-អាគតដ្ឋាន ..................................................................................... ៦១
៤.៨.៣-អនុវត្ត ..................................................................................... ៦១

៤.៩-ឧត្តិតិគាថា ............ ៦១
៤.៩.១-ប្លង់រចនាឧត្តិតិគាថា ............ ៦១
៤.៩.២-អាគតដ្ឋាន ............ ៦២
៤.៩.៣-អនុវត្ត ............ ៦២
៤.១០-អរិយាគីតិគាថា ............ ៦២
៤.១០.១-ប្លង់រចនាអរិយាគីតិគាថា ............ ៦២
៤.១០.២-អាគតដ្ឋាន ............ ៦៣
៤.១០.៣-អនុវត្ត ............ ៦៣
៤.១១-វេតាលីយគាថា ............ ៦៣
៤.១១.១-ប្លង់រចនាវេតាលីយគាថា ............ ៦៣
៤.១១.២-អាគតដ្ឋាន ............ ៦៣
៤.១១.៣-អនុវត្ត ............ ៦៤
៤.១២-ឱបច្ឆន្ទសកគាថា ............ ៦៤
៤.១២.១-ប្លង់រចនាឱបច្ឆន្ទសកគាថា ............ ៦៤
៤.១២.២-អាគតដ្ឋាន ............ ៦៤
៤.១២.៣-អនុវត្ត ............ ៦៤
៤.១៣-អាបាតលិកាគាថា ............ ៦៤
៤.១៣.១-ប្លង់រចនាអាបាតលិកាគាថា ............ ៦៤
៤.១៣.២-អាគតដ្ឋាន ............ ៦៥
៤.១៣.៣-អនុវត្ត ............ ៦៥
៤.១៤-ទក្ខិណន្តិកាគាថា ............ ៦៥
៤.១៤.១-ប្លង់រចនាទក្ខិណន្តិកាគាថា ............ ៦៥
៤.១៤.២-អាគតដ្ឋាន ............ ៦៥
៤.១៤.៣-អនុវត្ត ............ ៦៦
៤.១៥-ឧទិច្ចវុត្តិគាថា ............ ៦៦
៤.១៥.១-ប្លង់រចនាឧទិច្ចវុត្តិគាថា ............ ៦៦
៤.១៥.២-អាគតដ្ឋាន ............ ៦៦

៤.១៥.៣-អនុវត្ត ........................................................................................................ ៦៦
៤.១៦-បច្ចវុត្តិគាថា ........................................................................................................ ៦៧
៤.១៦.១-ប្លង់រចនាបច្ចវុត្តិគាថា ........................................................................................ ៦៧
៤.១៦.២-អាគតដ្ឋាន ........................................................................................................ ៦៧
៤.១៦.៣-អនុវត្ត ........................................................................................................ ៦៧
៤.១៧-បវត្តកគាថា ........................................................................................................ ៦៧
៤.១៧.១-ប្លង់រចនាបវត្តកគាថា ........................................................................................ ៦៧
៤.១៧.២-អាគតដ្ឋាន ........................................................................................................ ៦៨
៤.១៧.៣-អនុវត្ត ........................................................................................................ ៦៨
៤.១៨-អបរន្តិកាគាថា ........................................................................................................ ៦៨
៤.១៨.១-ប្លង់រចនាអបរន្តិកាគាថាទី១ ........................................................................................ ៦៨
៤.១៨.២-អាគតដ្ឋាន ........................................................................................................ ៦៨
៤.១៨.៣-អនុវត្ត ........................................................................................................ ៦៩
៤.១៨.២-ប្លង់រចនាអបរន្តិកាគាថាទី២ ........................................................................................ ៦៩
៤.១៨.៣-អាគតដ្ឋាន ........................................................................................................ ៦៩
៤.១៩-ចារុហាសិនីគាថា ........................................................................................................ ៦៩
៤.១៩.១-ប្លង់រចនាចារុហាសិនីគាថាទី១ ........................................................................................ ៦៩
៤.១៩.២-អាគតដ្ឋាន ........................................................................................................ ៧០
៤.១៩.៣-អនុវត្ត ........................................................................................................ ៧០
៤.១៩.២-ប្លង់រចនាចារុហាសិនីគាថាទី២ ........................................................................................ ៧០
៤.១៩.៣-អាគតដ្ឋាន ........................................................................................................ ៧០
៤.២០-អចលធិតគាថា ........................................................................................................ ៧១
៤.២០.១-ប្លង់រចនាអចលធិតិគាថា ........................................................................................ ៧១
៤.២០.២-អាគតដ្ឋាន ........................................................................................................ ៧១
៤.២០.៣-អនុវត្ត ........................................................................................................ ៧១
៤.២១-មត្តាសមកគាថា ........................................................................................................ ៧២
៤.២១.១-ប្លង់រចនាមត្តាសមកគាថា ........................................................................................ ៧២

៤.២១.២-អាគតដ្ឋាន ..... ៧២
៤.២១.៣-អនុវត្ត ..... ៧២
៤.២២-វិសិលោកគាថា ..... ៧២
៤.២២.១-ប្លង់រចនាវិសិលោកគាថា ..... ៧២
៤.២២.២-អាគតដ្ឋាន ..... ៧២
៤.២២.៣-អនុវត្ត ..... ៧៣
៤.២៣-វានវាសិកាគាថា ..... ៧៣
៤.២៣.១-ប្លង់រចនាវានវាសិកាគាថា ..... ៧៣
៤.២៣.២-អាគតដ្ឋាន ..... ៧៣
២.២៣.៣-អនុវត្ត ..... ៧៣
៤.២៤-ចិត្រាគាថា ..... ៧៣
៤.២៤.១-ប្លង់រចនាចិត្រាគាថា ..... ៧៣
៤.២៤.២-អាគតដ្ឋាន ..... ៧៤
៤.២៤.៣-អនុវត្ត ..... ៧៤
៤.២៥-ឧបចិត្រាគាថា ..... ៧៤
៤.២៥.១-ប្លង់រចនាឧបចិត្រាគាថា ..... ៧៤
៤.២៥.២-អាគតដ្ឋាន ..... ៧៤
៤.២៥.៣-អនុវត្ត ..... ៧៥
៤.២៦-បាទាកុលកគាថា ..... ៧៥
៤.២៦.១-ប្លង់រចនាបាទាកុលកគាថា ..... ៧៥
៤.២៦.២-អាគតដ្ឋាន ..... ៧៥
៤.២៦.៣-អនុវត្ត ..... ៧៥
៤.២៧-គាទិសង្ខ្យានយៈ (វិធីរកចំនួនគរុជាដើម) ..... ៧៦
៤.២៧.១-ឧទាហរណ៍ ..... ៧៦

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សេចក្តីសន្និដ្ឋាន ..... ៧៧
អនុសាសន៍ ..... ៧៧

# កន្ត្តនិទ្ទេស

គន្ថនិទ្ទេស ........................................................................................................ ៧៩

# ឧបសម្ពន្ធ

ឧបសម្ពន្ធ ........................................................................................................ ៨១

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១-លំនាំបញ្ហានៃការស្រាវជ្រាវ

កាលព្រះសម្មាសម្ពុទ្ធទ្រង់ធរមាននៅ ព្រះអង្គតែងតែត្រាស់សំដែងព្រះធម្មទេសនាដើម្បីអប់រំដល់សាវ័ករបស់ព្រះអង្គអស់រយៈកាល ៤៥ ព្រះវស្សា។ ក្នុងធម្មទេសនាដែលទ្រង់បានសំដែងនោះទៀតសោត គឺទ្រង់បានសំដែងជាភាសាបាលីនេះឯង។ ភាសាបាលីនេះ ជាភាសាមួយដែលមានវ័យចំណាស់ និងជាភាសាមួយដែលមានក្បួនខ្នាតវេយ្យាករណ៍ច្បាស់លាស់ គ្មានការវិវត្តន៍ និងមិនមានបុគ្គលណាមួយធ្វើឱ្យខូចខាតបានឡើយ ។ ភាសានេះមានឈ្មោះហៅបានច្រើនយ៉ាងដូចជាៈ

- **មូលភាសា** បានដល់ ភាសាដើម ឬភាសាដំបូង ព្រោះប្រើនិយាយគ្នាតាំងអំពីដើមកប្ប
- **ព្រហ្មភាសា** បានដល់ ភាសាដ៏ប្រសើរ ឬភាសារបស់ព្រហ្ម
- **យថាភុច្ចភាសា** បានដល់ ភាសាតាមបែបធម្មជាតិ
- **សភាវនិរុត្តិភាសា** បានដល់ ភាសាដែលប្រព្រឹត្តទៅតាមសភាវធម៌
- **បរមត្ថវោហារភាសា** បានដល់ ភាសាដែលប្រកាសប្រាប់នូវបរមត្ថ
- **អរិយវោហារភាសា** បានដល់ ភាសាដែលប្រកាសប្រាប់នូវអត្ថអរិយសច្ចៈ
- **មាគធីភាសា** បានដល់ ភាសាដែលមានប្រើក្នុងនគរមគធៈ។[១]

ដោយឡែកក្នុងប្រទេសកម្ពុជាយើងតាមការសិក្សាស្រាវជ្រាវមកគឺធ្លាប់មានអរិយធម៌វប្បធម៌ដ៏រុងរឿង អក្សរសាស្ត្រខ្មែរ និងអក្សរបាលី-សំស្ក្រឹត។

នាសម័យមហានគរ បុព្វបុរសខ្មែរជាអ្នកពូកែថ្វីវោហារ ចូលចិត្តតែងកំណាព្យកាព្យឃ្លោង ទាំងខេមរភាសា បាលិភាសា និងសំស្ក្រឹតភាសា មិនតែប៉ុណ្ណោះថែមទាំងបានចារបន្សល់ទុកលើផ្ទាំងសិលាជាកម្រងអប់រំទូន្មាន បូជាព្រះ និងរៀបរាប់ពីទ្រព្យសម្បត្តិសាធារណៈជាដើម ដែលមានភស្តុតាងរហូតដល់សព្វថ្ងៃនេះ។

មិនតែប៉ុណ្ណោះ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជបានបើកដំណើរការនូវពុទ្ធិកមហាវិទ្យាល័យបាលី-សំស្ក្រឹត និងភាសាបរទេស តាំងពីគ.ស.២០០៦ ក្នុងនោះមានមុខវិជ្ជា បាលិបរិវត្តន៍ ខេមរបរិវត្តន៍ បាលីតែងឆន្ទ អក្សរសិល្ប៍បាលី ជាដើម។ ចំណោមមុខវិជ្ជាទាំងនោះ មុខវិជ្ជារចនាគាថានេះ ក៏ជាមុខវិជ្ជាដែលមានសារៈសំខាន់ផងដែរ។

ដើម្បីឆ្លើយតបនឹងតម្រូវការសិក្សារបស់សិក្ខាកាម ដែលស្រឡាញ់ចូលចិត្តសិក្សាស្រាវជ្រាវផ្នែកគាថាក្នុងបាលិភាសា ក្រុមទូលបង្គំ ខ្ញុំព្រះករុណា ក៏សម្រេចយកប្រធានបទខាងលើនេះមកសរសេរជាសារណា

---

១ កច្ចាយនព្យាករណបាលិ, ភាគ១ (ប្រែនិងប្រកបរូបតាមសូត្រដោយ ទូច សុវណ្ណមុនី), ព.ស. ២៥៦១/ គ.ស.២០១៨, ទំព័រ ង។

ឡើង។ ហេតុដូច្នេះហើយ ទើបក្រុមសារណាខិតខំសិក្សាស្រាវជ្រាវសរសេរឱ្យសម្រេចបានជាវណ្ណកម្មនេះឡើង ដើម្បីរួមចំណែកថែរក្សាស្នាដៃបុព្វបុរស និងបន្តបន្សល់ទុកដល់សិក្ខាកាមជំនាន់ក្រោយ ៗ ទៀត។

## ១.២-គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងដើម្បីពង្រីកចំណេះដឹងផ្នែកខាងគាថានេះ ដើម្បីឱ្យស្គាល់ឈ្មោះគាថាផង និងដើម្បីឱ្យដឹងពីរបៀបរចនាគាថាផង ម្យ៉ាងទៀត ដើម្បីទុកជាឯកសារស្វ័យសិក្សាដល់សិស្សប្អូនជំនាន់ក្រោយផង។

ក្នុងការសិក្សាស្រាវជ្រាវនេះ ក្រុមបានកំណត់នូវគោលបំណងសំខាន់ ៗ ដូចខាងក្រោមនេះ៖

- ដើម្បីពង្រឹងចំណេះដឹងខ្លួនឯងក្នុងមត្តាគាថានេះ ឱ្យកាន់តែប្រសើរឡើង។
- ដើម្បីបានជាឯកសារក្នុងការសិក្សាស្រាវជ្រាវរបស់សិក្ខាកាមបន្ថែមលើពុទ្ធិរបស់ខ្លួន និងដើម្បីអភិវឌ្ឍចំណេះដឹងបន្ថែមទៀត។
- ដើម្បីរួមចំណែកក្នុងការអភិរក្សអក្សរសាស្ត្របាលី។
- ដើម្បីបន្សល់ទុកជាសម្បត្តិព្រះពុទ្ធសាសនា។

## ១.៣-ចំណោទបញ្ហានៃការស្រាវជ្រាវ

ការសិក្សាពីវិធីប្រព័ន្ធគាថា ធ្វើឱ្យយើងចេះវិភាគ ឬស្គាល់ពីប្រភេទនៃគាថានីមួយៗ ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សំដែងក្នុងគម្ពីរទាំង ៣ មានគម្ពីរព្រះវិន័យបិដក គម្ពីរព្រះសុត្តន្តបិដក និងគម្ពីរព្រះអភិធម្មបិដក ក្នុងគម្ពីរទាំងនេះសុទ្ធតែមានព្រះគាថាដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ និងព្រះសាវ័កបានពោលទុកមក។

ការសិក្សាស្រាវជ្រាវក្រោមប្រធានបទថា ឆន្ទោជោតកៈនេះមានលទ្ធផល ដែលអាចទទួលយកបានដោយអាស្រ័យទៅលើចម្លើយនៃសំណួរខាងក្រោមនេះ៖

- អ្វីទៅដែលហៅថា ឆន្ទោជោតកៈ ?
- អ្វីទៅដែលហៅថា មត្តាគាថា ?
- តើមត្តាគាថានេះចែកជាប៉ុន្មានក្រុម ? ហើយក្រុមនីមួយៗចែកជាប៉ុន្មានប្រភេទទៀត ?
- តើការរចនាប្រភេទមត្តាគាថានេះ មានប្លង់សម្រាប់រចនាយ៉ាងណា និងរបៀបរចនាដូចម្ដេច ?
- តើវិធីតែងគាថាក្នុងប្រភេទមត្តាគាថាមានភាពលំបាកដែរឬទេ ?
- តើការតែងគាថាក្នុងប្រភេទមត្តាគាថានេះ បម្រើផលប្រយោជន៍អ្វីខ្លះដល់សង្គម ?

## ១.៤-វិធីសាស្ត្រនៃការស្រាវជ្រាវ

ប្រភពទិន្នន័យដែលក្រុមសារណាបានសិក្សាស្រាវជ្រាវរាវរកឯកសារពាក់ព័ន្ធមានដូចជា៖

### ១.៤.១-ទិន្នន័យចម្បង

វុត្តោទយប្បករណ៍ រចនាដោយព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈ

### ១.៤.២-ឯកសារបន្ទាប់បន្សំ

ឆន្ទោសារត្ថមេទិនី រចនាដោយព្រះវជិរបញ្ញត្ថេរៈ។[២]

ឆន្ទោមញ្ជរី រចនាដោយ ព្រះវិសុទ្ធាចារត្ថេរ

ឆន្ទោសារត្ថមញ្ជូសា រចនាដោយព្រះញាណិន្ទត្ថេរ

វុត្តោទ័យ ប្រែនិងរៀបរៀងដោយព្រះញាណបវរវិជ្ជា អែម

វុត្តោទយប្បករណ រចនាដោយព្រះសង្ឃរក្ខិតមហាសាមិ ប្រែលោតប្រយោគដោយ កញ្ញា មាស ស៊ីថា

វុត្តោទយពោធិនី (ច្បាប់ថៃ)។

ទិន្ន័យដែលបានមកពីការចុះទៅធ្វើបទសម្ភាសដោយផ្ទាល់ជាមួយនឹងសាស្ត្រាចារ្យបាលីដូចជា

- បាលិបារគូ **ឌូច សុវណ្ណមុនី**
- ព្រះតេជព្រះគុណ **មួង សារុទ្ធី**

## ១.៥-ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ទំហំនៃការស្រាវជ្រាវក្នុងឆន្ទោជោតកៈនេះ ក្រុមទូលព្រះបង្គំ ខ្ញុំព្រះករុណា សូមលើកយកតែ **មត្តាវុត្តិ ឬ មត្តាគាថា** ដែលព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈសំដែងទុកក្នុងវុត្តោទយប្បករណ៍មកធ្វើជាឯកសារគោលក្នុងការសិក្សាស្រាវជ្រាវដោយមិនលើកយក **វណ្ណវុត្តិ ឬវណ្ណគាថា** មកធ្វើការស្រាវជ្រាវនោះឡើយ។ ហើយលទ្ធផលក្នុងការស្រាវជ្រាវនេះ ផ្តោតសំខាន់ដល់ការសិក្សាស្វែងរកគាថាដែលមានប្រាកដក្នុងព្រះត្រៃបិដក និងអដ្ឋកថា ឬគម្ពីរនានា ដែលសមស្របតាមមេសូត្រ និងប្លង់សម្រាប់រចនាគាថានោះ ៗ តែប៉ុណ្ណោះ ដោយក្រុមបានយកគាថាទាំងអស់នោះ មកធ្វើជាអាគតដ្ឋាន ជាក់ស្តែងដើម្បីបង្ហាញថាប្រភេទ មត្តាគាថា ដែលបានពោលទុកក្នុងប្រធានបទថា ឆន្ទោជោតកៈ នេះពិតជាមានក្នុងគម្ពីរទាំងអស់នោះមែន។ ចុងក្រោយ ការសិក្សាស្រាវជ្រាវក្នុងប្រធានបទខាងលើនេះ សម្រាប់ប្រើប្រាស់តែក្នុងវិស័យពុទ្ធិកសិក្សាមុខវិជ្ជាភាសាបាលីនេះតែប៉ុណ្ណោះ។

## ១.៦-សារប្រយោជន៍នៃការស្រាវជ្រាវ

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវដោយយកចិត្តទុកដាក់ខ្ពស់ និងវិធីសាស្ត្រស្រាវជ្រាវមួយដែលមានឯកសារត្រឹមត្រូវនិងគ្រប់គ្រាន់មក ប្រយោជន៍ដែលបានមកពីការស្រាវជ្រាវនេះ បានធ្វើឱ្យក្រុមចេះដឹងដូចជា៖

---

២ វុត្តោទយប្បករណ៍ រចនាដោយព្រះសង្ឃរក្ខិតមហាសាមិត្ថេរ, ឆន្ទោសារត្ថមេទិនី រចនាដោយព្រះវជិរបញ្ញត្ថេរ, ឆន្ទោមញ្ជរី រចនាដោយ ព្រះវិសុទ្ធាចារត្ថេរ, ឆន្ទោសារត្ថមញ្ជូសា រចនាដោយព្រះញាណិន្ទត្ថេរ, បរិវត្តដោយ មហាធម្មកណ្ឋាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យ-បញ្ញាសាស្ត្រកម្ពុជា, ខែកទ្រេបទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ។

– យល់ដឹងពីនិយមន័យ ឬអត្ថន័យនៃ គរុ លហុ គណ មត្តា ឆន្ទ និងគាថា ជាដើម។
– ស្គាល់និមយន័យ ឬអត្ថន័យនៃឈ្មោះរបស់គាថានីមួយៗ ច្បាស់លាស់។
– ដឹងវិធីរចនាគាថាដោយអាស្រ័យមេសូត្រដែលអាចារ្យពោលប្រាប់ក្នុងគម្ពីរនោះស្រាប់។
– អាចត្រួតពិនិត្យគាថាប្រភេទមត្តាគាថានេះបាន ដោយពឹងផ្អែកលើមេសូត្រនិងប្លង់។

## ១.៧-រចនាសម្ពន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជា ៤ ជំពូកគឺ



# ជំពូក២
# រំលឹកទ្រឹស្តី

## ២.១-និយមន័យ

ទ្រឹស្តីដែលត្រូវលើកឡើង មានការទាក់ទងនឹងប្រធានបទកំពុងធ្វើការសិក្សាស្រាវជ្រាវ ដើម្បីធានាបានថា ការសិក្សាស្រាវជ្រាវមួយនេះអាចជឿជាក់បាន និងមានប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយមានដូចជា៖

### ២.១.១-ឆន្ទោជោតក

ឆន្ទោជោតក មកពី **ឆន្ទ**-សទ្ទបបទ + **ជុត**-បកាសនេ + **ណ្វុ**-បច្ច័យ, ប្រែថា គម្ពីរសម្រាប់សំដែងនូវឆន្ទ **វិ. ឆន្ទំ ជោតេតិ ឯតេនាតិ ឆន្ទោជោតកំ** (**បករណំ**), (កត្តុរូប-ករណសាធនៈ)។ ឬម្យ៉ាងទៀតប្រែថា គម្ពីរជាទីសំដែងនូវឆន្ទ វិ. **ឆន្ទំ ជោតេតិ ឯត្ថាតិ ឆន្ទោ-ជោតកំ** (**បករណំ**), (កត្តុរូប-អធិករណសាធនៈ)។

### ២.១.២-មត្តា

**មត្តា** មកពី **មា**-ធាតុ (**បរិមាណេ**) ក្នុងអត្ថថា ប្រមាណ ចុះ **ត**-បច្ច័យ និង**អា**-ឥត្ថិជោតក-បច្ច័យ។ ប្រែថា កាលឯណាដែលបុគ្គលរមែងប្រមាណ ព្រោះហេតុនោះ កាលនោះ ឈ្មោះថា **មត្តា**, **វិ. មីយតីតិ មត្តា**។ **មត្តា**-សព្ទក្នុងសូត្រនុ៎ះ រមែងពោលនូវកាលគឺត្រឹមតែកិរិយាផ្ទាត់នូវម្រាមនៃដៃ និងកិរិយាប៉ប្រិចនូវភ្នែក សមដូចបាលីក្នុងបទរូបសិទ្ធិថា **មត្តាសទ្ទោ ចេត្ថ អច្ឆរាសង្ឃាតអក្ខិនិ-មីលនសង្ខាតំ កាលំ វទតិ**។

បាលីថា **មត្តា** សំស្រ្កឹតថា **មាត្រា** ក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ (ជោតញាណោ) ជួន ណាត ពន្យល់ថា **មត្តា** និង **មាត្រា** បានដល់ ខ្នាតរបស់សំឡេង ឬរង្វាស់នៃសំឡេង។

សរុបមកថា **មត្តា** សព្ទ ខ្មែរប្រើជា **មាត្រា** បានដល់ ខ្នាតសំឡេងនៃស្រៈទាំងពីរគឺ រស្សៈ និង ទីឃៈ ព្រមទាំងព្យញ្ជនៈ សមដូចបទរូបសិទ្ធិថា **ឯកមត្តា រស្សា** រស្សសរៈទាំងឡាយមានចំនួនមួយ **មាត្រា** (មួយមាត្រាស្មើមួយប៉ប្រិចភ្នែក)។ **ទ្វិមត្តា ទីឃា** ទីឃសរៈទាំងឡាយមានចំនួន ២ មាត្រា (ពីរមាត្រាស្មើពីរប៉ប្រិចភ្នែក)។ **អឌ្ឍមត្តា ព្យញ្ជនា** ព្យញ្ជនៈទាំងឡាយមានចំនួនកន្លះមាត្រា។ កាលបើទីឃសរៈនៅរួមនឹងព្យញ្ជនៈរាប់បាន ២ មាត្រាកន្លះក្នុងប្រយោគធម្មតា តែបើក្នុងគាថាទោះ ២ មាត្រាកន្លះឱ្យរាប់ត្រឹមតែ ២ មាត្រាដដែល។ ចំណែកខាងរស្សៈបើនៅរួមនឹងព្យញ្ជនៈរាប់បាន ១ មាត្រាកន្លះ តែក្នុងគាថាឱ្យរាប់ត្រឹមមួយមាត្រាដដែល។

### ២៣.១.-គាថា

**គាថា** មកពី **គា**-ធាតុ ( **សទ្ទេ** ) ក្នុងអត្ថថា បន្លឺសំឡេង ចុះ **ថ**-បច្ច័យ ឬ**ថកិ**-បច្ច័យ[៣] ចុះ **អា**-ឥត្ថិជោតកបច្ច័យ។ ប្រែថា បទឯណាដែលបុគ្គលរមែងសូត្រ ព្រោះហេតុនោះ បទនោះ ឈ្មោះថា **គាថា**, វិ. **គាយតីតិ គាថា**[៤] (កម្មរូប-កម្មសាធនៈ)។ ម្យ៉ាងទៀតពាក្យថា **គាថា** នេះ មកពី **គមុ**-ធាតុ ឬ**គម**-ធាតុ ( **ពន្ធនេ** ) ក្នុងអត្ថថា ប្រព័ន្ធ ចុះ **ថ**-បច្ច័យ, លុបទីបំផុតធាតុ។ ប្រែថា បទឯណាដែលត្រូវករីប្រព័ន្ធ ព្រោះហេតុនោះ បទនោះ ឈ្មោះថា **គាថា**, វិ. **គមិតព្វា ពន្ធិតព្វាតិ គាថា**[៥](កម្មរូប-កម្មសាធនៈ)។

ពាក្យថា **គាថា** នេះមានសព្ទវេវចនៈ ដែលអាចជំនួសគ្នាប្រើបានដូចជា **សិលោកោ**, **គាថា**, **វុត្តិ**, **វុត្តំ**, **បជ្ជំ**។ **សិលោកោ** ជាបុំលិង្គ **វុត្តិ** និង **គាថា** ជាឥត្ថីលិង្គ, **វុត្តំ** និង **បជ្ជំ** ជានបុំសកលិង្គ។

### ២.១.៤-មត្តាគាថា

**មត្តាគាថា** មកពី **មត្តា** និង **គាថា** ។ ប្រែថា គាថាដែលអាចារ្យប្រព័ន្ធដោយការរាប់ចំនួនមាត្រា មានវិគ្គហៈថា **មត្តាយ ពន្ធិតា គាថា មត្តាគាថា** (តតិយាតប្បុរិសសមាសជាមជ្ឈេលោបសមាស), ឬវិគ្គហៈមួយបែបទៀតថា **មត្តាយ និយមេត្វា ពន្ធិតគាថា មត្តាគាថា** (តតិយាតប្បុរិសសមាសជាមជ្ឈេលោបសមាស)។

ពាក្យដែលជាវេវចនៈនឹងពាក្យថា **មត្តាគាថា** នេះឃើញមានប្រើដូចជា **មត្តាវុត្តិ**, **មត្តាវុត្តំ**, **មត្តាបជ្ជំ**។ សមដូចសាធកៈក្នុងគម្ពីរ ឆន្ទោសារត្ថមញ្ជូសា ថា **តាយ** (**មត្តាយ**) **និយមេត្វា ពន្ធិតបជ្ជំ មត្តាបជ្ជំ**[៦] គាថាដែលត្រូវប្រព័ន្ធដោយការកំណត់ចំនួនមាត្រា។

ភាពផ្សេងគ្នារវាងវណ្ណគាថា និងមត្តាគាថាដូច្នេះគឺ **មត្តាគាថា** បានដល់គាថាដែលរចនាដោយការរាប់ចំនួនមាត្រា ចំណែកឯ **វណ្ណគាថា** បានដល់ គាថាដែលរចនាដោយរាប់ចំនួនអក្ខរៈឬព្យាង្គ។

### ២.១.៥-លហុ

**លហុ** មកពី **លង្ឃ**-ធាតុ (**គតិយំ**) ក្នុងអត្ថថា ប្រព្រឹត្តទៅ ចុះ **ឧ**-បច្ច័យ, អាទេសៈ **ឃ** ជា **ហ**,

---

៣ កិ នេះអានថា ថ-បច្ច័យមាន ក ជាអនុពន្ធ ជាបច្ច័យក្នុងគម្ពីរមោល្លាន។

៤ ព្រះពុទ្ធប្បិយភិក្ខុ, ចូឡធាតុបច្ចយជោតិកា, បរិវត្តដោយមហាធម្មកណ្ឋាគារិកៈ វ៉ាន់ ចាន់សារ៉ែន, ហួយ វ៉ាន់ ថន, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព.ស. ២៥៦៤ គ.ស. ២០២១, ទំព័រ ៥៨០ (PDF)។

៥ ព្រះពុទ្ធប្បិយភិក្ខុ, ចូឡធាតុបច្ចយជោតិកា, បរិវត្តដោយមហាធម្មកណ្ឋាគារិកៈ វ៉ាន់ ចាន់សារ៉ែន, ហួយ វ៉ាន់ ថន, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព.ស. ២៥៦៤ គ.ស. ២០២១, ទំព័រ ៥៨១ (PDF)។

៦ ព្រះញាណិន្ទត្ថេរ, ឆន្ទោមញ្ជរីដីកា ឈ្មោះ ឆន្ទោសារត្ថមញ្ជូសា, បរិវត្តដោយ មហាធម្មកណ្ឋាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញា-សាស្ត្រកម្ពុជា, ខែកទ្រេបទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រ ២៦១។

លុបនិគ្គហិត។ ប្រែថា (ស្រះឯណា) រមែងប្រព្រឹត្តទៅដោយភាពលឿនរហ័ស ព្រោះហេតុនោះ (ស្រះនោះ) ឈ្មោះថា **លហុ**, **វិ. លហុភាវេន លង្ឃតិ បវត្តតីតិ លហុ**[៧] (កត្តុរូប-កត្តុសាធន)។ **រស្ស** និង **លហុ** ជាសព្ទអាចផ្លាស់ប្តូរគ្នាប្រើបាន គ្រាន់តែប្លែកគ្នាហៅដូច្នេះគឺ **រស្ស** ជាគូនិង **ទីឃ** ចំណែកឯ **លហុ** ជាគូនិង **គរុ**។ សមដូចកច្ចាយនសូត្រលេខ ៤ សំដែងថា **លហុមត្តា តយោ រស្សា** ស្រះចំនួន ៣ ដែលមានកាលបន្លឺសំឡេងរហ័ស ឈ្មោះថា រស្ស។

### ២.១.៦-គរុ

**គរុ** មកពី **គរ**-ធាតុ (**គតិយំ**) ក្នុងអត្ថថា ប្រព្រឹត្តទៅ ចុះ **ណុ**-បច្ច័យ ។ ប្រែថា សំឡេងទាំងឡាយឯណារមែងប្រព្រឹត្តទៅដោយភាពមិនឆាប់រហ័ស ព្រោះហេតុនោះ សំឡេងទាំងឡាយនោះឈ្មោះថា **គរុ**, **វិ. គរតិ អសីឃភាវេន បវត្តតីតិ គរុ**[៨] (កត្តុរូប-កត្តុសាធនៈ)។

**គរុ** បានដល់ អក្សរដែលមានសំឡេងមិនឆាប់រហ័ស គឺត្រូវពោលឱ្យយូរ បើរាប់ជាមាត្រាមាន ២មាត្រា។ គរុមាន ៤ គឺ **សំយោគាទិគរុ ១ ទីឃគរុ ១ និគ្គហិតបរគរុ ១ ចាទន្តគរុ ១** ដូចព្រះអាចារ្យសង្ឃរក្ខិតមហាសាមិត្ថេរៈសំដែងទុកក្នុងវុត្តោទយប្បករណ៍គាថាលេខ ៧ ថា

**សំយោគាទិ ច ទីឃោ ច, និគ្គហីតបរោ ច យោ;**

**គរុ វង្កោ ចាទន្តោ វា, រស្សោញ្ញោ មត្តិកោ លុជុ។**

គរុមាន ៤ ប្រភេទគឺ **សំយោគាទិគរុ ១**, **និគ្គហីតបរគរុ ១**, **ទីឃគរុ ១**, **ចាទន្តគរុ ១**, គរុជំនួសដោយសញ្ញាកោង (◡) មានកាលបន្លឺសំឡេងចំនួនពីរមាត្រា, លហុជំនួសដោយសញ្ញាត្រង់ (।) មានកាលបន្លឺសំឡេងចំនួនមួយមាត្រា។

គម្ពីរវុត្តោទ័យ ប្រែនិងរៀបរៀងជាភាសាខ្មែរដោយ **ព្រះញាណបវរវិជ្ជា អែម** ថា សំឡេងដែលពោលធ្ងន់ វែង យូរ កំណត់ពីរមាត្រាហៅថា គរុមាន ៤ គឺ

- អក្ខរៈដែលជាសំយោគសង្កត់ខ្យល់ជាប់នឹងអក្ខរៈខាងចុង ហៅថា សំយោគគរុ មានមាត្រាពីរ
- ស្រះវែង **អា ឦ ឩ ឯ ឱ** ហៅថា **ទីឃគរុ** មានមាត្រាពីរ
- អក្ខរៈដែលមាននិគ្គហិតនៅខាងចុង ហៅថា **និគ្គហិតគរុ** មានមាត្រាពីរ
- អក្ខរៈដែលតាំងនៅខាងដើមបាទក្តី ឬអក្ខរៈដែលតាំងនៅខាងចុងបាទក្តី ក៏ហៅថា **ចាទន្តគរុ** មានមាត្រាពីរ។

---

៧ ព្រះពុទ្ធប្បិយភិក្ខុ, ចូឡធាតុបច្ចយជោតិកា, បរិវត្តដោយ មហាធម្មភណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, ហួយ វ៉ាន់ ថន, បោះពុម្ពដោយពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព.ស. ២៥៦៤ គ.ស. ២០២១, ទំព័រ ១២៧៧ (PDF) ។

៨ ព្រះពុទ្ធប្បិយភិក្ខុ, ចូឡធាតុបច្ចយជោតិកា, បរិវត្តដោយមហាធម្មភណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, ហួយ វ៉ាន់ ថន, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព.ស. ២៥៦៤ គ.ស. ២០២១, ទំព័រ ៥៧៤ (PDF)។

**គរុ** បានដល់ អក្សរដែលមានសំឡេងធ្ងន់, វែង, យូរ មានមាត្រាពីរជំនួសដោយសញ្ញាកោង (◡) ចំណែកឯ **លហុ** បានដល់ អក្សរដែលមានសំឡេងស្រាល, ខ្លី, រហ័ស មានមាត្រាមួយជំនួសដោយសញ្ញាត្រង់ (ı)។

### ២.១.៧-គណ

**គណ** មកពី **គណ**-ធាតុ (**សង្ខ្យានេ**) ក្នុងអត្ថថាការរាប់ ចុះ **អ**-បច្ច័យ ។ ប្រែថា (វត្ថុឯណា) ដែលបុគ្គលរមែងរាប់មួយអន្លើដោយអវយវៈ ព្រោះហេតុនោះ (វត្ថុនោះ) ឈ្មោះថា **គណ** បានដល់ក្រុម, **វិ. អវយវេន សហ គណីយតីតិ គណោ, សមូហោ**[9] (កម្មរូប-កម្មសាធនៈ)។ ម្យ៉ាងទៀតពាក្យថា **គណ** នេះមកពី **អក្ខរ** និង **គណ** ។ ប្រែថា ក្រុមរបស់អក្ខរៈទាំងឡាយ ឈ្មោះថា **គណ**, **វិ. អក្ខរានំ គណោ គណោ** (ឆដ្ឋីតប្បុរិសសមាស ជាអាទិបទលោបសមាស)។

### ២.១.៨-ឆន្ទ

ពាក្យថា **ឆន្ទ** មកពី **ឆទ**-ធាតុ (**សំវរណេ**) ក្នុងអត្ថថា បិទបាំង ចុះ **អ**-បច្ច័យ, ចុះនិគ្គហិតអាគម អាទេសៈនិគ្គហិតជា **ន**-អក្សរ។ ប្រែថា (វិធីឯណា) រមែងបិទបាំងនូវទោស ព្រោះហេតុនោះ (វិធីនោះ) ឈ្មោះ **ឆន្ទ**, **វិ. វជ្ជំ ឆាទយតីតិ ឆន្ទំ**[10] (កត្តុរូប-កត្តុសាធនៈ)។

## ២.២-គណសញ្ញា

គណៈសម្រាប់ប្រើក្នុងវណ្ណគាថាមាន ៨ សមដូចវុត្តោទយប្បករណ៍គាថាលេខ ៥ សំដែងថា

**សព្វគ្វា ម្នាទិគលហូ, ភ្យា មជ្ឈន្តគរូ ជសា;**
**មជ្ឈន្តលា រតេត្ថ, គណា គោ គរុ លោ លហុ។**

គណៈសម្រាប់ប្រើក្នុងវណ្ណគាថាមាន ៨ គឺ មគណៈនិងនគណៈជាគណៈ ដែលមានសំឡេងគរុសុទ្ធ និងលហុសុទ្ធ ភគណៈនិងយគណៈជាគណៈដែលមានសំឡេងគរុក្នុងខាងដើមនិងលហុខាងដើម ជគណៈនិងសគណៈជាគណៈដែលមានសំឡេងគរុក្នុងកណ្តាលនិងគរុក្នុងទីបំផុត រគណៈនិងតគណៈជាគណៈ

---

៩ ព្រះពុទ្ធប្បិយភិក្ខុ, ចូឡធាតុបច្ចយជោតិកា, បរិវត្តដោយមហាធម្មកណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, ហួយ វ៉ាន់ ថន, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព.ស. ២៥៦៤ គ.ស. ២០២១, ទំព័រ ៥៥៧ (PDF)។

១០ ព្រះពុទ្ធប្បិយភិក្ខុ, ចូឡធាតុបច្ចយជោតិកា, បរិវត្តដោយមហាធម្មកណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, ហួយ វ៉ាន់ ថន, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព.ស. ២៥៦៤ គ.ស. ២០២១, ទំព័រ ៦៥៨ (PDF)។

ដែលមានសំឡេងលហុក្នុងកណ្ដាល និងលហុក្នុងទីបំផុត, គ-អក្សរឈ្មោះថា **គរុ** **ល**-អក្សរឈ្មោះថា លហុ។

គណៈទាំង ៨ នេះក្នុងដីកាឈ្មោះ ឆន្ទោសារត្ថមេទិនី ថា **ឯតេ អដ្ឋ គណា វណ្ណវុត្តិយំ ភវន្តិ** គណៈទាំងឡាយ ៨ នេះសម្រាប់ប្រើក្នុងវណ្ណគាថា។ ហើយគណៈទាំងអស់សម្រាប់ប្រើក្នុងវណ្ណគាថានេះមិនរាប់ចំនួនមាត្រាទេ ព្រោះហេតុនេះហើយ ទើបលោកហៅថា **វណ្ណគាថា** បានដល់គាថាដែលរាប់ចំនួនអក្ខរៈ។

សូមសង្កេតតារាងគណៈក្នុងវណ្ណគាថានិងឧទាហរណ៍

| ល.រ. | ឈ្មោះគណៈ | គរុលហុសរូបៈ | ឧទាហរណ៍ | សញ្ញា | ចំនួនអក្ខរៈ |
|---|---|---|---|---|---|
| ១ | មគណៈ | **សព្វគរុ** (សំឡេងគរុសុទ្ធ) | **សព្វញ្ញូ** | ◡◡◡ | |
| ២ | នគណៈ | **សព្វលហុ** (សំឡេងលហុសុទ្ធ) | **សុមុនិ** | ɩɩɩ | |
| ៣ | ភគណៈ | **អាទិគរុ** (សំឡេងគរុខាងដើម) | **មារជិ** | ◡ɩɩ | |
| ៤ | យគណៈ | **អាទិលហុ** (សំឡេងលហុខាងដើម) | **មហេសី** | ɩ◡◡ | ៣ |
| ៥ | ជគណៈ | **មជ្ឈគរុ** (សំឡេងគរុកណ្ដាល) | **មុនិន្ទ** | ɩ◡ɩ | |
| ៦ | សគណៈ | **អន្តគរុ** (សំឡេងគរុខាងចុង) | **សុគតោ** | ɩɩ◡ | |
| ៧ | រគណៈ | **មជ្ឈលហុ** (សំឡេងលហុកណ្ដាល) | **ជាយកោ** | ◡ɩ◡ | |
| ៨ | តគណៈ | **អន្តលហុ** (សំឡេងលហុខាងចុង) | **មារារិ** | ◡◡ɩ | |

ចំណែកខាងគណៈសម្រាប់ប្រើក្នុងមត្តាគាថាមាន ៥ គណៈគឺ ភគណៈ ១ ជគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។[១១] ដូចព្រះអាចារ្យសំដែងទុកក្នុងវុត្តោទយប្បករណ៍គាថាលេខ ៦ ថា

**ភជសា សព្វគលហូ, បញ្ចមេ សណ្ឋិតា គណា;**
**អរិយាទិម្ហិ វិញ្ញេយ្យា, គណោ ឥធ ចតុក្កលោ។**

(មត្តាគាថាចុះគណៈ ៥) គឺ ភគណៈ១ ជគណៈ១ សគណៈ១ មគណៈ ១ និងនគណៈ១ ដែលតាំងនៅហើយ (ក្នុងប្រភេទនៃគាថា) មានអរិយាគាថាជាដើម គណៈ (សម្រាប់ចុះក្នុងមត្តាគាថា) នេះមានចំនួន ៤ មាត្រា។

---

១១ មត្តាគាថានេះ ក្នុងគាថាខ្លះឃើញនាំយកគណៈក្នុងវណ្ណគាថាគឺ រគណៈ យគណៈ មកប្រើផងដែរ។

តារាងគណៈក្នុងមត្តាគាថានិងឧទាហរណ៍

| ល.រ. | ឈ្មោះគណៈ | គរុលហុសរូបៈ | ឧទាហរណ៍ | សញ្ញា | ចំនួនមាត្រា |
|---|---|---|---|---|---|
| ១ | ភគណៈ | អាទិគរុ (សំឡេងគរុខាងដើម) | មារជិ | ᑌıı | ៤ |
| ២ | ជគណៈ | មជ្ឈគរុ (សំឡេងគរុកណ្តាល) | មុនិន្ទ | ıᑌı | |
| ៣ | សគណៈ | អន្តគរុ (សំឡេងគរុខាងចុង) | សុគតោ | ııᑌ | |
| ៤ | មគណៈ | សព្វគរុ (សំឡេងគរុសុទ្ធ) | ជាថោ | ᑌᑌ | |
| ៥ | នគណៈ | សព្វលហុ (សំឡេងលហុសុទ្ធ) | វរតនុ | ııı | |

## ២.៣-ហេតុនាំឱ្យកើតគាថា

**កឹសុ និទានំ គាថានំ, កឹសុ តាសំ វិយញ្ជនំ;**

**កឹសុ សន្និស្សិតា គាថា, កឹសុ គាថានមាសយោតិ។**

(ទេវបុត្រសួរថា) អ្វីហ្ន៎ ជាដើមហេតុនៃគាថាទាំងឡាយ អ្វីហ្ន៎ ជាគ្រឿងបង្កើតគាថាទាំងឡាយនោះ គាថាអាស្រ័យនឹងអ្វី អ្វីជាទីអាស្រ័យរបស់គាថាទាំងឡាយ ។

**ឆន្ទោ និទានំ គាថានំ, អក្ខរា តាសំ វិយញ្ជនំ;**

**នាមសន្និស្សិតា គាថា, កវិ គាថានមាសយោតិ។**

(ព្រះពុទ្ធត្រាស់ថា) ឆន្ទ ជាដើមហេតុនៃគាថាទាំងឡាយ អក្ខរៈ ជាគ្រឿងបង្កើតគាថាទាំងឡាយនោះ គាថាអាស្រ័យនឹងនាម ចិន្តកវី ជាទីអាស្រ័យរបស់គាថាទាំងឡាយ។[១២]

ក្នុងដីកានោះដដែលបានសំដែងថា **អក្ខរសមុទាយោ បទំ** ក្រុមនៃអក្ខរៈឈ្មោះថា **បទ**, **បទសមុទាយោ គាថា** ក្រុមនៃបទឈ្មោះថា **គាថា**។[១៣]

## ២.៤-លក្ខណៈផ្សេងគ្នារវាងឆន្ទ និងគាថា

**អក្ខរនិយមោ ឆន្ទំ, គរុលហុនិយមោ ភវេ វុត្តិ។**[១៤]

ការកំណត់អក្ខរៈឈ្មោះថា ឆន្ទ ការកំណត់គរុនិងលហុឈ្មោះថា គាថា។

---

១២ ព្រះត្រៃបិដកបាលី និងសេចក្តីប្រែជាភាសាខ្មែរ, សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ បឋមភាគ ២៩ កវិសូត្រទី ១០, ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ, បោះពុម្ពលើកទី ២, ព.ស. ២៥០៦, ទំព័រ ១០០ ។

១៣ សុត្តន្តបិដក (ដីកា) សំយុត្តនិកាយ (ដីកា) សគាថវគ្គ (ដីកា) ទេវតាសំយុត្តំ (ច្បាប់ឆដ្ឋសង្គាយនា)។

១៤ ពាលាវតារ, គណ្ឋិបទត្ថវិនិច្ឆយសារ, សន្ធិកណ្ឌ (ឆដ្ឋសង្គាយនា)។

# ជំពូកទី៣
# ប្រែលោតប្រយោគ និងបរិយាយមេសូត្រ

## ៣.១-ប្រែលោតប្រយោគ

### ៣.១.១-គណនិយម

ឆដ្ឋោខិលលហុ ជោ វា, គយុតញ្ញេ ឆក្កណា ន ជោ វិសមេ;
អរិយាយន្តទ្ធេ លោ, ឆដ្ឋោន្តេ គោ គណា ឆញ្ញេ។

(គណោ រីគណៈ) ឆដ្ឋោ ទី៦ អខិលលហុ (វា) ជាលហុសុទ្ធ(ក្តី) ជោ វា ជាជគណៈក្តី (ភវតិ រមែងមាន បុព្វទ្ធេ ក្នុងបុព្វទ្ធៈ អរិយាយ នៃអរិយាគាថា); ឆក្កណា រីគណៈចំនួន៦ ទាំងឡាយ គយុតា ដែលប្រកបហើយដោយគរុខាងចុងនៃបាទ អញ្ញេ ដទៃ (ឆដ្ឋគណតោ ចាកគណៈទី ៦ ភវន្តិ រមែងមាន); ជោ រីជគណៈ ន (ភវតិ) រមែងមិនមាន វិសមេ ក្នុងវិសមដ្ឋាន; (គណោ រីគណៈ) ឆដ្ឋោ ទី ៦ លោ ជាលហុ (ភវតិ រមែងមាន) អន្តទ្ធេ ក្នុងអបរទ្ធៈ អរិយាយ នៃអរិយាគាថា; គោ រីគរុ (ភវតិ រមែងមាន) អន្តេ ក្នុងទីបំផុត (អបរទ្ធស្ស នៃអបរទ្ធៈ); គណា រីគណៈទាំងឡាយ ឆ ចំនួន ៦ អញ្ញេ ដទៃ (ឆដ្ឋលហុ ចាន្តគរុតោ ចាកឆដ្ឋលហុនិងបាទន្តគរុ ភវន្តិ រមែងមាន); (ជោ រីជគណៈ ន ភវតិ រមែងមិនមាន វិសមេ ក្នុងវិសមដ្ឋាន)។

### ៣.១.២-យតិនិយម

បឋមទ្ធេ ឆដ្ឋោ ចេ, សព្វលហោត្វាទិ,លហុនិ, ភវតិ យតិ;
តប្បុរកោន្តេបិ ស ចេ, ចរិមេ, បិ ភវតិ ចតុត្ថោន្តេ។

ចេ ប្រសិនបើ ឆដ្ឋោ (គណោ រីគណៈ) ទី ៦ សព្វលហុ ជាសព្វលហុគណៈ (ភវេយ្យ គប្បីមាន) បឋមទ្ធេ ក្នុងបុព្វទ្ធៈ (អរិយាយ របស់អរិយាគាថា), យតិ រីការឈប់បន្លឺសំឡេង ភវតិ រមែងមាន អាទិលហុនិ ក្នុងលហុដំបូង ឯត្ថ (ឆដ្ឋគណោ ក្នុងគណៈទី ៦) នុ៎ះ, ចេ ប្រសិនបើ សោ (ឆដ្ឋគណោ រីគណៈទី ៦) នោះ តប្បុរកោ ជាគណៈដែលមានសព្វលហុគណៈនោះក្នុងខាងចុង (ភវតិ រមែងមាន), (យតិ រីការឈប់បន្លឺសំឡេង) ភវតិ រមែងមាន អន្តេបិ សូម្បីក្នុងទីបំផុតនៃគណៈទី ៦, (ចេ ប្រសិនបើ) ចតុត្ថោ (គណោ រីគណៈ) ទី៤ (តប្បុរកោ ជាគណៈដែលមានសព្វលហុគណៈនោះក្នុងខាងចុង) ភវតិ រមែងមាន ចរិមេបិ សូម្បីក្នុងអបរទ្ធៈ, (យតិ រីការឈប់បន្លឺសំឡេង

ភវតិ រមែងមាន) អន្តេ ក្នុងទីបំផុត (នៃគណៈទី៤), (ចេ ប្រសិនបើ លហុក្ខរោ រីលហុអក្សរ ឆដ្ឋោ ទី ៦ តប្បរកោ ជាគណៈដែលមានសព្វលហុគណៈនោះក្នុងខាងចុង ភវតិ រមែងមាន, យតិ រីការឈប់បន្លឺសំឡេង ភវតិ រមែងមាន អន្តេបិ ក្នុងទីបំផុតនៃលហុអក្សរនោះ) ។

### ៣.១.៣-អរិយាសាមញ្ញគាថា

អរិយាសាមញ្ញំ ចេ, បុព្វោទិតលក្ខណំ ភវេ យស្សា។

ចេ ថាបើ បុព្វោទិតលក្ខណំ រីលក្ខណៈដែលខ្ញុំបានពោលហើយ (ក្នុង២ គាថា) ខាងដើម ភវេ គប្បីមាន យស្សា (អរិយាយ) ដល់អរិយាគាថាឯណា, (តំ អរិយាបជ្ជំ) រីអរិយាគាថានោះ (បណ្ឌិតេហិ គឺបណ្ឌិតទាំងឡាយ វិញ្ញេយ្យំ គប្បីជ្រាប) អរិយាសាមញ្ញំ ឈ្មោះថា **អរិយាសាមញ្ញគាថា**។

### ៣.១.៤-បថ្យាអរិយាគថា

អាទិមមថ ចាទយុគំ យស្សា, ត្យំសេហិ សា បថ្យា។

អថ ប្រសិនបើ ចាទយុគំ រីគូនៃបាទ អាទិមំ ដំបូង (ឧភយត្ថ បុព្វទ្ធអបរទ្ធេសុ ក្នុងបុព្វទ្ធៈ និងអបរទ្ធៈទាំងឡាយទាំងពីរ) យស្សា (អរិយាគាថាយ របស់អរិយាគាថា) ឯណា (បុព្វោទិត-លក្ខណាយំ ដែលមានលក្ខណៈគឺខ្ញុំពោលហើយ (ក្នុង ២ គាថា) ខាងដើម (យុត្តំ ប្រកបហើយ) ត្យំសេហិ ដោយគណៈចំនួន ៣ ទាំងឡាយ, សា (អរិយាគាថា រីអរិយាគាថា) នោះ (អរិយេហិ គឺអ្នកដ៏ប្រសើរទាំងឡាយ វិញ្ញេយ្យា គប្បីជ្រាប) បថ្យា ឈ្មោះថា **បថ្យាអរិយាគាថា**។

### ៣.១.៥-វិបុលាអរិយាគាថា

យត្ថ គណាត្តយមុល្លង្ឃិ-, យោភយត្ថាទិមោ ភវេ វិបុលា។

(ចេ ប្រសិនបើ) អាទិមោ (បឋមតតិយចាទោ រីបឋមបាទនិងតតិយបាទ) ដំបូង ឧភយត្ថ (បុព្វទ្ធាបរទ្ធេសុ ក្នុងបុព្វទ្ធៈ និងអបរទ្ធៈទាំងឡាយ) ទាំងពីរ យត្ថ (អរិយាយំ ក្នុងអរិយាគាថា) ឯណា ឧល្លង្ឃិយ ឆ្លងហើយ គណាត្តយំ នូវប្រជុំ ៣ នៃគណៈ ភវេ គប្បីមាន, (សា អរិយាគាថា រីអរិយាគាថា) នោះ (វិញ្ញូហិ គឺអ្នកប្រាជ្ញទាំងឡាយ វិញ្ញេយ្យា គប្បីជ្រាប) វិបុលា នាម ឈ្មោះថា **វិបុលាគាថា**។

### ៣.១.៦-ចបលាអរិយាគាថា

គរុមជ្ឈគោ ជការោ, ចតុត្ថកោ ទុតិយកោ ចបលា។

(ចេ ប្រសិនបើ) **ចតុត្ថកោ** (ច) រីចតុត្ថគណៈផង **ទុតិយកោ** (ច) រីទុតិយគណៈផង (**ឧភយត្ថ បុព្វទ្ធអបរទ្ធេសុ** ក្នុងបុព្វទ្ធៈ និងអបរទ្ធៈទាំងឡាយទាំងពីរ **យស្សា អរិយាយ** របស់អរិយាគាថាឯណា **បុព្វោទិតលក្ខណាយ** ដែលមានលក្ខណៈត្រូវខ្ញុំពោលហើយក្នុងខាងដើម), **ជការោ** រីជគណៈ **គរុមជ្ឈគោ** ដែលប្រព្រឹត្តទៅក្នុងកណ្ដាលនៃគរុ (២ សំឡេង) (**ភវតិ** រមែងមាន), (**សា អរិយាគាថា**) រីអរិយាគាថានោះ **ចបលា** (**នាម**) ឈ្មោះថា **បចលាគាថា** (**ភវតិ** រមែងមាន)។

### ៣.១.៧-មុខចបលាអរិយាគាថា

ចបលាគតាខិលំ ចេ, ទលាទិមំ លក្ខណំ ភជតិ យស្សា;
បថ្យាលក្ខណមញ្ញំ, មុខចបលា នាម សា ភវតិ ។

ចេ ប្រសិនបើ **លក្ខណំ** រីលក្ខណៈ (របស់ជគណៈ) **ចបលាគតំ** ដែលប្រាកដហើយក្នុងសូត្រចបលាអរិយាគាថា **អខិលំ** ទាំងអស់ **ភជតិ** រមែងចូលដល់ **ទលំ អាទិមំ** នូវបុព្វទ្ធៈ **យស្សា** (**អរិយាយ** របស់អរិយាគាថា) ឯណា, (**ចេ** ថាបើ) **បថ្យាលក្ខណំ** រីលក្ខណៈនៃបថ្យាអរិយាគាថា (**ភជតិ** រមែងចូលដល់) **អញ្ញំ** (**អបរទ្ធំ** នូវអបរទ្ធៈ) ដទៃទៀត, **សា** (**អរិយា** រីអរិយាគាថា) នោះ **មុខចលបលា នាម** ឈ្មោះថា **មុខចបលាគាថា ភវតិ** រមែងមាន។

### ៣.១.៨-ជឃនចបលាអរិយាគាថា

បថ្យាយ លក្ខណំ ចេ, បឋមទ្ធេ លក្ខណំ តុ ចបលាយ;
ទុតិយេ ទលេច យស្សា, បរិកិត្តិតា សា ជឃនចបលា។

(ចេ ប្រសិនបើ) **លក្ខណំ** រីលក្ខណៈ **បថ្យាយ** របស់បថ្យាអរិយាគាថា (**ភជតិ** រមែងចូលដល់) **បឋមទ្ធេ** ក្នុងបុព្វទ្ធៈ **យស្សា** (**អរិយាយ** របស់អរិយាគាថា) ឯណា, (**អថ** ប្រសិនបើ) **លក្ខណំ** រីលក្ខណៈ **ចបលាយ** របស់ចបលាគាថា (**ភជតិ** ចូលដល់) **ទុតិយេ ទលេ** ក្នុងអបរទ្ធៈ, **សា** (**អរិយា** រីអរិយាគាថា) នោះ (**បណ្ឌិតេហិ** គឺបណ្ឌិតទាំងឡាយ) **បរិកិត្តិតា** ពោលហើយ **ជឃនចបលា** ឈ្មោះថា **ជឃនចបលាគាថា**។

អរិយាជាតិយោ។

**អរិយាជាតិយោ** វីក្រុមរបស់អរិយាគាថាទាំងឡាយ (**និដ្ឋិតា** ចប់ហើយ)។

### ៣.១.៩-គីតិគាថា

សព្វំ បឋមឧលេ យទិ,  លក្ខណមរិយាយ វុត្តមុភយេសុ;
យស្សា ឧលេសុ យុត្តំ,  វុត្តា សា គីតិ វុត្តយតិលលិតា។

**យទិ** ប្រសិនបើ **លក្ខណំ** វីលក្ខណៈ **សព្វំ** ទាំងអស់ (**មយា** គឺខ្ញុំ) **វុត្តំ** ពោលហើយ **បឋម-ឧលេ** ក្នុងបុព្វទ្ធៈ **អរិយាយ** របស់អរិយាគាថា **យុត្តំ** ត្រូវប្រកបហើយ **ឧលេសុ** ក្នុងបុព្វទ្ធៈនិងអបរទ្ធៈទាំងឡាយ **ឧភយេសុ** ទាំងពីរ **យស្សា** (**គាថាយ** របស់គាថា) ឯណា, **សា** (**គាថា** វីគាថា) នោះ **វុត្តយតិលលិតា** ដែលល្អស្អាតដោយយតិគឺខ្ញុំពោលហើយ (**មហាកវីភិ** គឺមហាកវីទាំងឡាយ) **វុត្តា** ពោលហើយ **គីតិ** ឈ្មោះថា **គីតិគាថា**។

### ៣.១.១០-ឧបគីតិគាថា

អរិយាយំ ទុតិយឌ្ឍេ,  គទិតាខិលលក្ខណំ យំ តំ;
ភវតិ ឧលេសុភយេសុបិ,  យទិ យស្សា សាយមុបគីតិ។

**យំ អខិលលក្ខណំ** វីលក្ខណៈទាំងអស់ឯណា (**មយា** គឺខ្ញុំ) **គទិតំ** ពោលហើយ **ទុតិយឌ្ឍេ** ក្នុងអបរទ្ធៈ **អរិយាយំ** ក្នុងអរិយាគាថា (**អត្ថិ** រមែងមាន), **យទិ** ប្រសិនបើ **តំ** (**អខិលលក្ខណំ** វីលក្ខណៈទាំងអស់) នោះ **ភវតិ** រមែងមាន **ឧភយេសុបិ ឧលេសុ** ក្នុងបុព្វទ្ធៈនិងអបរទ្ធៈទាំងឡាយសូម្បីទាំងពីរ **យស្សា** (**គាថាយ** របស់គាថា) ឯណា, **សា អយំ** (**គាថា** វីគាថា) នោះ (**វុត្តយតិលលិតា** ដែលល្អស្អាតដោយយតិគឺខ្ញុំពោលហើយ) **ឧបគីតិ** ឈ្មោះថា **ឧបគីតិគាថា** (**ភវតិ** រមែងមាន)។

### ៣.១.១១-ឧគ្គីតិគាថា

អរិយាយឌ្ឍទ្វិតយំ,  បុព្វោទិតលក្ខណោបេតំ;
វិបរិយយេជាភិហិតំ,  យស្សា សម្ភវតិ ចេហ សោគ្គីតិ។

**ចេ** ថាបើ **អឌ្ឍទ្វិតយំ** វីប្រជុំពីរនៃបុព្វទ្ធៈនិងអបរទ្ធៈ **បុព្វោទិតលក្ខណោបេតំ** ដែលប្រកបដោយលក្ខណៈគឺខ្ញុំពោលហើយក្នុងខាងដើម **អរិយាយ** របស់អរិយាគាថា (**អាចរិយេន**)

អភិហិតំ គឺអាចារ្យរចនាហើយ វិបរិយយេន ដោយការត្រឡប់គ្នា (បុព្វទ្ធាបរទ្ធានំ របស់បុព្វទ្ធៈនិងអបរទ្ធៈទាំងឡាយ ឧភិន្នំ ទាំងពីរ) យស្សា (គាថាយ របស់គាថា) ឯណា សម្ភវតិ រមែងមានសា (គាថា រីគាថា) នោះ (វុត្តយតិលលិតា ដែលល្អស្អាតដោយយតិគឺខ្ញុំពោលហើយ) ឧគ្គីតិ ឈ្មោះថា **ឧគ្គីតិគាថា** (ភវតិ រមែងមាន) ឥហ (គីតិជាតិយំ ក្នុងក្រុមរបស់គីតិគាថា) នេះ។

### ៣.១.១២-អរិយាគីតិគាថា

អរិយាបុព្វទ្ធំ យទិ, គរុនេកេនាធិកេន និធនេ យុត្តំ;
យទិ បុព្វទ្ធសមានំ, ឥតរំ ទលមិតរំ ចោទិតាយមរិយាគីតិ។

យទិ ប្រសិនបើ អរិយាបុព្វទ្ធំ រីបុព្វទ្ធៈរបស់អរិយាគាថា (យស្សា គាថាយ របស់គាថា) ឯណា យុត្តំ ប្រកបហើយ គរុនា ដោយគរុ អធិកេន ដែលមានចំនួនលើស ឯកេន ចំនួនមួយព្យាង្គ និធនេ ក្នុងទីបំផុតនៃបាទទីពីរ, យទិ ថាបើ ឥតរំ ទលំ ច រីអបរទ្ធៈក្រៅនេះផង បុព្វទ្ធសមានំ ដែលមានព្យាង្គដូចគ្នាដោយបុព្វទ្ធៈ (សម្ភវតិ រមែងមាន) អយំ (គាថា រីគាថា) នេះ អរិយាគីតិ ឈ្មោះថា **អរិយាគីតិគាថា** (បិង្គលេន ដែលអាចារ្យបិង្គលៈ) ឧទិតា ពោលហើយ។

### គីតិជាតិយោ។

គីតិជាតិយោ រីពួកនៃគីតិគាថាទាំងឡាយ និដ្ឋិតា ចប់ហើយ។

### ៣.១.១៣-វេតាលីយគាថា

វិសមេ ឆ សិយុំ កលា មុខេ, សមេ ត្វដ្ឋ រលគា តតោបរិ;
វេតាលីយំ តមុច្ចតេ, លហុឆក្កំ ន និរន្តរំ សមេ។

(ចេ ប្រសិនណា) កលា រីមាត្រាទាំងឡាយ ឆ ប្រាំមួយ សិយុំ គប្បីមាន មុខេ ក្នុងខាងដើម វិសមេ ក្នុងវិសមបាទ (យស្ស បជ្ជស្ស របស់គាថាឯណា) តុ ចំណែកឯ (ចេ ថាបើ កលា រីមាត្រាទាំងឡាយ) អដ្ឋ ប្រាំបី (សិយុំ គប្បីមាន មុខេ ក្នុងខាងដើម) សមេ ក្នុងសមបាទ (យស្ស បជ្ជស្ស របស់គាថាឯណា, ចេ ថាបើ) រលគា រីគណៈនិងលហុនិងគរុទាំងឡាយ (សិយុំ គប្បីមាន) ឧបរិ ក្នុងខាងក្រោយ តតោ (ឆមត្តាតោ ច អដ្ឋមត្តាតោ ច ចាក ៦ មាត្រាទាំងឡាយផង ៨ មាត្រាទាំងឡាយផង) នោះ លហុឆក្កំ រីពួកនៃលហុ ៦ ន (ភវតិ រមែងមិនមាន) និរន្តរំ ជាប់តគ្នា សមេ ក្នុងសមបាទ, តំ (លក្ខណសម្បន្នំ បជ្ជំ រីគាថាដែលដល់ព្រមហើយដោយលក្ខណៈនោះ កវិវរេហិ គឺកវីដ៏ប្រសើរទាំងឡាយ) ឧច្ចតេ រមែងពោល វេតាលីយំ ឈ្មោះថា **វេតាលីយគាថា**។

## ៣.១.១៤-ឱបច្ឆន្ទសកគាថា

វេតាលីយោបមំ មុខេ តំ, ឱបច្ឆន្ទសកំ រយា យទន្តេ។

(យទិ ប្រសិនបើ យំ បជ្ជំ រីគាថា) ឯណា វេតាលីយោបមំ ដូចវេតាលីយគាថា មុខេ ក្នុងខាងដើម (វិសមបាទសមបាទានំ នៃវិសមបាទនិងសមបាទទាំងឡាយ សិយា គប្បីមាន), យទិ ប្រសិនបើ រយា រីគណៈ និងយគណៈទាំងឡាយ (សិយុំ គប្បីមាន) អន្តេ ក្នុងទីបំផុត (យថាក្កមំ តាមលំដាប់), តំ (បជ្ជំ រីគាថា) នោះ ឱបច្ឆន្ទសកំ ឈ្មោះថា **ឱបច្ឆន្ទសកគាថា** (ភវតិ រមែងមាន)។

## ៣.១.១៥-អាបាតលិកាគាថា

អាបាតលិកា កថិតាយំ, ភគគាន្តេ យទិ បុព្វមិវញ្ញំ។

យទិ ថាបើ ភគគា រីភគណៈ និងគរុ និងគរុទាំងឡាយ (សិយុំ គប្បីមាន) អន្តេ ក្នុងទីបំផុត (យស្សា គាថាយ នៃគាថាឯណា), យទិ ថាបើ អញ្ញំ (លក្ខណំ រីលក្ខណៈ) ដទៃ បុព្វំ (វេតាលីយំ ឥវ ដូចជាវេតាលីយគាថា) ក្នុងខាងដើម (សិយា គប្បីមាន), អយំ (គាថា រីគាថា) នេះ (កវិវរេហិ គឺកវីដ៏ប្រសើរទាំងឡាយ) កថិតា ពោលហើយ អាបាតលិកា ឈ្មោះថា **អាបាតលិកាគាថា**។

## ៣.១.១៦-ទក្ខិណន្តិកាគាថា

យទាទិតោ ទក្ខិណន្តិកា, បិតេត្ថ បាទេស្វាខិលេសុ ជោ។

យទិ ប្រសិនបើ ជោ រីជគណៈ បិតោ រៀងហើយ អាទិតោ ក្នុងខាងដើម បាទេសុ ក្នុងបាទទាំងឡាយ អខិលេសុ គ្រប់បាទ (យស្សា គាថាយ របស់គាថាឯណា), (បទ ចំណែកឯ សេសំ លក្ខណំ រីលក្ខណៈដែលនៅសល់ វេតាលីយសទិសំ ដូចវេតាលីយគាថា សិយា គប្បីមាន), (សា គាថា រីគាថានោះ ឆន្ទញ្ញូហិ គឺអ្នកចេះនូវឆន្ទទាំងឡាយ កថិតា ពោលហើយ) ឯត្ថ (មត្តាវុត្តិយំ ក្នុងមត្តាគាថា) នុ៎ះ ទក្ខិណន្តិកា ឈ្មោះថា **ទក្ខិណន្តិកាគាថា** ។

## ៣.១.១៧-ឧទិច្ចវុត្តិគាថា

ឧទិច្ចវុត្តីតិ វុច្ចតេ ជោ, បាទោ វិសមេសុ សណ្ឋិតោ។

ចេ ប្រសិនបើ ជោ រីជគណៈ សណ្ឋិតោ តាំងនៅហើយ អាទោ ក្នុងខាងដើម វិសមេសុ ក្នុងវិសមបាទទាំងឡាយ (យស្សា គាថាយ របស់គាថាឯណា, អញ្ញំ លក្ខណំ រីលក្ខណៈដទៃ

វេតាលីយោបមំ ដូចជាវេតាលីយគាថា សិយា គប្បីមាន សា គាថា រីគាថានោះ ឆន្ទញ្ញូហិ គឺអ្នកចេះនូវឆន្ទទាំងឡាយ) វុច្ចតេ រមែងពោល ឧទិច្ចវុត្តិ ឥតិ ឈ្មោះថា **ឧទិច្ចវុត្តិគាថា**។

### ៣.១.១៨-បច្ចវុត្តិគាថា

បុព្វត្ត សមេសុ ចេ គជា,      បច្ចវុត្តិរុទិតាតិ សណ្ឋិតា។

ចេ ថាបើ គជា រីគរុ និងជគណៈទាំងឡាយ សណ្ឋិតា ស្ថិតនៅហើយ បុព្វត្ត (ឋានេសុ ក្នុងទីទាំងឡាយ) ខាងដើម សមេសុ ក្នុងសមបាទទាំងឡាយ (យស្សា គាថាយ របស់គាថាឯណា ចេ ប្រសិនបើ អញ្ញំ លក្ខណំ រីលក្ខណៈដទៃ វេតាលីយោបមំ ដូចវេតាលីយគាថា សិយា គប្បីមាន) (សា គាថា រីគាថានោះ ឆន្ទញ្ញូហិ គឺអាចារ្យអ្នកដឹងនូវឆន្ទទាំងឡាយ) ឧទិតា ពោលហើយ បច្ចវុត្តិ ឥតិ ឈ្មោះថា **បច្ចវុត្តិគាថា**។

### ៣.១.១៩-បវត្តកគាថា

សមាសមាត្រាទិនំ សមា,      សំយុតា ភវតិ តំ បវត្តកំ។

ចេ ថាបើ សមាសមា រីសមបាទនិងវិសមបាទទាំងឡាយ អាទិនំ (បច្ចវុត្តិឧទិច្ចវុត្តិ-គាថានំ របស់បច្ចវុត្តិគាថានិងឧទិច្ចវុត្តិគាថាទាំងឡាយ) ដែលតាំងនៅខាងដើម សមាសំយុត្តា ដែលប្រកបព្រមហើយដោយបាទដូចគ្នា (ភវន្តិ រមែងមាន យស្មឹ បជ្ជេ ក្នុងគាថាឯណា), តំ (បជ្ជំ រីគាថា) នោះ បវត្តកំ ឈ្មោះថា **បវត្តកគាថា** ភវតិ រមែងមាន អត្រ (ឆន្ទសិ ក្នុងគម្ពីរឆន្ទ) នេះ ។

### ៣.១.២០-អបរន្តិកាគាថា

អស្ស សា សមកតាបរន្តិកា។

(យទិ ថាបើ យា គាថា រីគាថាឯណា) សមកតា ដែលអាចារ្យរចនាហើយដោយសមបាទ អស្ស (វេតាលីយស្ស របស់វេតាលីយគាថា) នោះ (អត្ថិ រមែងមាន), សា (គាថា រីគាថា) នោះ អបរន្តិកា ឈ្មោះថា **អបរន្តិកាគាថា**។

### ៣.១.២១-ចារុហាសិនីគាថា

តទញ្ញជា ចារុហាសិនី។

(*យា គាថា* រីគាថាឯណា) *តជ្ជញ្ញជា* ដែលកើតហើយដោយវិសមបាទដទៃ ចាកសមបាទរបស់វេតាលីយគាថានោះ (*សា គាថា* រីគាថានោះ) *ចារុហាសិនី* ឈ្មោះថា **ចារុហាសិនីគាថា** (*ភវតិ* រមែងមាន)។

*វេតាលីយជាតិយោ។*

*វេតាលីយជាតិយោ* រីក្រុមរបស់វេតាលីយគាថាទាំងឡាយ *និដ្ឋិតា* ចប់ហើយ។

### ៣.១.២២-អចលធិតិគាថា

*ទ្វិកវិហតវសុលហុ អចលធិតិរិហ។*

(*ចេ* ថាបើ) *ទ្វិកវិហតវសុលហុ* រីលហុ ៨ ព្យាង្គដែលត្រូវគុណដោយចំនួន ២ (*ភវតិ* រមែងមាន *ចាទេសុ* ក្នុងបាទទាំងឡាយ *ចតូសុ* បួន *សោឡសមត្តិកេសុ* ដែលមានចំនួនមាត្រា ១៦ (*យស្សា គាថាយ* របស់គាថាឯណា), (*សា វុត្តិ* រីគាថានោះ) *អចលធិតិ* ឈ្មោះថា **អចល-ធិតិគាថា** (*ភវតិ* រមែងមាន) *ឥហ* (*ឆន្ទសិ* ក្នុងគម្ពីរឆន្ទនេះ)។

### ៣.១.២៣-មត្តាសមកគាថា

*មត្តាសមកំ នវមោ លគន្តេ។*

(*ចេ* ប្រសិនបើ) *នវមោ* (*មត្តិកោ* រីមាត្រា) ទី៩ *លោ* ជាលហុ (*ភវតិ* រមែងមាន *ចាទេសុ* ក្នុងបាទទាំងឡាយ *សោឡសមត្តិកេសុ* ដែលមានចំនួន ១៦ មាត្រា (*មត្តាសមកេ* ក្នុងមត្តា-សមកគាថា ), (*ចេ* ថាបើ) *គោ* រីគរុ *អន្តេ* ក្នុងទីបំផុតនៃបាទ (*ភវតិ* រមែងមាន), (*តំ បជ្ជំ* រីគាថានោះ) *មត្តាសមកំ* ឈ្មោះថា **មត្តាសមកគាថា** (*ភវតិ* រមែងមាន)។

### ៣.១.២៤-វិសិលោកគាថា

*ជោ ន្លាថវាណ្ណវា វិសិលោកោ។*

(*ចេ* ប្រសិនបើ) *ជោ* រីជគណៈ (*ភវតិ* រមែងមាន *បរំ* ខាងចុង *អណ្ណវា* ចាក ៤ មាត្រាដំបូង *ចាទេសុ* ក្នុងបាទទាំងឡាយ *សោឡសមត្តិកេសុ* ដែលមានចំនួន ១៦ មាត្រា), *អថវា* ឬថា *ន្លា* រីនគណៈ និងលហុទាំងឡាយ (*ភវន្តិ* រមែងមាន *បរំ* ខាងចុង) *អណ្ណវា* ចាក៤ មាត្រាដំបូង, (*ច* និង *គរុកោ* រីគរុ *ភវតិ* រមែងមាន *អន្តេ* ក្នុងទីបំផុត), (*សោ សិលោកោ* រីគាថានោះ) *វិសិលោកោ* ឈ្មោះថា **វិសិលោកគាថា** (*ភវតិ* រមែងមាន)។

### ៣.១.២៥-វានវាសិកាគាថា

តទ្វយតោ វានវាសិកាខ្យា។

(ចេ ប្រសិនបើ) ជោ (អថវា) រឺជគណៈក្តី ន្លា (អថវា) រឺនគណៈនិងលហុទាំងឡាយក្តី (ភវន្តិ រមែងមាន បរំ ខាងចុង) តទ្វយតោ ចាកប្រជុំ ២ (នៃមាត្រា ៤) នោះ (=ចាក៨មាត្រានោះ) (បាទេសុ ក្នុងបាទទាំងឡាយ សោឡសមត្តិកេសុ ដែលមានចំនួនមាត្រា ១៦ ច និង គរុកោ រឺគរុ ភវតិ រមែងមាន អន្តេ ក្នុងទីបំផុត វានវាសិកាយំ ក្នុងវានវាសិកាគាថា យស្សា ឯណា សា គាថា រឺគាថានោះ) វានវាសិកា ឈ្មោះថា **វានវាសិកាគាថា** ភវតិ រមែងមាន។

### ៣.១.២៦-ចិត្រាគាថា

បញ្ចដ្ឋនវសុ យទិ លោ ចិត្រា។

យទិ ថាបើ លោ រឺលហុ (ភវតិ រមែងមាន) បញ្ចដ្ឋនវសុ ក្នុងមាត្រា ៥ និងមាត្រា ៨ និងមាត្រា ៩ ទាំងឡាយ (បាទេសុ ក្នុងបាទទាំងឡាយ សោឡសមត្តិកេសុ ដែលមានមាត្រា ១៦ (យស្សំ ចិត្រាយំ ក្នុងចិត្រាគាថាឯណា), (ច ថែមទាំង គរុកោ រឺគរុ ភវតិ រមែងមាន អន្តេ ក្នុងទីបំផុត (នៃបាទ) សា គាថា រឺគាថានោះ) ចិត្រា ឈ្មោះថា **ចិត្រាគាថា** (ភវតិ រមែងមាន)។

### ៣.១.២៧-ឧបចិត្រាគាថា

គល្យាដ្ឋហិ ចេសា វុបចិត្រា។

ចេ ប្រសិនបើ គល្យា រឺគរុនិងលហុនិងយគណៈទាំងឡាយ (ភវន្តិ រមែងមាន បរំ ក្នុងខាងចុង) អដ្ឋហិ (កលាហិ ចាកមាត្រាទាំងឡាយ) ៨ បាទេសុ ក្នុងបាទទាំងឡាយ សោឡសមត្តិកេសុ ដែលមានមាត្រា ១៦ (ចេ ប្រសិនបើ គរុកោ រឺគរុ ភវតិ រមែងមាន អន្តេ ច ក្នុងទីបំផុត (នៃបាទ) ផង ឧបចិត្រាយំ ក្នុងឧបចិត្រាគាថា យស្សំ ឯណា សា គាថា រឺគាថានោះ) ឧបចិត្រា ឈ្មោះថា **ឧបចិត្រាគាថា** (ភវតិ រមែងមាន)។

### ៣.១.២៨-បាទាកុលកគាថា

យមតីតលក្ខណវិសេសយុតំ, (ចិត្រា)
មត្តាសមាទិបាទាភិហិតំ; (វិសិលោក)
អនិយតវុត្តបរិមាណសហិតំ, (វានវាសិកា)
បថិតំ ជនេសុ បាទាកុលកំ។ (វិសិលោក)

យំ (បជ្ជំ) រីគាថាឯណា **អតីតលក្ខណវិសេសយុតំ** ដែលប្រកបហើយដោយលក្ខណៈដ៏វិសេស (របស់គាថាចំនួន ៥ មានមត្តាសមកគាថាជាដើម ដែលអាចារ្យពោលហើយ) ក្នុងខាងដើម **មត្តាសមាទិបាទាភិហិតំ** (ដែលអាចារ្យ) រចនាហើយដោយបាទរបស់គាថាមានមត្តាសមកគាថាជាដើម **អនិយតវុត្តបរិមាណសហិតំ** ដែលប្រកបដោយចំនួននៃគាថាមិនពិតប្រាកដ (**ភវតិ** រមែងមាន **តំ បជ្ជំ** រីគាថានោះ) **បថិតំ** ដែលប្រាកដហើយ **ជនេសុ** ក្នុងជនទាំងឡាយ (**ឆន្ទញ្ញូសុ** ជាអ្នកចេះនូវឆន្ទ) **បាទាកុលកំ** ឈ្មោះថា **បាទាកុលកគាថា** (**ភវតិ** រមែងមាន)។

## មត្តាសមកជាតិយោ។

**មត្តាសមកជាតិយោ** រីក្រុមនៃមត្តាសមកគាថាទាំងឡាយ **និដ្ឋិតា** ចប់ហើយ។

### ៣.១.២៩-គាទិសង្ខ្យានយ:

វិនា វណ្ណេហិ មត្តា គា, វិនា វណ្ណា គរូហិ តុ;
វិនា លហូហិ គរវោ, ទលេ បជ្ជាទិនោ មតា។

**គា** រីគរុទាំងឡាយ (**សោតុជនេហិ** គឺអ្នកសិក្សាទាំងឡាយ **មត្តា** ដឹងហើយ) **ទលេ** ក្នុងបុព្វទ្ធៈនិង អបរទ្ធៈ **បជ្ជាទិនោ** (**សិលោកស្ស** របស់គាថា) ដែលមានបថ្យាអរិយាគាថាជាដើម **វិនា ដោយការលុប វណ្ណេហិ** ដោយក្រុមព្យាង្គទាំងឡាយ **មត្តា** ចាកមាត្រាដែលជាលហុ, **តុ** ចំណែកខាង **វណ្ណា** រីក្រុមព្យាង្គទាំងឡាយ (**សោតុជនេហិ** គឺអ្នកសិក្សាទាំងឡាយ **មតា** ដឹងហើយ) **វិនា** ដោយការលុប **គរូហិ** ដោយព្យាង្គដែលជាគរុទាំងឡាយ (**មត្តា** ចាកមាត្រាជាលហុ), (**តុ** ចំណែកខាង) **លហូនិ** រីលហុទាំងឡាយ (**សោតុជនេហិ** គឺអ្នកសិក្សាទាំងឡាយ) **មតា** ដឹងហើយ **វិនា** ដោយការលុប **គរវោ** ដោយគរុទាំងឡាយ **វណ្ណា** ចាកក្រុមព្យាង្គ។

## ឥតិ វុត្តោទយេ ឆន្ទសិ មត្តាវុត្តិនិទ្ទេសោ នាម ទុតិយោ បរិច្ឆេទោ។

**បរិច្ឆេទោ** រីបរិច្ឆេទ **ទុតិយោ** ទី២ **មត្តាវុត្តិនិទ្ទេសោ នាម**
ឈ្មោះថា មត្តាវុត្តិនិទ្ទេស **ឆន្ទសិ** ក្នុងគម្ពីរឆន្ទ **វុត្តោទយេ** ឈ្មោះវុត្តោទយៈ **ឥតិ** ចប់ហើយ។

## ៣-២.បរិយាយមេសូត្រ

### ៣.២.១-តណៈនិយមៈ

មុននឹងចូលដល់ការកំណត់គណៈក្នុងក្រុមនៃអរិយាគាថានេះ អ្នកសិក្សាទាំងឡាយ គប្បីស្គាល់ពាក្យមួយចំនួនដូចជា **បុព្វទ្ធ**, **អបរទ្ធ**, **វិសមដ្ឋាន**, **សមដ្ឋាន** ព្រោះពាក្យទាំងអស់នេះជាបច្ចេកសព្ទដែលមានប្រើក្នុងក្រុមអរិយាគាថា។

សួរថា៖ ហេតុអ្វីចាំបាច់ត្រូវស្គាល់ពាក្យទាំងអស់ខាងលើនេះ? ឆ្លើយថា បានជាចាំបាច់ត្រូវស្គាល់ពាក្យទាំងអស់ខាងលើនេះជាមុនសិន ព្រោះក្នុងអរិយាគាថាជាដើមនោះ ត្រូវព្រះអាចារ្យកំណត់ប្រើពាក្យទាំងនេះ ដើម្បីធ្វើឱ្យអ្នកសិក្សាងាយស្រួល ក្នុងការសង្កេតតាមបំណង ដែលលោកបានសំដែងទុកក្នុងអរិយាគាថាជាដើមនោះឯង។

ពាក្យថា **បុព្វទ្ធ** ប្រែថា កន្លះខាងដើមនៃគាថា បានដល់ **បឋមបាទ និងទុតិយបាទ** ចំណែក **អបរទ្ធ** ប្រែថា កន្លះខាងចុងនៃគាថា បានដល់ **តតិយបាទ** និង**ចតុត្ថបាទ**។

ពាក្យថា **វិសមេ** ក្នុងគាថានេះបានដល់ **វិសមដ្ឋាន** ៗ បានដល់ឋាន ៤ គឺ **បឋមវិសមដ្ឋាន តតិយវិសមដ្ឋាន បញ្ចមវិសមដ្ឋាន** និង **សត្តមវិសមដ្ឋាន** សមដូចសាធកៈដែលព្រះដីកាចារ្យសំដែងទុកក្នុងឆន្ទោសារត្ថមេទិនី ថា **វិសមេ បឋមតតិយបញ្ចមសត្តមក្ខេត្តេ ចតុដ្ឋានេ**។ ចំណែកឯ **សមដ្ឋាន** បានដល់ឋាន ៤ គឺ **ទុតិយសមដ្ឋាន ចតុត្ថសមដ្ឋាន ឆដ្ឋសមដ្ឋាន** និង**អដ្ឋមសមដ្ឋាន**។

ភាពខុសគ្នានៃ **វិសមបាទ** និង **វិសមដ្ឋាន** ដូច្នេះគឺ **វិសមបាទ** បានដល់ **បឋមបាទ** និង **តតិយបាទ**។ ចំណែក **វិសមដ្ឋាន** បានដល់ **បឋមវិសមដ្ឋាន តតិយវិសមដ្ឋាន បញ្ចមវិសមដ្ឋាន** និង**សត្តមវិសមដ្ឋាន**។

ភាពខុសគ្នានៃ **សមបាទ** និង **សមដ្ឋាន** ដូច្នេះគឺ **សមបាទ** បានដល់ **ទុតិយបាទ** និង**ចតុត្ថបាទ**។ ចំណែក **សមដ្ឋាន** បានដល់ **ទុតិយសមដ្ឋាន ចតុត្ថសមដ្ឋាន ឆដ្ឋសមដ្ឋាន** និង**អដ្ឋមសមដ្ឋាន**។

បន្ទាប់ពីបានស្គាល់អត្ថន័យរបស់បុព្វទ្ធៈ និងអបរទ្ធៈជាដើមហើយ ឥឡូវនេះនឹងសំដែងតាមបំណងរបស់គាថាលេខ ១៧ នេះ ដែលព្រះអាចារ្យសំដែងទុកថា បុព្វទ្ធៈនេះចែកចេញជា ៤ លក្ខណៈគឺ

លក្ខណៈទី ១ ត្រូវមាន ៧ គណៈនិងមានគរុតាំងនៅខាងចុងបាទ។

លក្ខណៈទី ២ ត្រង់គណៈទី ៦ ត្រូវប្រកបដោយជគណៈ ឬនគណៈ។

លក្ខណៈទី ៣ ក្នុងវិសមដ្ឋានហាមវៀងជគណៈ។

លក្ខណៈទី ៤ គណៈដែលនៅសល់វៀងគណៈមួយណាក៏បាន។

ចំណែកខាងអបរទ្ធៈក៏ចែកចេញជា ៤ លក្ខណៈដែរ គឺ

លក្ខណៈទី ១ ត្រូវមាន ៧ គណៈនិងមានគរុតាំងនៅខាងចុងបាទ។

លក្ខណៈទី ២ គណៈទី ៦ ត្រូវតែជាលហុ។

លក្ខណៈទី ៣ ក្នុងវិសមដ្ឋានហាមរៀងជគណៈ។

លក្ខណៈទី ៤ គណៈដែលនៅសល់រៀងគណៈមួយណាក៏បាន។

សមដូចគាថាលេខ ១៧ ដែលសំដែងដោយព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈថា

**ឆដ្ឋោ ចិ លលហុ ជោ វា, គយុតញ្ញេ ឆក្កណា ន ជោ វិសមេ;**

**អរិយាយដ្ឋច្ឆេ លោ, ឆដ្ឋោ ន្តេ គោ គណា ឆញ្ញេ។**

គណៈទី ៦ ជានគណៈក្តី ជាជគណៈក្តី (រមែងមានក្នុងបុព្វទ្ធៈនៃអរិយាគាថា), គណៈចំនួន ៦ ទាំងឡាយដែលប្រកបហើយដោយបាទន្តគរុ (ផ្សេងពីគណៈទី ៦ រមែងមាន), ជគណៈរមែងមិនមានក្នុងវិសមដ្ឋាន, គណៈទី ៦ ជាលហុ (រមែងមាន) ក្នុងអបរទ្ធៈនៃអរិយាគាថា, គរុ (រមែងមាន) ក្នុងទីបំផុត (នៃអបរទ្ធៈ), គណៈទាំងឡាយចំនួន ៦ ផ្សេងពី (ឆដ្ឋលហុ និងបាទន្តគរុរមែងមាន), (ជគណៈរមែងមិនមានក្នុងវិសមដ្ឋាន)។

ពោលឱ្យពិស្តារតាមដីកាឈ្មោះ ឆន្ទោសារត្ថមេទិនី ថា ក្នុងបុព្វទ្ធៈនេះចែកចេញជា ៨ ឋាន ក្នុងអបរទ្ធៈក៏ចែកចេញជា ៨ ឋានដូចគ្នា។

បុព្វទ្ធៈចែកចេញជា ៨ ឋានគឺ

- **បឋមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **ទុតិយសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៥ នេះគឺ ភគណៈ ១ ជគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **តតិយវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **ចតុត្ថសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៥ នេះគឺ ភគណៈ ១ ជគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **បញ្ចមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **ឆដ្ឋសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ២ នេះគឺ ជគណៈ ១ នគណៈ ១។
- **សត្តមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **អដ្ឋមសមដ្ឋាន** ឱ្យរៀងគរុ ១ សំឡេង។

អបរទ្ធៈក៏ចែកចេញជា ៨ ឋានដូចក្នុងបុព្វទ្ធៈដែរ ខុសតែត្រង់លេខរៀងទី ៦ គឺ **ឆដ្ឋសមដ្ឋាន** ឱ្យរៀងលហុ ១ សំឡេងតែប៉ុណ្ណោះ។

អរិយាគាថានេះ បឋមបាទមានចំនួន ១២ មាត្រា ទុតិយបាទមានចំនួន ១៨ មាត្រា តតិយបាទមាន ចំនួន ១២ មាត្រា ចតុត្ថបាទមានចំនួន ១៥ មាត្រា។ ក្នុងបុព្វទ្ធៈមានចំនួន ៣០ មាត្រា។ ចំណែកខាង អបរទ្ធៈមានចំនួន ២៧ មាត្រា។ បើសរុបចំនួនមាត្រាទាំងបុព្វទ្ធៈនិងអបរទ្ធៈមានចំនួន ៥៧ មាត្រា។

សូមបញ្ជាក់ថា គាថាលេខ ១៧ នេះជាមេសូត្រ ដែលអាចារ្យសំដែងមកដើម្បីកំណត់វិធីចុះគណៈ ក្នុងក្រុមនៃអរិយាគាថា និងក្រុមនៃគីតិគាថាទាំងអស់ ដែលនឹងមានពេលនៅខាងមុខចាប់ពីគាថាលេខ ២០, ២១...ជាដើមតទៅ។ តែបើនឹងសួររកឈ្មោះគាថាលេខ ១៧ នេះថា តើលោកប្រព័ន្ធដោយគាថាអ្វី? ឆ្លើយថា គាថាលេខ ១៧ នេះលោកប្រព័ន្ធដោយប្រើលក្ខណៈរបស់អរិយាសាមញ្ញគាថា ទាំងលក្ខណៈទាំង លក្ខ្យៈរបស់អរិយាសាមញ្ញគាថានោះ មានសំដែងនៅគាថាលេខ ១៩ ខាងមុខ។ ដូច្នេះគាថានេះក៏បាន ឈ្មោះថា អរិយាសាមញ្ញគាថា ដែលជាប្រភេទអរិយាគាថាធម្មតាៗ តែប៉ុណ្ណោះ។

ចំណាំ លក្ខណៈដែលផ្សេងគ្នារវាងបុព្វទ្ធៈ និងអបរទ្ធៈនេះគឺ ក្នុងឆដ្ឋសមដ្ឋាននៃបុព្វទ្ធៈឱ្យរៀងគណៈ បាន ២ គឺជគណៈ ឬនគណៈ ចំណែកខាងអបរទ្ធៈវិញ ក្នុងឆដ្ឋសមដ្ឋានឱ្យរៀងតែលហុ ១ សំឡេង។ ឯលក្ខណៈដទៃទៀតដូចគ្នាទាំងអស់។

គាថាដែលជាឧទាហរណ៍ទាំងអស់ខាងលើនេះ ឈ្មោះថា អរិយាសាមញ្ញគាថា ឬហៅត្រឹមតែអរិយា-គាថាក៏បាន។

### ៣.២.២-យតិនិយមៈ

ពាក្យថា **យតិ** នេះបានដល់ ការឈប់បន្តិសំឡេង សមដូចសាធកៈក្នុងឆន្ទោសារត្ថមេទិនី ថា **វិច្ឆេទោ យតិ នាម។**

ការប្រើយតិនេះ ព្រះសង្ឃរក្ខិតមហាសាមិត្ថេរាចារ្យបានសំដែងនៅក្នុងគាថាលេខ ១០ ខាងដើមរួច ហើយ ដែលមាននិយាយទាក់ទងនឹងការឈប់បន្តិសំឡេងត្រង់ទីបំផុតបាទជាដើម ក្នុងគាថានេះមិនពោល ដល់រឿងហ្នឹងទៀតទេ សូមអធិប្បាយត្រឹមតែលក្ខណៈដែលមានក្នុងគាថានេះ។

យតិក្នុងអរិយាគាថានេះទាក់ទិននឹងសព្វលហុគណៈក្នុងទីតាំង ៤ យ៉ាងគឺ

- ក្នុងបុព្វទ្ធៈ បើគណៈទី ៦ ជាសព្វលហុគណៈ យតិរមែងមានត្រង់លហុខាងដើមគណៈទី ៦។
- ក្នុងបុព្វទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានត្រង់លហុខាងចុងគណៈទី ៦។
- ក្នុងអបរទ្ធៈ បើគណៈទី ៥ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃគណៈទី៤។
- ក្នុងអបរទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃលហុអក្សរដែលតាំងនៅ ហើយក្នុងគណៈទី ៦។

សមដូចគាថាលេខ ១៨ ដែលមានប្រាកដក្នុងវុត្តោទយប្បករណ៍ថា

*បឋមេច្ឆ ឆដ្ឋោ ចេ, សព្វលហោត្វាធិ,លហុធិ, ភវតិ យតិ;*
*តប្បរកោរេច្ចបិ ស ចេ, ចរិមេ,ឋិ ភវតិ ចតុត្ថោវេ្ត។*

ក្នុងបុព្វទ្ធៈ បើគណៈទី ៦ ជាសព្វលហុគណៈ (= នគណៈ), យតិរមែងមានត្រង់លហុដំបូង, ក្នុងបុព្វទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃគណៈទី ៦; ក្នុងអបរទ្ធៈ បើគណៈទី ៥ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃគណៈទី ៤; ក្នុងអបរទ្ធៈ បើគណៈទី ៧ ជាសព្វសហុគណៈ យតិរមែងមានក្នុងទីបំផុតនៃលហុអក្សរដែលតាំងនៅហើយក្នុងឋានទី ៦ នោះ។

ដើម្បីឱ្យងាយសង្កេតក្នុងការប្រើយតិ (ការឈប់បន្លឺសំឡេង) ក្រុមខ្ញុំសូមជំនួសដោយសញ្ញាចុល្លភាគ (,) នេះ ឬដែលធ្លាប់តែហៅថាក្បៀសនោះ មកធ្វើការកត់សំគាល់ក្នុងគាថានៅក្នុងជំពូកទី ៤។

## ៣.២.៣-*អរិយាសាញ្ញគាថា*

បទថា *អរិយាសាមញ្ញ* នេះមានបទវិគ្គហៈថា *អរិយាហិ សាមញ្ញំ អរិយាសាមញ្ញំ* គាថាដែលទូទៅដោយអរិយាគាថាទាំងឡាយឈ្មោះថា *អរិយាសាមញ្ញ* (*អរិយ* + *សាមញ្ញ* ក្នុងតតិយាតប្បុ.)។

គាថានេះ ជាគាថាដែលប្រព្រឹត្តទៅដោយការកំណត់ចំនួនមាត្រា គណៈដែលយកមករៀងទុកក្នុងអរិយាសាមញ្ញគាថា មាន ៥ គណៈគឺ ភគណៈ ជគណៈ សគណៈ មគណៈ និង នគណៈ, គណៈទាំង ៥ នេះមានចំនួន ៤ មាត្រាដូចគ្នាទាំងអស់។

លក្ខណៈទាំងអស់របស់គាថានេះ ដូចបានពោលហើយក្នុង ២ គាថាខាងដើមគឺ គាថាលេខ ១៧ និង គាថាលេខ ១៨។ គាថាលេខ ១៧ សំដែងអំពីការកំណត់គណៈដែលត្រូវរៀងក្នុងអរិយាសាមញ្ញគាថា។ គាថាលេខ ១៨ សំដែងអំពីការកំណត់យតិដែលត្រូវឈប់បន្លឺសំឡេងក្នុងអរិយាសាមញ្ញគាថា។

អរិយាគាថានេះ បឋមបាទមានចំនួន ១២ មាត្រា ទុតិយបាទមានចំនួន ១៨ មាត្រា តតិយបាទមានចំនួន ១២ មាត្រា ចតុត្ថបាទមានចំនួន ១៥ មាត្រា។ ក្នុងបុព្វទ្ធៈមានចំនួន ៣០ មាត្រា។ ចំណែកខាងអបរទ្ធៈមានចំនួន ២៧ មាត្រា។ បើសរុបចំនួនមាត្រាទាំងបុព្វទ្ធៈ និងអបរទ្ធៈមានចំនួន ៥៧ មាត្រា។

សរុបមកថា គាថាណាដែលប្រកបដោយលក្ខណៈរបស់គាថាលេខ ១៧ និងគាថាលេខ ១៨ គាថានោះឈ្មោះថា អរិយាសាមញ្ញគាថា ដូចគាថាដែលព្រះអាចារ្យសំដែងទុកក្នុងវុត្តោទយប្បករណ៍ថា

*អរិយាសាមញ្ញំ ចេ, បុព្វេ ឧទិតលក្ខណំ ភវេ យស្សា។*

លក្ខណៈរបស់គាថាឯណា ដែលលោកពោលហើយក្នុង ២ គាថាខាងដើម គាថានោះបណ្ឌិតគប្បីជ្រាបថាជា **អរិយាសាមញ្ញគាថា។**

## ៣.២.៤-*បថ្យាអរិយាគាថា*

បទថា *បថ្យាអរិយា* មានវិគ្គហៈថា *បថ្យា ច សា អរិយា ចាតិ បថ្យាអរិយា* គាថាដែលកវីគប្បីពោលផង គាថាដែលកវីគប្បីពោលនោះជាអរិយាគាថាផង ព្រោះហេតុដូច្នោះ ឈ្មោះថា *បថ្យា-*

អរិយា (បថ្យា + ច + ត + អរិយា + ច ក្នុងអត្ថវិសេសនបុព្វបទ.)។

បថ្យាអរិយាគាថានេះ មិនមានអ្វីឱ្យប្លែកពិសេសជាងអរិយាសាមញ្ញគាថានោះទេ ព្រោះលក្ខណៈគាថាលេខ ១៧ និងគាថាលេខ ១៨ ត្រូវបានយកមកប្រើក្នុងគាថានេះដដែល គ្រាន់តែក្នុងគាថានេះអាចារ្យសំដែងដល់បឋមបាទ និងទុតិយបាទ ត្រូវប្រកបដោយគណៈទាំងឡាយ ៣ ហើយគណៈទាំង ៣ នោះមានចំនួន ១២ មាត្រា។ ម្យ៉ាងទៀតលោកពោលទុកក្នុងដីកាថា យតិរមែងមានក្នុងទីបំផុតនៃបឋម-បាទនិងទុតិយបាទ។

សរុបមកថា បឋមបាទ និងទុតិយបាទ ប្រកបដោយលក្ខណៈរបស់គាថាលេខ១៧ និង១៨ ដដែល។ ហើយក្នុងបឋមបាទ និងទុតិយបាទនោះ ប្រកបដោយគណៈទាំងឡាយ ៣ ឈ្មោះថា បថ្យាអរិយាគាថា ដូចគាថាលេខ ២០ ដែលអាចារ្យសំដែងថា

អាទិមមេច ទាទយុតំ, យស្សា ត្យំសេហិ សា បថ្យា។

ប្រសិនបើ ចំនួន ២ បាទដំបូងរបស់អរិយាគាថា ដែលមានលក្ខណៈគឺខ្ញុំពោលហើយក្នុង ២ គាថាមុន ដែលប្រកបហើយដោយចំនួន ៣ គណៈទាំងឡាយ, អរិយាគាថានោះ អ្នកដ៏ប្រសើរទាំងឡាយគប្បីជ្រាបថា ឈ្មោះថា **បថ្យាអរិយាគាថា**។

### ៣.២.៤-វិបុលាអរិយាគាថា

បទថា វិបុលា មានវិគ្គហៈថា បថ្យាតោ វិសិដ្ឋេន បការេន ឧលតិ បវត្តតីតិ វិបុលា គាថាឯណារមែងប្រព្រឹត្តទៅដោយប្រការដ៏វិសេសជាងបថ្យាអរិយាគាថា ព្រោះហេតុនោះ គាថានោះឈ្មោះថា វិបុលា (ឧ-វិសិដ្ឋបការ + លុ-បវត្តនេ + អ)។

គាថានេះត្រូវយកលក្ខណៈរបស់គាថាលេខ ១៧ និង ១៨ មកធ្វើជាលក្ខណៈរបស់ខ្លួន ដែលខុសគ្នានោះត្រង់ទីបំផុតនៃបឋមបាទ និងទុតិយបាទក្នុងបុព្វទ្ធៈ និងអបរទ្ធៈត្រូវលើសលហុ ១ សំឡេង ( = ១មាត្រា) ឬគរុ ១ សំឡេង ( = ២មាត្រា)។

សរុបមួយគាថាបួនបាទត្រូវជា ៥៧ មាត្រា។ សមដូចគាថាលេខ ២១ ដែលអាចារ្យសំដែងទុកក្នុងវុត្តោទយប្បករណ៍ថា

យត្ថ គណាត្តយមុល្លង្ឃិ-, យោភយត្ថាទិមោ ភវេ វិបុលា។

ប្រសិនបើ បឋមបាទនិងតតិយបាទដំបូង ក្នុងបុព្វទ្ធៈនិងអបរទ្ធៈទាំងពីរ របស់អរិយាគាថាឯណា (ដែលមានលក្ខណៈត្រូវខ្ញុំពោលហើយក្នុងសូត្រដំបូងមានជាអាទិ៍ថា ឆដ្ឋោ ចិ លលហុ ជោ វា) ដែឆ្លងផុតហើយនូវក្រុមនៃគណៈទាំង ៣, អរិយាគាថានោះ វិញ្ញូជនទាំងឡាយគប្បីជ្រាបឈ្មោះថា **វិបុលា-គាថា**។

វិបុលាអរិយាគាថានេះ បើនឹងពោលឱ្យពិស្តារមាន ៣ ប្រភេទទៀតគឺ មុខវិបុលាអរិយា-គាថា ១ ជឃនវិបុលាអរិយាគាថា ១ ឧភយវិបុលាអរិយាគាថា ១ ដូចឆន្ទោសារត្ថមេទិនីថា វិបុលា ហិ មុខវិបុលាជឃនវិបុលាឧភយវិបុលាវសេន តិវិធា ភវេ។ ព្រះវជិរបញ្ញត្ថេរៈ

សំដែងបន្តទៀតថា

**វិបុលាឲ្យន្តសព្វត្ថ,          ភេទេន តិវិធា ភវេ។**

វិបុលាអរិយាគាថានេះ ចែកជា ៣ ប្រភេទគឺ **អាទិវិបុលាអរិយាគាថា ១ អន្តវិបុលាអរិយាគាថា ១ សព្វវិបុលាអរិយាគាថា ១។**

ចំណែកឯ ឆន្ទោសារត្ថមញ្ជូសា ដែលរចនាដោយព្រះញាណិន្ទត្ថេរៈថា **តត្ថ វិបុលាគាថា តិវិធា ហោតិ មុខវិបុលា ជឃនវិបុលា មហាវិបុលា** (បណ្តាវិបុលានិងចបលាទាំងឡាយ) នោះ វិបុលាគាថាមាន ៣ ប្រការគឺ **មុខវិបុលាគាថា ១ ជឃនវិបុលាគាថា ១ មហាវិបុលា-គាថា។**[១៥]

គណៈដែលអាចលើសបានមាន ៥ គណៈគឺ

– រៀងឱ្យបាន ៣ គណៈ បើឆ្លងចូលភគណៈអាចលើសគរុ ១ សំឡេង

– រៀងឱ្យបាន ៣ គណៈ បើឆ្លងចូលជគណៈអាចលើសលហុ ១ សំឡេង

– រៀងឱ្យបាន ៣ គណៈ បើឆ្លងចូលសគណៈអាចលើសលហុ ១ សំឡេង

– រៀងឱ្យបាន ៣ គណៈ បើឆ្លងចូលមគណៈអាចលើសគរុ ១ សំឡេង

– រៀងឱ្យបាន ៣ គណៈ បើឆ្លងចូលនគណៈអាចលើសលហុ ១ សំឡេង។

បីគណៈឆ្លងចូលគណៈ ៥ គឺ

| បឋមបាទនិងតតិយបាទ | | ទុតិយបាទនិងចតុត្ថបាទ |
|---|---|---|
| ៣គណៈ | ∪ | ıı = ភគណៈ |
| | ı | ∪ ı = ជគណៈ |
| | ı | ı ∪ = សគណៈ |
| | ∪ | ∪ = មគណៈ |
| | ı | ı ı ı = នគណៈ |

គាថានេះមានចំនួនមាត្រា ៥៧ ចែកចេញជា ២ គឺ បុព្វទ្ធៈមាន ៣០ មាត្រា និងអបរទ្ធៈមាន ២៧ មាត្រា។ ប្រសិនបើបឋមបាទលើសដោយគរុ ១ សំឡេងមានចំនួន ១៤ មាត្រា ទុតិយបាទមានចំនួន ១៦ មាត្រា។ ប្រសិនបើទុតិយបាទលើសដោយលហុ ១ សំឡេង មានចំនួន ១៣ មាត្រា ចតុត្ថបាទមានចំនួន ១៧ មាត្រា។

---

១៥ វិបុលានិងចបលាគាថានេះ ក្នុងគម្ពីរឆន្ទោសារត្ថមញ្ជូសានោះបានអធិប្បាយគាថាទាំងពីរនេះក្នុងលេខ ២៨៣ ដល់ ២៨៤ ដាក់បញ្ចូលក្នុងលេខឃ្នាបតែមួយ។ ដោយឡែកក្នុងគម្ពីរឆន្ទោសារត្ថមេទិនី មិនបានអធិប្បាយគាថាពីរនេះបញ្ចូលក្នុងលេខឃ្នាបជាមួយគ្នានោះទេ។

### ៣.២.៦-ចបលាអរិយាគាថា

បទថា **ចបលា** មានវិគ្គហៈថា **ចបលតិ វិក្ខិបតីតិ ចបលា** គាថាឯណារមែងញាប់ញ័រ គឺរមែងរសាត់រសាយទៅ ព្រោះហេតុដូច្នោះ គាថានោះ ឈ្មោះថា **ចបលា** (ចុប-សណ្ដានេ/វិក្ខេបនេ + អល-បច្ច័យក្នុងអត្ថសុទ្ធសាធនៈ)។

ក្នុងចបលាអរិយាគាថានេះចែកចេញជា ២ គឺ បុព្វទ្ធៈ និងអបរទ្ធៈ។

១-បុព្វទ្ធៈចែកចេញជា ៨ ឋានគឺ

- បឋមវិសមដ្ឋាន ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ២ នេះគឺ មគណៈ ១ សគណៈ ១។
- **ទុតិយសមដ្ឋាន** ឱ្យរៀងជគណៈ។
- **តតិយវិសមដ្ឋាន** ឱ្យរៀងមគណៈ។
- **ចតុត្ថសមដ្ឋាន** ឱ្យរៀងជគណៈ។
- **បញ្ចមវិសមដ្ឋាន** ឱ្យរៀងមគណៈ ឬភគណៈ។
- **ឆដ្ឋសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ២ នេះគឺ ជគណៈ ១ នគណៈ ១។
- **សត្តមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **អដ្ឋមសមដ្ឋាន** ឱ្យរៀងគរុ ១ សំឡេង។

២-អបរទ្ធៈក៏ចែកចេញជា ៨ ឋានដូចក្នុងបុព្វទ្ធៈដែរ ខុសតែត្រង់លេខរៀងទី ៦ គឺ ឆដ្ឋសមដ្ឋាន ឱ្យរៀងលហុ ១ សំឡេង។

យតិក្នុងចបលាអរិយាគាថានេះទាក់ទិននឹងសព្វលហុគណៈក្នុងទីតាំង ៤ យ៉ាងគឺ

- ក្នុងបុព្វទ្ធៈ បើគណៈទី ៦ ជាសព្វលហុគណៈ យតិរមែងមានត្រង់លហុខាងដើមគណៈទី ៦
- ក្នុងបុព្វទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃគណៈទី ៦
- ក្នុងអបរទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃលហុអក្សរ ដែលតាំងនៅហើយក្នុងគណៈទី ៦។

បឋមបាទមានចំនួន ១២ មាត្រា ទុតិយបាទមានចំនួន ១៨ មាត្រា តតិយបាទមានចំនួន ១២ មាត្រា ចតុត្ថបាទមានចំនួន ១៥ មាត្រា។ ក្នុងបុព្វទ្ធៈមានចំនួន ៣០ មាត្រា។ ចំណែកខាងអបរទ្ធៈមានចំនួន ២៧ មាត្រា។ បើសរុបចំនួនមាត្រាទាំងបុព្វទ្ធៈនិងអបរទ្ធៈមានចំនួន ៥៧ មាត្រា។

សរុបមកថា អរិយាគាថាដែលអាចារ្យរចនាដោយជគណៈតាំងនៅក្នុងទុតិយសមដ្ឋាន និងចតុត្ថ-សមដ្ឋាន ក្នុងរវាងគរុពីរដែលនៅអមសងខាងជគណៈនោះ ឈ្មោះថា **ចបលាអរិយាគាថា**។ សមដូចគាថាលេខ ២២ ដែលព្រះសង្ឃរក្ខិតមហាសាមិត្ថេរាចារ្យសំដែងថា

**គរុមជ្ឈគោ ជការោ, ចតុត្ថគោ ទុតិយគោ ចបលា។**

ប្រសិនបើ ចតុត្ថគណៈ និងទុតិយគណៈ បុព្វទ្ធៈនិងអបរទ្ធៈទាំងពីរ របស់អរិយាគាថាឯណា

ដែលមានលក្ខណៈត្រូវខ្ញុំពោលហើយខាងដើម, ជគណៈដែលប្រព្រឹត្តទៅក្នុងកណ្តាលនៃគរុ ២ សំឡេង រមែងមាន, អរិយាគាថានោះ ឈ្មោះថា **ចបលាគាថា**។

## ៣.២.៧-មុខចបលាអរិយាគាថា

បទថា **មុខចបលា** នេះមានវិគ្គហៈថា **មុខេ ចបលាលក្ខណំ យស្សាតិ មុខចបលា** លក្ខណៈរបស់ចបលាគាថាក្នុងកន្លះដំបូងរមែងមានដល់គាថាឯណា ព្រោះហេតុដូច្នោះ គាថានោះ ឈ្មោះថា **មុខចបលា** (**មុខ** + **ចបលា** + **យ** ក្នុងអត្ថទិ្វបទចតុត្ថីភិន្នាធិករណពហុព្វីហិ.)។

គាថានេះប្រកបដោយលក្ខណៈពីរ គឺ មួយ យកលក្ខណៈរបស់ចបលាអរិយាគាថាក្នុងបុព្វទ្ធៈ មកធ្វើជាលក្ខណៈរបស់ខ្លួនក្នុងបុព្វទ្ធៈ ១, យកលក្ខណៈរបស់បថ្យាអរិយាគាថាក្នុងអបរទ្ធៈ មកធ្វើជាលក្ខណៈរបស់ខ្លួនក្នុងអបរទ្ធៈ ១។

អធិប្បាយថា មុខចបលាអរិយាគាថាចែកជា២ លក្ខណៈគឺ បុព្វទ្ធៈ១ អបរទ្ធៈ១។

បុព្វទ្ធៈចែកចេញជា ៨ ឋានគឺ

- **បឋមវិសមដ្ឋាន** ឱ្យរៀងមគណៈ ឬសគណៈ។
- **ទុតិយសមដ្ឋាន** ឱ្យរៀងជគណៈ។
- **តតិយវិសមដ្ឋាន** ឱ្យរៀងមគណៈ។
- **ចតុត្ថសមដ្ឋាន** ឱ្យរៀងជគណៈ។
- **បញ្ចមវិសមដ្ឋាន** ឱ្យរៀងមគណៈ ឬភគណៈ។
- **ឆដ្ឋសមដ្ឋាន** ឱ្យរៀងជគណៈ ឬនគណៈ។
- **សត្តមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ មគណៈ១ សគណៈ ១ ភគណៈ ១ នគណៈ ១។
- **អដ្ឋមសមដ្ឋាន** ឱ្យរៀងគរុ ១ សំឡេង។

អបរទ្ធៈចែកចេញជា ៨ ឋានគឺ

- **បឋមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **ទុតិយសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៥ នេះគឺ ភគណៈ ១ ជគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **តតិយវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **ចតុត្ថសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៥ នេះគឺ ភគណៈ ១ ជគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។

– **បញ្ចមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។

– **ឆដ្ឋសមដ្ឋាន** ឱ្យរៀងលហុ ១ សំឡេង។

– **សត្តមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។

– **អដ្ឋមសមដ្ឋាន** ឱ្យរៀងគរុ ១ សំឡេង។

យតិក្នុងមុខចបលាអរិយាគាថានេះទាក់ទិននឹងសព្វលហុគណៈក្នុងទីតាំង ៤ យ៉ាងគឺ

- ក្នុងបុព្វទ្ធៈ បើគណៈទី ៦ ជាសព្វលហុគណៈ យតិរមែងមានត្រង់លហុខាងដើមគណៈទី ៦
- ក្នុងបុព្វទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានត្រង់ទីបំផុតនៃគណៈទី ៦
- ក្នុងអបរទ្ធៈ បើគណៈទី ៥ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃគណៈទី ៤
- ក្នុងអបរទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃលហុអក្សរដែលតាំងនៅហើយក្នុងគណៈទី ៦ ។

មុខចបលាអរិយាគាថានេះ បឋមបាទមានចំនួន ១២ មាត្រា ទុតិយបាទមានចំនួន ១៨ មាត្រា តតិយបាទមានចំនួន ១២ មាត្រា ចតុត្ថបាទមានចំនួន ១៥ មាត្រា។ ក្នុងបុព្វទ្ធៈមានចំនួន ៣០ មាត្រា។ ចំណែកខាងអបរទ្ធៈមានចំនួន ២៧ មាត្រា។ បើសរុបចំនួនមាត្រាទាំងបុព្វទ្ធៈនិងអបរទ្ធៈមានចំនួន ៥៧ មាត្រា។

សរុបមកថា ក្នុងបុព្វទ្ធៈនៃមុខចបលាអរិយាគាថានេះ ដូចលក្ខណៈរបស់ចបលាអរិយាគាថាក្នុងបុព្វទ្ធៈ ឯអបរទ្ធៈដូចលក្ខណៈរបស់បថ្យាអរិយាគាថាក្នុងអបរទ្ធៈ។ ដូចគាថាលេខ ២៣ ដែលប្រាកដក្នុងវុត្តោទយប្បករណ៍ថា

**ចបលាគតាទិលំ ចេ, ធលាធិមំ លក្ខណំ ភជតិ យស្សា;**

**បថ្យាលក្ខណមញ្ញំ, មុខចបលា នាម សា ភវតិ។**

ប្រសិនបើលក្ខណៈរបស់ជគណៈ ដែលប្រាកដហើយក្នុងសូត្រ របស់ចបលាអរិយាគាថាទាំងអស់ រមែងចូលដល់នូវបុព្វទ្ធៈរបស់អរិយាគាថាឯណា, ប្រសិនបើ បថ្យាអរិយាគាថា រមែងចូលដល់អបរទ្ធៈដទៃទៀត, អរិយាគាថានោះ ឈ្មោះថា **មុខចបលាគាថា**។

## ៣.២.៨-ជឃនចបលាអរិយាគាថា

បទថា **ជឃនចបលា** មានវិគ្គហៈថា **ជឃនេន ចបលាលក្ខណំ យស្សាតិ ជឃនចបលា** លក្ខណៈរបស់ចបលាគាថាក្នុងអបរទ្ធៈរមែងមានដល់គាថាឯណា ព្រោះហេតុដូច្នោះ គាថានោះ ឈ្មោះថា ជឃនចបលា ( **ជឃន** + **ចបលា** + **យ** ក្នុងអត្ថទ្វិបទចតុត្ថីភិន្នាធិករណពហុព្វីហិ.)។

គាថានេះប្រកបដោយលក្ខណៈ ២ គឺ នាំយកលក្ខណៈរបស់បថ្យាអរិយាគាថាក្នុងបុព្វទ្ធៈ មកធ្វើជាលក្ខណៈរបស់ខ្លួនក្នុងបុព្វទ្ធៈ ១, នាំយកលក្ខណៈរបស់ចបលាអរិយាគាថាក្នុងអបរទ្ធៈមកធ្វើជា លក្ខណៈ

របស់ខ្លួនក្នុងអបរទ្ធៈ ១។

អធិប្បាយថា ជយនចបលាអរិយាគាថាចែកជា ២ លក្ខណៈគឺ បុព្វទ្ធៈ ១ អបរទ្ធៈ ១។ បុព្វទ្ធៈ ចែកជា ៨ឋាននោះគឺ

- **បឋមវិសមដ្ឋាន** ឱ្យរៀងគណៈណាមួយ បណ្ដាគណៈទាំង ៤ គឺ ភគណៈ សគណៈ មគណៈ នគណៈ។
- **ទុតិយសមដ្ឋាន** ឱ្យរៀងគណៈណាមួយ បណ្ដាគណៈទាំង ៥ គឺ ភគណៈ ជគណៈ សគណៈ មគណៈ នគណៈ។
- **តតិយវិសមដ្ឋាន** ឱ្យរៀងគណៈណាមួយ បណ្ដាគណៈទាំង ៤ គឺ ភគណៈ សគណៈ មគណៈ នគណៈ។
- **ចតុត្ថសមដ្ឋាន** ឱ្យរៀងគណៈណាមួយ បណ្ដាគណៈទាំង ៥ គឺ ភគណៈ ជគណៈ សគណៈ មគណៈ នគណៈ។
- **បញ្ចមវិសមដ្ឋាន** ឱ្យរៀងគណៈណាមួយ បណ្ដាគណៈទាំង៤ គឺ ភគណៈ សគណៈ មគណៈ នគណៈ។
- **ឆដ្ឋសមដ្ឋាន** ឱ្យរៀងជគណៈ ឬនគណៈ។
- **សត្តមវិសមដ្ឋាន** ឱ្យរៀងគណៈណាមួយ បណ្ដាគណៈទាំង ៤ គឺ ភគណៈ សគណៈ មគណៈ នគណៈ។
- **អដ្ឋមសមដ្ឋាន** ឱ្យរៀងគរុ១សំឡេង។

អបរទ្ធៈចែកចេញជា ៨ ឋានគឺ

- **បឋមវិសមដ្ឋាន** ឱ្យរៀងសគណៈ ឬមគណៈ។
- **ទុតិយសមដ្ឋាន** ឱ្យរៀងជគណៈ។
- **តតិយវិសមដ្ឋាន** ឱ្យរៀងមគណៈ។
- **ចតុត្ថសមដ្ឋាន** ឱ្យរៀងជគណៈ។
- **បញ្ចមវិសមដ្ឋាន** ឱ្យរៀងមគណៈ ឬភគណៈ។
- **ឆដ្ឋសមដ្ឋាន** ឱ្យរៀងលហុ ១ សំឡេង។
- **សត្តមវិសមដ្ឋាន** ឱ្យរៀងគណៈណាមួយ បណ្ដាគណៈទាំង៤ នេះគឺ ភគណៈ សគណៈ មគណៈ នគណៈ។
- **អដ្ឋមសមដ្ឋាន** ឱ្យរៀងគរុ ១ សំឡេង។

យតិរបស់ជយនចបលាអរិយាគាថានេះទាក់ទិននឹងសព្វលហុគណៈក្នុងទីតាំង ៣ យ៉ាងគឺ

- បុព្វទ្ធៈ បើគណៈទី ៦ ជាសព្វលហុគណៈ យតិរមែងមានត្រង់លហុខាងដើមគណៈទី ៦

– បុព្វទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃគណៈទី ៦
– អបរទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃលហុអក្សរដែលតាំងនៅហើយក្នុងគណៈទី ៦។

ជឃនចបលាអរិយាគាថានេះ បឋមបាទមានចំនួន ១២ មាត្រា ទុតិយបាទមានចំនួន ១៨ មាត្រា តតិយបាទមានចំនួន ១២ មាត្រា ចតុត្ថបាទមានចំនួន ១៥ មាត្រា។ ក្នុងបុព្វទ្ធៈមានចំនួន ៣០ មាត្រា។ ចំណែកខាងអបរទ្ធៈមានចំនួន ២៧ មាត្រា។ បើសរុបចំនួនមាត្រាទាំងបុព្វទ្ធៈនិងអបរទ្ធៈមានចំនួន ៥៧ មាត្រា។

សរុបមកថាជឃនចបលាគាថានេះ ក្នុងបុព្វទ្ធៈរចនាដូចលក្ខណៈរបស់បថ្យាអរិយាគាថា ចំណែកខាងអបរទ្ធៈរចនាដូចលក្ខណៈរបស់ចបលាអរិយាគាថា ហៅថា ជឃនចបលាអរិយាគាថា។ សមដូចគាថាលេខ ២៤ ក្នុងវុត្តោទយប្បករណ៍សំដែងថា

បថ្យាយ លក្ខណំ ចេ, បឋមឌ្ឍេ លក្ខណំ តុ ចបលាយ;
ទុតិយេ ឧលេថ យស្សា, បកិត្តិតា សា ជឃនចបលា។

ប្រសិនបើលក្ខណៈរបស់បថ្យាអរិយាគាថា រមែងចូលដល់ក្នុងបុព្វទ្ធៈ របស់អរិយាគាថាឯណា, ប្រសិនបើលក្ខណៈរបស់ចបលាគាថា រមែងចូលដល់ក្នុងអបរទ្ធៈរបស់អរិយាគាថាឯណា, អរិយាគាថានោះ បណ្ឌិតទាំងឡាយពោលថា **ជឃនចបលាគាថា**។

## សរុបក្រុមអរិយាគាថា ៦ ប្រភេទគឺ

- **អរិយាគាថា ឬអរិយាសាមញ្ញគាថា** បុព្វទ្ធៈនិងអបរទ្ធៈមាន ៧ គណៈ និងគរុ ១ សំឡេងខាងចុងបាទ, ត្រង់វិសមដ្ឋានហាមរៀងជគណៈ, ត្រង់គណៈទី ៦ ក្នុងបុព្វទ្ធៈរៀងជគណៈ ឬនគណៈ ក្នុងគណៈទី ៦ ខាងអបរទ្ធៈរៀងលហុ ១ សំឡេង។
- **បថ្យាអរិយាគាថា** បឋមបាទនិងតតិយបាទមាន ៣ គណៈ គឺថាឱ្យមានយតិត្រង់ ៣ គណៈ លក្ខណៈដទៃដូចគាថាលេខ ១៧ និង ១៨។
- **វិបុលាអរិយាគាថា** បឋមបាទនិងទុតិយបាទលើស ៣ គណៈ លក្ខណៈដទៃដូចគាថាលេខ ១៧ និង ១៨។
- **ចបលាអរិយាគាថា** បឋមបាទនិងទុតិយបាទ រៀងជគណៈកណ្ដាលគរុ, លក្ខណៈដទៃដូចគាថាលេខ ១៧ និង ១៨។
- **មុខចបលាអរិយាគាថា** បុព្វទ្ធៈយកលក្ខណៈរបស់ចបលាអរិយាគាថា អបរទ្ធៈយកលក្ខណៈបថ្យាអរិយា។
- **ជឃនចបលាអរិយាគាថា** បុព្វទ្ធៈយកលក្ខណៈបថ្យាអរិយា អបរទ្ធៈយកលក្ខណៈចបលាអរិយា។

ក្រុមអរិយាគាថាចប់ដោយសង្ខេបតែប៉ុណ្ណេះ។

## ៣.២.៩-គីតិគាថា

បទថា **គីតិ** មានវិគ្គហៈថា **សមេន សរេន គីយតិ ឧច្ចារីយតីតិ គីតិ** គាថាឯណាដែលករីរមែងបន្លឺសំឡេង (រមែងសូធ្យ) ដោយសំឡេងស្មើគ្នា ព្រោះហេតុដូច្នោះ គាថានោះ ឈ្មោះថា **គីតិ** (**គេ-សទ្ទេ/ ឧច្ចារណេ** + **តិ**-បច្ច័យក្នុងអត្ថកម្មសាធនៈ)។

គីតិគាថានេះ ត្រូវនាំយកលក្ខណៈរបស់អរិយាគាថាប៉ែកបុព្វទ្ធៈ មកធ្វើជាលក្ខណៈរបស់ខ្លួនទាំងបុព្វទ្ធៈ ទាំងអបរទ្ធៈ ។

គាថានេះចែកជា ២ ផ្នែកគឺ បុព្វទ្ធៈមួយផ្នែក អបរទ្ធៈមួយផ្នែក។ ទាំងបុព្វទ្ធៈនិងអបរទ្ធៈប្រកបដោយលក្ខណៈ ៤ ដូចគ្នាដូច្នេះគឺ

លក្ខណៈទី ១ ត្រូវមាន ៧ គណៈនិងមានគរុតាំងនៅខាងចុងបាទ។

លក្ខណៈទី ២ ត្រង់គណៈទី ៦ ត្រូវប្រកបដោយជគណៈ ឬនគណៈ។

លក្ខណៈទី ៣ ក្នុងវិសមដ្ឋានហាមរៀងជគណៈ។

លក្ខណៈទី ៤ គណៈដែលនៅសល់រៀងគណៈមួយណាក៏បាន។

គណលក្ខណៈ[១៦]សម្រាប់ប្រើក្នុងគីតិគាថា

បុព្វទ្ធៈចែកចេញជា ៨ ឋានគឺ

- **បឋមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **ទុតិយសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ៥ នេះគឺ ភគណៈ ១ ជគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **តតិយវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **ចតុត្ថសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ៥ នេះគឺ ភគណៈ ១ ជគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **បញ្ចមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **ឆដ្ឋសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ២ នេះគឺ ជគណៈ១ នគណៈ ១។
- **សត្តមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។

---

១៦ ជួនលោកប្រើជាគណនិយមៈ ជួនប្រើជាគណលក្ខណៈ មានន័យថា ប្រើមួយណាក៏បាន ព្រោះពេលដល់វិធីកំណត់គណៈ ឬថា មេសូត្រសម្រាប់រៀងគណៈ ឯពាក្យថា យតិនិយមៈ និងយតិលក្ខណៈប្រើមួយណាក៏បានដូចគ្នា ។

– **អដ្ឋមសមដ្ឋាន** ឱ្យរៀងគរុ ១ សំឡេង។

ចំណែកខាងអបរទ្ធៈចែកឋានជា ៨ ដូចបុព្វទ្ធៈដែរ។

យតិលក្ខណៈសម្រាប់ប្រើក្នុងគីតិគាថា

យតិក្នុងគីតិគាថានេះទាក់ទិននឹងសព្វលហុគណៈក្នុងទីតាំង ៤ យ៉ាងគឺ

– ក្នុងបុព្វទ្ធៈ បើគណៈទី ៦ ជាសព្វលហុគណៈ យតិរមែងមានត្រង់លហុខាងដើមគណៈទី ៦។

– ក្នុងបុព្វទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃគណៈទី ៦។

– ក្នុងអបរទ្ធៈ បើគណៈទី ៦ ជាសព្វលហុគណៈ យតិរមែងមានត្រង់លហុខាងដើមគណៈទី ៦។

– ក្នុងអបរទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃគណៈទី ៦។

បឋមបាទនិងតតិយបាទមានចំនួន ១២ មាត្រាដូចគ្នា ទុតិយបាទនិងចតុត្ថបាទមានចំនួន ១៨ មាត្រាដូចគ្នា។ បុព្វទ្ធៈនិងអបរទ្ធៈមានចំនួន ៣០ មាត្រាដូចគ្នា។ គីតិគាថានេះ មានចំនួន ៦០ មាត្រា។

គីតិគាថានេះ មានលក្ខណៈដូចបុព្វទ្ធៈរបស់អរិយាគាថាដែលពោលមកក្នុងគាថាលេខ ១៧ និង ១៨ ឈ្មោះថា គីតិគាថា សមដូចព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈសំដែងថា

**សព្វំ បឋមទលេ យទិ, លក្ខណមរិយាយ វុត្តមុភយេសុ;**

**យស្សា ទលេសុ យុត្តំ, វុត្តា សា គីតិ វុត្តយតិលលិតា។**

ប្រសិនបើលក្ខណៈទាំងអស់ ដែលខ្ញុំពោលហើយក្នុងបុព្វទ្ធៈនៃអរិយាគាថា ដែលត្រូវប្រកបហើយក្នុងបុព្វទ្ធៈ និងក្នុងអបរទ្ធៈទាំងឡាយទាំងពីររបស់គាថាឯណា, គាថានោះដែលល្អហើយដោយយតិគឺខ្ញុំពោលហើយ ត្រូវមហាកវីទាំងឡាយពោលថា គីតិគាថា។

## ៣.២.១០-ឧបគីតិគាថា

បទថា **ឧបគីតិ** នេះមានវិគ្គហៈថា **គីតិយា សមីបេ បវត្តតីតិ ឧបគីតិ** គាថាឯណារមែងប្រព្រឹត្តទៅក្នុងទីជិតនៃគីតិគាថា ព្រោះហេតុដូច្នោះ គាថានោះ ឈ្មោះថា **ឧបគីតិ** (**ឧប** + **គីតិ** ក្នុងអត្ថឆដ្ឋីអព្យយីភាវ.) ។ គាថាដែលមានលក្ខណៈស្រដៀងគ្នានឹងគីតិគាថា។

ឧបគីតិគាថានេះ មានភាពស្រដៀងគ្នាទៅនឹងគីតិគាថាដោយន័យថា បាននាំយកលក្ខណៈប៉ែកអបរទ្ធៈរបស់អរិយាគាថាខាងដើមក្នុងគាថាលេខ ១៧ និង១៨ មកធ្វើជា លក្ខណៈរបស់ខ្លួនឯងទាំងបុព្វទ្ធៈ និងអបរទ្ធៈ។

គណនិមយៈក្នុងឧបគីតិគាថា

បុព្វទ្ធៈនិងអបរទ្ធៈចែកចេញជា ៨ ឋានព្រមទាំងគណលក្ខណៈក៏រៀងដូចគ្នាតែបែបមួយដូច្នេះគឺ

– **បឋមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។

– **ទុតិយសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង៥ នេះគឺ ភគណៈ ១ ជគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។

– **តតិយវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ១ សគណៈ ១ មគណៈ ១ នគណៈ ១។

– **ចតុត្ថសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៥ នេះគឺ ភគណៈ ១ ជគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។

– **បញ្ចមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។

– **ឆដ្ឋសមដ្ឋាន** ឱ្យរៀងលហុ ១ សំឡេង។

– **សត្តមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។

– **អដ្ឋមសមដ្ឋាន** ឱ្យរៀងគរុ ១ សំឡេង។

យតិនិយមៈក្នុងឧបគីតិគាថា

យតិលក្ខណៈទាក់ទិននឹងសព្វលហុគណៈក្នុងទីតាំង ៤ គឺ

– ក្នុងបុព្វទ្ធៈ បើគណៈទី ៥ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃគណៈទី ៤។

– ក្នុងបុព្វទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃលហុ-អក្សរដែលតាំងនៅហើយក្នុងគណៈទី ៦ ។

– ក្នុងអបរទ្ធៈ បើគណៈទី ៥ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃគណៈទី ៤។

– ក្នុងអបរទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃលហុអក្សរ ដែលតាំងនៅហើយក្នុងគណៈទី ៦ ។

ឧបគីតិគាថានេះ បឋមបាទមានចំនួន ១២ មាត្រា ទុតិយបាទមានចំនួន ១៥ មាត្រាតតិយបាទមានចំនួន ១២ មាត្រា ចតុត្ថបាទមានចំនួន ១៥ មាត្រា។ ក្នុងបុព្វទ្ធៈនិងអបរទ្ធៈមានចំនួន ២៧ មាត្រាដូចគ្នា។ បើសរុបចំនួនមាត្រាទាំងបុព្វទ្ធៈនិងអបរទ្ធៈមានចំនួន ៥៤ មាត្រា។

ពោលដោយសង្ខេបថា គាថាដែលបុព្វទ្ធៈនិងអបរទ្ធៈទាំងពីរដូចប៉ែកអបរទ្ធៈរបស់អរិយាគាថាលេខ ១៧ និង ១៨ ខាងដើមឈ្មោះថា **ឧបគីតិគាថា** ។ ដូចគាថាលេខ ២៦ ដែលអាចារ្យសង្ឃរក្ខិតមហា-សាមិត្ថេរៈសំដែងថា

***អរិយាយំ ទុតិយទ្ធេ, កថិតាវិលលក្ខណំ យំ តំ;***

***ភវតិ ឧភេសុភយេសុបិ, យទិ យស្សា សាយមុបគីតិ។***

លក្ខណៈទាំងអស់ខ្ញុំបានពោលក្នុងអបរទ្ធៈដែលមានក្នុងអរិយាគាថា, ថាបើលក្ខណៈទាំងអស់របស់គាថារមែងមានសូម្បីក្នុងបុព្វទ្ធៈនិងអបរទ្ធៈ, គាថាដែលល្អស្អាតដោយយតិគឺខ្ញុំពោលហើយនោះ ឈ្មោះថា **ឧបគីតិគាថា។**

### ៣.២.១១-ឧគ្គីតិគាថា

បទថា **ឧគ្គីតិ** មានវិគ្គហៈថា **គីតីនំ វិបរីតំ ឧគ្គីតិ** គាថាដែលជាវិបរីតៈរបស់គីតិគាថា ឈ្មោះថា **ឧគ្គីតិ** ( **ឧ-វិបរីត + គីតិ** ក្នុងអត្ថធម្មីអព្យយីភាវៈ) គាថាដែលប្តូរកន្លះខាងចុងជាកន្លះដំបូងរបស់គីតិ-គាថា។

គាថានេះប្រកបដោយលក្ខណៈរបស់អរិយាគាថាលេខ ១៧ និង១៨ ឬថានាំសូត្រទាំងពីរនៃគាថាខាងដើមនោះមកប្រើក្នុងឧគ្គីតិគាថានេះ។

ដូចបានពោលហើយថា សូត្រក្នុងគាថាលេខ ១៧ ពោលអំពីគណនិយមៈ សូត្រក្នុងគាថាលេខ ១៨ ពោលអំពី យតិនិយមៈ។ អ្វីដែលប្លែកពីអរិយាគាថានោះដូច្នេះគឺ យកលក្ខណៈបុព្វទ្ធៈនៃអរិយាគាថាមកធ្វើជាអបរទ្ធៈរបស់ឧគ្គីតិគាថានេះ យកលក្ខណៈអបរទ្ធៈនៃអរិយាគាថាមកធ្វើជាបុព្វទ្ធៈរបស់ឧគ្គីតិគាថានេះ។

គណនិយមៈក្នុងឧគ្គីតិគាថា

សេចក្តីអធិប្បាយថា បុព្វទ្ធៈចែកចេញជា៨ ឋាននោះគឺ

- **បឋមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **ទុតិយសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៥ នេះគឺ ភគណៈ ១ ជគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **តតិយវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **ចតុត្ថសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៥ នេះគឺ ភគណៈ ១ ជគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **បញ្ចមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **ឆដ្ឋសមដ្ឋាន** ឱ្យរៀងបានតែលហុមួយសំឡេង។
- **សត្តមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **អដ្ឋមសមដ្ឋាន** ឱ្យរៀងគរុមួយសំឡេង។

អបរទ្ធៈក៏ចែកចេញជា ៨ ឋានដូចក្នុងបុព្វទ្ធៈដែរ ខុសតែត្រង់លេខរៀងទី ៦ គឺឆដ្ឋសមដ្ឋាន ឱ្យរៀងគណៈបាន ២ គឺ ជគណៈ ឬនគណៈណាមួយ។

យតិនិយមៈក្នុងឧគ្គីតិគាថា

យតិក្នុងឧគ្គីតិគាថានេះទាក់ទិននឹងសព្វលហុគណៈក្នុងទីតាំង ៤ យ៉ាងគឺ

- ក្នុងបុព្វទ្ធៈ បើគណៈទី ៥ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃគណៈទី ៤ ។

– ក្នុងបុព្វទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃលហុ-អក្សរដែលតាំងនៅហើយក្នុងគណៈទី ៦ ។
– ក្នុងអបរទ្ធៈ បើគណៈទី ៦ ជាសព្វលហុគណៈ យតិរមែងមានត្រង់លហុខាងដើមគណៈទី ៦ ។
– ក្នុងអបរទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតគណៈទី ៦។

ឧគ្គីតិគាថានេះ បឋមបាទមានចំនួន ១២ មាត្រា ទុតិយបាទមានចំនួន ១៥ មាត្រា តតិយបាទមានចំនួន ១២ មាត្រា ចតុត្ថបាទមានចំនួន ១៨ មាត្រា។ ក្នុងបុព្វទ្ធៈមានចំនួន ២៧ មាត្រា។ ចំណែកខាងអបរទ្ធៈមានចំនួន ៣០ មាត្រា។ បើសរុបចំនួនមាត្រាទាំងបុព្វទ្ធៈនិងអបរទ្ធៈមានចំនួន ៥៧ មាត្រា។

សង្ខេបមកថា យកបុព្វទ្ធៈរបស់អរិយាគាថា មកធ្វើជាអបរទ្ធៈរបស់ឧគ្គីតិគាថានេះ ហើយយកអបរទ្ធៈរបស់អរិយាគាថា មកធ្វើជាបុព្វទ្ធៈរបស់ឧគ្គីតិគាថានេះ ទើបបានឈ្មោះប្រាកដថា ឧគ្គីតិគាថា។ សមដូចគាថាលេខ ២៧ ដែលព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈសំដែងទុកក្នុងវុត្តោទយប្បករណ៍ថា

**អរិយាយទ្ធទ្ធិតយំ, បុព្វោទិតលក្ខណោបេតំ;**
**វិបរិយយេឋាភិហិតំ, យស្សា សម្ភវតិ ចេហ សោគ្គីតិ។**

ប្រសិនបើ ប្រជុំ ២ នៃបុព្វទ្ធៈនិងអបរទ្ធៈ របស់អរិយាគាថាដែលប្រកបដោយលក្ខណៈគឺខ្ញុំពោលហើយក្នុងខាងដើម ដែលអាចារ្យរចនាហើយដោយការត្រឡប់គ្នា របស់បុព្វទ្ធៈនិងអបរទ្ធៈទាំងពីររបស់គាថាឯណា គាថាដែលបរិសុទ្ធដោយលក្ខណៈគឺខ្ញុំពោលហើយនោះ ឈ្មោះថា **ឧគ្គីតិគាថា** រមែងមានក្នុងក្រុមនៃគីតិជាតិនេះ។

### ៣.២.១២-អរិយាគីតិគាថា

បទថា **អរិយាគីតិ** នេះមានវិគ្គហៈថា **អរិយា ច សា គីតិ ចាតិ អរិយាគីតិ** អរិយាគាថាផងអរិយាគាថានោះជាគីតិគាថាផង ព្រោះហេតុដូច្នោះ ឈ្មោះថា **អរិយាគីតិ** (**អរិយា** + **ច** + **ត** + **គីតិ** + **ច**) ។ គីតិគាថាដែលមានលក្ខណៈដូចអរិយាគាថា។

គាថានេះ ប្រកបដោយលក្ខណៈរបស់អរិយាគាថាដូចគាថាមុនៗ ដោយមួយគាថានេះត្រូវនាំយកលក្ខណៈប៉ែកបុព្វទ្ធៈរបស់អរិយាគាថា មកធ្វើជាលក្ខណៈរបស់ខ្លួនឯងពេញមួយគាថាតែម្តង អ្វីដែលប្លែកពីអរិយាគាថានោះគឺ ក្នុងឆដ្ឋសមដ្ឋានហាមរៀងសព្វលហុគណៈ និងក្នុងអដ្ឋសមដ្ឋានត្រូវរៀងមគណៈឬសគណៈ។

គណនិយមៈក្នុងអរិយាគីតិគាថា

សេចក្តីអធិប្បាយថា បុព្វទ្ធៈនិងអបរទ្ធៈនៃគាថានេះចែកចេញជា ៨ ឋានគឺ

– **បឋមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
– **ទុតិយសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្តាគណៈទាំង ៥ នេះគឺ ភគណៈ ១ ជគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។

- **តតិយវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **ចតុត្ថសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ៥ នេះគឺ ភគណៈ ១ ជគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **បញ្ចមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **ឆដ្ឋសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ២ នេះគឺ ជគណៈ ១ នគណៈ ១។
- **សត្តមវិសមដ្ឋាន** ឱ្យរៀងគណៈមួយណាក៏បាន បណ្ដាគណៈទាំង ៤ នេះគឺ ភគណៈ ១ សគណៈ ១ មគណៈ ១ នគណៈ ១។
- **អដ្ឋមសមដ្ឋាន** ឱ្យរៀងមគណៈ ឬសគណៈ។

យតិនិយមៈក្នុងអរិយាគីតិគាថា

- ក្នុងបុព្វទ្ធៈ បើគណៈទី ៦ ជាសព្វលហុគណៈ យតិរមែងមានត្រង់លហុខាងដើមគណៈទី ៦។
- ក្នុងបុព្វទ្ធៈ បើគណៈទី ៧ ជាសព្វលហុគណៈ យតិរមែងមានក្នុងទីបំផុតនៃគណៈទី ៦។
- ក្នុងអបរទ្ធៈ បើគណៈទី ៦ ជាសព្វលហុគណៈ យតិរមែងមានត្រង់លហុខាងដើមគណៈទី ៦។
- ក្នុងអបរទ្ធៈ បើគណៈទី ៧ ជាសព្វលហុ យតិរមែងមានក្នុងទីបំផុតនៃគណៈទី ៦។

អរិយាគាថានេះ បឋមបាទនិងតតិយបាទមានចំនួន ១២ មាត្រាដូចគ្នា ឯទុតិយបាទនិងចតុត្ថ-បាទមានចំនួន ២០ មាត្រាដូចគ្នា។ ក្នុងបុព្វទ្ធៈនិងអបរទ្ធៈមានចំនួន ៣២ មាត្រា។ បើសរុបចំនួនមាត្រាទាំងបុព្វទ្ធៈនិងអបរទ្ធៈមានចំនួន ៦៤ មាត្រា។

សរុបសេចក្ដីមកថា គាថាដែលបុព្វទ្ធៈ និងអបរទ្ធៈទាំងពីរនេះ រចនាដោយបុព្វទ្ធៈរបស់អរិយាគាថា ហើយក្នុងអដ្ឋមសមដ្ឋានរៀងសគណៈឬមគណៈ ឈ្មោះថា អរិយាគីតិគាថា។ សមដូចគាថាលេខ ២៨ ដែលព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈសំដែងថា

**អរិយាបុព្វឌ្ឍំ យទិ, គរុនេកោជាធិកោន និធនេ យុត្តំ;**
**យទិ បុព្វឌ្ឍសមានំ, ឧលមិតរំ ចោទិតាយមរិយាគីតិ។**

បើបុព្វទ្ធៈនៃអរិយាគាថារបស់គាថាណា ដែលប្រកបហើយដោយគរុ ដែលលើសដោយចំនួនមួយព្យាង្គក្នុងទីបំផុតនៃបាទទីពីរ និងអបរទ្ធៈក្រៅនេះ ដែលមានព្យាង្គដូចគ្នាដោយបុព្វទ្ធៈ គាថានោះ អាចារ្យបិង្គលៈពោលថា **អរិយាគីតិគាថា**។

## សរុបក្រុមគីតិគាថា ៤ ប្រភេទគឺ

- **គីតិគាថា** បុព្វទ្ធៈនិងអបរទ្ធៈដូចបុព្វទ្ធៈរបស់អរិយាគាថា។
- **ឧបគីតិគាថា** បុព្វទ្ធៈនិងអបរទ្ធៈដូចអបរទ្ធៈរបស់អរិយាគាថា។
- **ឧគ្គីតិគាថា** បុព្វទ្ធៈដូចអបរទ្ធៈនៃអរិយាគាថា ឯអបរទ្ធៈដូចបុព្វទ្ធៈនៃអរិយាគាថា។

– **អរិយាគីតិគាថា** គឺតិគាថាដែលថែមគរុមួយសំឡេងទៀត។

ក្រុមគឺតិគាថាចប់ដោយសង្ខេបតែប៉ុណ្ណេះ។

### ៣.២.១៣-វេតាលីយគាថា

ពាក្យថា **វេតាលីយ** មានបទវិគ្គហៈថា **វិសេសោ តាលោ វិតាលោ** ដើមត្នោតវិសេស ឈ្មោះថា **វិតាល** (**វិ**-**វិសេស** + **តាល** ក្នុងអត្ថវិសេសនបុព្វបទកម្មធារយសមាស)។ **វិតាលោ វិយាតិ វិតាលំ** គាថាឯណាដូចជាដើមត្នោតវិសេស ព្រោះហេតុដូច្នោះ គាថានោះ ឈ្មោះថា **វិតាល** (**វិតាល** + **ណ**-បច្ច័យក្នុងឧបមាតទ្ធិត)។ **វិតាលំ ឯវ វេតាលីយំ** គាថាដែលដូចដើមត្នោតវិសេសមែនពិត ឈ្មោះថា **វេតាលីយ** (**វិតាល** + **ណ្យ**-បច្ច័យ-សកត្ថតទ្ធិត + **ឦ**-អាគម, ឬមកពី **វិតាល** + **ឦយ**-បច្ច័យក្នុងសកត្ថតទ្ធិត)។

គាថានេះក្នុងវិសមបាទ ចែកចេញជា ៤ ឋានគឺ

– **បឋមដ្ឋាន** ត្រូវរៀងមាត្រាឱ្យបាន ៦ មាត្រា។

– **ទុតិយដ្ឋាន** ត្រូវរៀងរគណៈ។

– **តតិយដ្ឋាន** ត្រូវរៀងលហុ ១ សំឡេង។

– **ចតុត្ថដ្ឋាន** ត្រូវរៀងគរុ ១ សំឡេង។

ចំណែកក្នុងសមបាទក៏មាន ៤ ឋានដូចវិសមបាទដែរគឺ

– **បឋមដ្ឋាន** ត្រូវរៀងឱ្យបាន ៨ មាត្រា។

– **ទុតិយដ្ឋាន** ត្រូវរៀងរគណៈ។

– **តតិយដ្ឋាន** ត្រូវរៀងលហុ ១ សំឡេង។

– **ចតុត្ថដ្ឋាន** ត្រូវរៀងគរុ ១ សំឡេង។

ចំណាំ : គាថានេះ ហាមរៀងពួកលហុ ៦ ព្យាង្គជាប់គ្នាក្នុងសមបាទ ។

ពាក្យថា **វិសមចាទ** បានដល់ **បឋមចាទ** និង**តតិយចាទ**។ **សមចាទ** បានដល់ **ទុតិយចាទ** និង**ចតុត្ថចាទ**។

**បឋមចាទ** បើរាប់មាត្រាមានចំនួន ១៤ មាត្រា។ **ទុតិយចាទ** មានចំនួនមាត្រា ១៦ មាត្រា។ **តតិយចាទ** មានមាត្រាចំនួន១៤ មាត្រា។ **ចតុត្ថចាទ** មានចំនួនមាត្រា១៦ មាត្រា។ សរុបមួយគាថារបស់វេតាលីយគាថានេះ មានចំនួន៦០ មាត្រា។

ដូចគាថាលេខ២៩ ដែលព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈសំដែងទុកក្នុងគម្ពីរវុត្តោទយប្បករណ៍ថា

វិសមេ ឆ សិយុំ កលា មុខេ, សមេ ត្វដ្ឋ រលកា តតោបរិ;
វេតាលីយំ តមុច្ចតេ, លហុឆក្កំ ន និរន្តរំ សមេ។[១៧]

ក្នុងខាងដើមវិសមបាទមានចំនួន ៦ មាត្រា, ក្នុងខាងដើមសមបាទមានចំនួន ៨ មាត្រា, ខាងចុងនៃមាត្រា ៦ និងមាត្រា ៨ នោះមានរគណៈ លហុ និងគរុ, ហាមរៀងពួកលហុ ៦ ព្យាង្គជាប់គ្នាក្នុងសមបាទ, គាថាដែលមានលក្ខណៈបរិបូរ (ដូចបានពោលមកនេះ) ត្រូវកវីដ៏ប្រសើរទាំងឡាយហៅថា **វេតាលីយ-គាថា**។

## ៣.២.១៤-ឱបច្ឆន្ទសកគាថា

បទថា **ឱបច្ឆន្ទសក** នេះមានវិគ្គហៈថា **ឆន្ទស្ស សមីបត្តិ ឧបច្ឆន្ទំ** គាថាដែលមានក្នុងទីជិតនៃវេតាលីយគាថានោះ ឈ្មោះថា **ឧបច្ឆន្ទ** (**ឧប-សមីប** + **ឆន្ទ** ក្នុងអត្ថឧបសគ្គបុព្វកាព្យយីភាវ-សមាស)។ **ឧបច្ឆន្ទំ ឯវ ឱបច្ឆន្ទសិកំ** ឧបច្ឆន្ទហ្នឹងឯង ឈ្មោះថា **ឱបច្ឆន្ទសិកំ**, (**ឱបច្ឆន្ទ**-សព្ទ + **ណិក**-បច្ច័យក្នុងអត្ថសកត្ថតទ្ធិត ចុះ**ស**-អាគម)។

ឈ្មោះរបស់គាថានេះ ហៅបានពីរ គឺទីមួយមានឈ្មោះថា **ឱបច្ឆន្ទសក**, និងទីពីរមានឈ្មោះថា **ឱបច្ឆន្ទសិក** ដូចព្រះញាណិន្ទត្ថេរៈ បានសំដែងទុកក្នុងគម្ពីរឆន្ទោសារត្ថមញ្ជូសា ថា **វុត្តោទយេ បន ឱបច្ឆន្ទសកន្តិ ចាហោ** ចំណែកបាឋៈថា **ឱបច្ឆន្ទសកំ** ប្រាកដហើយក្នុងគម្ពីរវុត្តោទ័យ។ **សក្កដឆន្ទោសត្ថេសុ បន ឱបច្ឆន្ទសិកន្តិបិ ឱបច្ឆន្ទសកន្តិបិ ចាហោ** គម្ពីរឆន្ទរបស់សំស្រ្កឹតទាំងឡាយហៅថា **ឱបច្ឆន្ទសិក** ក៏មាន ហៅថា **ឱបច្ឆន្ទសក** ក៏មាន។

គាថានេះក្នុង **វិសមចាទ** ចែកចេញជា ៣ ឋានគឺក្នុង **បឋមដ្ឋាន** ត្រូវកំណត់ ឬរៀងចំនួនមាត្រាឱ្យបាន ៦ មាត្រា។ **ទុតិយដ្ឋាន** ត្រូវរៀងរគណៈ។ **តតិយដ្ឋាន** ត្រូវរៀងយគណៈ។ ចំណែកក្នុង **សមចាទ** ក៏មាន ៣ ឋានដូច **វិសមចាទ** ដែរ។ **បឋមដ្ឋាន** ត្រូវរៀងឱ្យបាន ៨ មាត្រា។ **ទុតិយ-ដ្ឋាន** ត្រូវរៀងរគណៈ។ **តតិយដ្ឋាន** ត្រូវរៀងយគណៈ។

ចំណាំ គាថានេះហាមរៀងពួកលហុ ៦ ព្យាង្គជាប់បន្តគ្នាក្នុងសមបាទ។

**បឋមចាទ** បើរាប់មាត្រាមានចំនួន ១៦ មាត្រា។ **ទុតិយចាទ**មានចំនួនមាត្រា ១៨ មាត្រា។ **តតិយចាទ**មានមាត្រាចំនួន ១៦ មាត្រា។ **ចតុត្ថចាទ**មានចំនួនមាត្រា ១៨ មាត្រា។

សរុបមួយគាថារបស់**ឱបច្ឆន្ទសកគាថា** ឬ **ឱបច្ឆន្ទសិកគាថា** នេះ មានចំនួន ៦០ មាត្រា។ សមដូចមេសូត្រគាថាលេខ ៣០ ដែលអាចារ្យរចនាទុកក្នុងវុត្តោទយប្បករណ៍ថា

---

១៧ វុត្តោទ័យ ប្រែនិងរៀបរៀងដោយ ព្រះញាណបវរវិជ្ជា អែម មិនឃើញមានគាថានេះទេ។

វេតាលីយោបមំ មុខេ តំ, ឱបច្ឆន្ទសកំ រយា យនន្តេ។[១៨]

គាថាដែលមានវេតាលីយគាថាជាឧបមា ក្នុងខាងដើមនៃវិសមបាទ និងសមបាទ, ហើយចុះរគណៈ និងយគណៈក្នុងទីបំផុតតាមលំដាប់, គាថានោះមានឈ្មោះថា **ឱបច្ឆន្ទសកគាថា**។

## ៣.២.១៥-អាបាតលិកាគាថា

បទថា **អាបាតលិកា** នេះមានវិគ្គហៈថា **អាបស្ស តលំ អាបតលំ** ផ្ទៃរបស់ទឹក ឈ្មោះថា **អាបតល** (**អាប** + **តល**-ក្នុងអត្ថឆដ្ឋីតប្បុរិសសមាស)។ **អាបតលំ វិយាតិ អាបតលំ** គាថាឯណាដូចជាផ្ទៃនៃទឹក ព្រោះហេតុដូច្នោះ គាថានោះ ឈ្មោះថា **អាបតល** (**អាបតល** + **ណ**-បច្ច័យក្នុងអត្ថឧបមាតទ្ធិត)។ **អាបតលេ និយុត្តា អាបាតលិកា** គាថាដែលប្រកបដោយលក្ខណៈរបស់វេតាលីយគាថា ដែលមានលក្ខណៈដូចជាផ្ទៃនៃទឹក ឈ្មោះថា **អាបាតលិកា** (**អាបតល** + **ណិក**-បច្ច័យក្នុងអត្ថនិយុត្តតទ្ធិត)។

វិសមបាទ សមបាទ និងឋានជាដើម កំណត់ដោយមាត្រាត្រូវរៀងឱ្យបាន៦ មាត្រាក្នុងខាងដើមវិសមបាទ និងរៀងឱ្យបាន ៨ មាត្រាក្នុងខាងដើមសមបាទ។ អាបាតលិកាគាថានេះ ជាគាថាឋិតក្នុងជំពូករបស់វេតាលីយគាថា ហេតុនេះហើយទើបមានលក្ខណៈរបស់វេតាលីយគាថា។

**វិសមបាទមាន ៣ ឋានគឺ**

- **បឋមដ្ឋាន** រៀងឱ្យបាន ៦ មាត្រា។
- **ទុតិយដ្ឋាន** រៀងភគណៈ។
- **តតិយដ្ឋាន** រៀងមគណៈ។

**សមបាទមាន ៣ ឋានគឺ**

- **បឋមដ្ឋាន** រៀងឱ្យបាន ៨ មាត្រា។
- **ទុតិយដ្ឋាន** រៀងភគណៈ។
- **តតិយដ្ឋាន** រៀងមគណៈ។

ចំណាំ គាថានេះហាមរៀងពួកលហុ ៦ ព្យាង្គជាប់បន្តគ្នាក្នុងសមបាទ។

**បឋមចរណ**មានចំនួន ១៤ មាត្រា។ **ទុតិយចរណ**មានចំនួន ១៦ មាត្រា។ **តតិយចរណ**មានចំនួន ១៤ មាត្រា។ **ចតុត្ថចរណ**មានចំនួន១៦ មាត្រា។ ដូច្នេះអាបាតលិកាគាថានេះ មានចំនួនមាត្រាសរុប ៦០ មាត្រា។ សមដូចគាថាលេខ ៣១ ដែលអាចារ្យសំដែងទុកក្នុងវុត្តោទយប្បករណ៍ថា

---

[១៨] គាថានេះមិនមានក្នុងគម្ពីរវុត្តោទ័យ ដែលប្រែនិងរៀបដោយព្រះញាណបវរវិជ្ជា អែម ទេ ។ ដោយលោកបានប្រាប់ក្នុងគម្ពីររបស់លោកត្រង់ទំព័រលេខ ២៧ ហើយថា មត្តាព្រឹត្តិនេះ មានសេចក្តីពិស្តារតទៅទៀត។

**អាចាតលិកា កចិតាយំ, ភគតាគ្គេ យតិ បុព្វមិវញ្ញំ។**

ភគណៈ និងគរុពីរ[១៩] ថាបើគប្បីមានក្នុងទីបំផុតរបស់គាថា ដែលមានលក្ខណៈដទៃទៀតដូចជាលក្ខណៈរបស់វេតាលីយគាថាខាងដើម កវីដ៏ប្រសើរហៅថា **អាបាតលិកាគាថា**។

### ៣.២.១៦-ឧក្កិណាន្តិកាគាថា

បទថា **ឧក្កិណាន្តិកា** នេះមានបទវិគ្គហៈថា **ឧក្កិណាស្ស អន្តោ ឧក្កិណន្តោ** ទីបំផុតរបស់វេតាលីយគាថាឈ្មោះថា **ឧក្កិណន្ត** (**ឧក្កិណ** + **អន្ត**-ក្នុងឆដ្ឋីតប្បុសសមាស)។ **ឧក្កិណន្តេ កោដ្ឋាសេ និយុត្តា ឧក្កិណាន្តិកា** គាថាដែលប្រកបក្នុងចំណែកដែលជាទីបំផុតរបស់ **វេតាលីយគាថា** ឈ្មោះថា **ឧក្កិណាន្តិកា** (**ឧក្កិណន្ត** + **ណិក**-បច្ច័យក្នុងអត្ថនិយុត្ត-តទ្ធិត)។

គាថានេះ ក៏មានលក្ខណៈរបស់វេតាលីយគាថា ចូលមកដូចគាថាមុនៗដែរ ក្នុងវិសមបាទចែកជា ៤ ឋានគឺ

– **បឋមដ្ឋាន** រៀង ៦ មាត្រា ព្រមទាំងមានជគណៈតាំងនៅក្នុងខាងដើមផង។

– **ទុតិយដ្ឋាន** រៀងរគណៈ។

– **តតិយដ្ឋាន** រៀងលហុ។

– **ចតុត្ថដ្ឋាន** រៀងគរុ។

**សមបាទចែកជា ៤ ឋានគឺ**

– **បឋមដ្ឋាន** រៀង ៨ មាត្រា ព្រមទាំងមានជគណៈតាំងនៅក្នុងខាងដើមផង។

– **ទុតិយដ្ឋាន** រៀងរគណៈ។

– **តតិយដ្ឋាន** រៀងលហុ។

– **ចតុត្ថដ្ឋាន** រៀងគរុ។

**បឋមចរណ**មានចំនួន១៤ មាត្រា។ **ទុតិយចរណ**មានចំនួន១៦ មាត្រា។ **តតិយចរណ**មានចំនួន ១៤ មាត្រា ។ **ចតុត្ថចរណ**មានចំនួន ១៦ មាត្រា។ មួយគាថានេះមានចំនួន ៦០ មាត្រា។

សមដូចគាថាលេខ ៣២ ដែលព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈ ពោលទុកក្នុងវុត្តោទយប្បករណ៍ថា

**យជាជិតោ ឧក្កិណាន្តិកា, ឋិតេត្ថ ចរណេសុ្វាវិសេសុ ជោ។**[២០]

---

១៩ គរុពីរ បានដល់ មគណៈ ជំនួសដោយសញ្ញា ◡ ◡ រាប់បាន ៤ មាត្រា។

២០ គាថានេះមិនមានក្នុងគម្ពីរវុត្តោទ័យ ដែលប្រែនិងរៀបដោយព្រះញាណបវរវិជ្ជា អែម ទេ។

គាថាណា ដែលមានជគណៈនៅខាងដើមបាទទាំងអស់, ចំណែកឯលក្ខណៈដែលនៅសល់ ដូចលក្ខណៈក្នុងវេតាលីយគាថា, គាថានោះ អ្នកស្ទាត់ជំនាញក្នុងឆន្ទទាំងឡាយ ពោលឈ្មោះទុកក្នុង មត្តាវុត្តិនេះថា **ទក្ខិណន្តិកាគាថា**។

## ៣.២.១៧-ឧជិច្ចវុត្តិគាថា

បទថា **ឧជិច្ចវុត្តិ** មានវិគ្គហៈថា **ឧជិចំ លក្ខណំ យស្សា សា ឧជិច្ចា** លក្ខណៈយ៉ាងធំទូលាយច្រើនសន្ធឹកសន្ធាប់របស់វេតាលីយគាថារមែងមានដល់គាថាឯណា គាថានោះឈ្មោះថា **ឧជិច្ចា**, (**ឧជិច្ច** + **លក្ខណ** + **យ** ក្នុងអត្ថទិ្វបទធដ្ឋីតុល្យាធិករណពហុព្វីហិ.)។ **ឧជិច្ចា វុត្តិ ឧជិច្ចវុត្តិ** គាថាដែលមានលក្ខណៈធំទូលាយ ឈ្មោះថា **ឧជិច្ចវុត្តិ** (**ឧជិច្ច** + **វុត្តិ** ក្នុងអត្ថវិសេសនបុព្វបទកម្មធារយសមាស)។

ឧទិច្ចវុត្តិគាថានេះប្រកបដោយលក្ខណៈច្រើន ឬថាមានលក្ខណៈធំទូលាយ ព្រោះយកលក្ខណៈរបស់គាថាមុនៗ មកធ្វើជាលក្ខណៈរបស់ខ្លួនឯង។ វិសមបាទយកលក្ខណៈរបស់ទក្ខិណន្តិកាគាថាមកធ្វើជាលក្ខណៈរបស់ខ្លួន ចំណែកសមបាទយកលក្ខណៈរបស់វេតាលីយគាថាមកធ្វើជាលក្ខណៈ របស់ខ្លួន។ ក្នុងទីនេះមិនបានយកលក្ខណៈទាំងអស់ដែលមានក្នុងដីកាមកទេ ព្រោះខ្លាចធ្វើឱ្យសារណានេះមានទំព័រច្រើនពេក។ ព្រោះហេតុនោះ សូមលើកតែលក្ខណៈសង្ខេបល្មមនឹងអាចរកឧទាហរណ៍មកជាគោលអាងបានតែប៉ុណ្ណោះ។ ឧទិច្ចវុត្តិគាថានេះ ជាគាថាមួយប្រភេទស្ថិតក្នុងក្រុមនៃវេតាលីយគាថា ដូច្នេះលក្ខណៈទាំងអស់របស់វេតាលីយគាថារមែងមានដោយចំណែកច្រើន។

ក្នុង**វិសមចាគ**ចែកជា ៤ ឋានគឺ

- **បឋមដ្ឋាន**ឱ្យរៀងបានចំនួន ៦ មាត្រា ហើយក្នុង ៦ មាត្រានោះមានជគណៈតាំងនៅខាងដើមផង (ជគណៈ + ២ មាត្រា = ៦មាត្រា )។
- **ទុតិយដ្ឋាន**រៀងរគណៈ (◡ ι ◡ )។
- **តតិយដ្ឋាន**រៀងលហុមួយសំឡេង ( ι )។
- **ចតុត្ថដ្ឋាន**រៀងគរុមួយសំឡេង (◡)។

ក្នុង**សមចាគ**ចែកជា ៤ ឋានគឺ

- **បឋមដ្ឋាន**រៀងឱ្យបាន ៨ មាត្រា។
- **ទុតិយដ្ឋាន**រៀងរគណៈ ( ◡ ι ◡ )។
- **តតិយដ្ឋាន**រៀងលហុមួយសំឡេង ( ι )។
- **ចតុត្ថដ្ឋាន**រៀងគរុមួយសំឡេង ( ◡ )។

ចំណាំ : គាថានេះ ហាមរៀងពួកលហុ ៦ ព្យាង្គជាប់គ្នាក្នុងសមបាទ ។

គាថានេះ**បឋមចរណៈ**មានចំនួន ១៤ មាត្រា។ **ទុតិយចរណៈ**មានចំនួន ១៦ មាត្រា។ **តតិយចរណៈ**មានចំនួន ១៤ មាត្រា។ **ចតុត្ថចរណៈ**មានចំនួន ១៦ មាត្រា។ សរុបមួយគាថាមានចំនួន ៦០ មាត្រា។ សមដូចមេសូត្រក្នុងវុត្តោទយប្បករណ៍គាថាលេខ ៣៣ ថា

**ឧទិច្ចវុត្តីតិ វុច្ចតេ, ជោ ចរោ វិសមេសុ សណ្ឋិតោ។**[២១]

ប្រសិនបើ ជគណៈតាំងនៅខាងដើមវិសមបាទនៃគាថាឯណា ហើយមានលក្ខណៈដទៃ ដូចជាលក្ខណៈរបស់វេតាលីយគាថា, គាថានោះ អ្នកស្ទាត់ជំនាញក្នុងឆន្ទទាំងឡាយ ហៅថា **ឧទិច្ចវុត្តិគាថា**។

## ៣.២.១៨-បច្ចវុត្តិគាថា

បទថា **បច្ចវុត្តិ** នេះមានវិគ្គហៈថា **បតិ វិរុទ្ធា វុត្តិ បច្ចវុត្តិ** គាថាដែលបដិបក្ខ (ដោយគាថាមុន) ឈ្មោះថា **បច្ចវុត្តិ** (**បតិ** + **វុត្តិ** ក្នុងអត្ថកម្មធារសមាស)។

គាថានេះ មានលក្ខណៈផ្ទុយគ្នាស្រឡះពីឧទិច្ចវុត្តិគាថាខាងលើនេះ ដោយន័យថា ឧទិច្ចវុត្តិគាថាយកសមបាទរបស់វេតាលីយគាថាមកធ្វើជាសមបាទរបស់ខ្លួនឯង ចំណែកឯបច្ចវុត្តិគាថានេះវិញ យកវិសមបាទរបស់វេតាលីយគាថាមកធ្វើជាវិសមបាទរបស់ខ្លួន។

**វិសមចរណៈ**ចែកជា ៤ ឋានគឺ

- **បឋមដ្ឋាន**រៀងឱ្យបានចំនួន ៦ មាត្រា។
- **ទុតិយដ្ឋាន**រៀងរគណៈ (ᴗ ı ᴗ)។
- **តតិយដ្ឋាន**រៀងលហុមួយសំឡេង ( ı )។
- **ចតុត្ថដ្ឋាន**រៀងគរុមួយសំឡេង ( ᴗ )។

**សមចរណៈ**ចែកជា ៤ ឋានគឺ

- **បឋមដ្ឋាន**រៀងឱ្យបាន ៨ មាត្រា តែក្នុង ៨ មាត្រានោះត្រូវប្រកបដោយគរុ ( ᴗ ) មួយសំឡេងខាងដើមគេ ព្រមទាំងមានជគណៈ ( ı ᴗ ı ) រៀងបន្ទាប់គរុនោះផង និងបន្តពីជគណៈរៀងថែម ២ មាត្រាទៀត ដោយឡែក ២ មាត្រានោះអាចជា **គរុ** ឬ**លហុ**២សំឡេង ក៏ស្មើនឹងចំនួន ២ មាត្រាដូចគ្នា។
- **ទុតិយដ្ឋាន**រៀងរគណៈ ( ᴗ ı ᴗ )។
- **តតិយដ្ឋាន**រៀងលហុមួយសំឡេង ( ı )។
- **ចតុត្ថដ្ឋាន**រៀងគរុមួយសំឡេង ( ᴗ )។

---

២១ គាថានេះមិនមានក្នុងគម្ពីរវុត្តោទ័យ ដែលប្រែនិងរៀបដោយព្រះញាណបវរវិជ្ជា អែម ទេ។

**បឋមចរណ**មានចំនួន ១៤ មាត្រា។ **ទុតិយចរណ**មានចំនួន ១៦ មាត្រា។ **តតិយចរណ**មានចំនួន ១៤ មាត្រា។ **ចតុត្ថចរណ**មានចំនួន ១៦ មាត្រា។ គាថានេះសរុបមាត្រាបាន ៦០ មាត្រា។ សមដូចគាថាលេខ៣៤ ដែលព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈបានរចនាទុកក្នុងវុត្តោទយប្បករណ៍ថា

**បុព្វត្ថ សមេសុ ចេ គជា        បច្ចវុត្តិ ឧជិតាតិ សណ្ឋិតា។**[២២]

ប្រសិនបើ គរុនិងជគណៈរៀងនៅខាងដើមសមបាទទាំងឡាយរបស់គាថា ដែលមានលក្ខណៈដូចវេតាលីយគាថា គាថានោះ អ្នកស្ទាត់ជំនាញក្នុងឆន្ទទាំងឡាយ ហៅថា **បច្ចវុត្តិគាថា**[២៣]។

### ៣.២.១៩-បវត្តកគាថា

បទថា **បវត្តក** នេះមានវិគ្គហៈថា **លក្ខណទ្វយេន បវត្តតីតិ បវត្តកំ** គាថាឯណារមែងប្រព្រឹត្តទៅដោយប្រជុំនៃលក្ខណៈ (របស់ឧទិច្ចវុត្តិគាថា និងបច្ចវុត្តិគាថា) ព្រោះហេតុដូច្នោះ គាថានោះ ឈ្មោះថា **បវត្តក** (**ប**-បុព្វ. + **វតុ**-បវត្តនេ + **ណ្វុ**-បច្ច័យក្នុងអត្ថសុទ្ធសាធនៈ) ។

ឈ្មោះថា **បវត្តកគាថា** ព្រោះប្រកបដោយលក្ខណៈរបស់គាថាទាំងពីរគឺ **ឧទិច្ចវុត្តិគាថា** និង **បច្ចវុត្តិគាថា**។

ក្នុងវិសមបាទនៃបវត្តកគាថានេះ ប្រកបដោយលក្ខណៈរបស់ឧទិច្ចវុត្តិគាថាខាងវិសមបាទមកធ្វើជាលក្ខណៈរបស់ខ្លួន។ ចំណែកឯសមបាទនៃបវត្តកគាថា ប្រកបដោយលក្ខណៈរបស់បច្ចវុត្តិគាថាខាងសមបាទមកធ្វើជាលក្ខណៈរបស់ខ្លួន។

បើពោលឱ្យពិស្តារជាងនេះទៀតថា ក្នុង**វិសមចរណ**ចែកជា ៤ ឋានគឺ

- **បឋមដ្ឋាន**រៀងឱ្យបានចំនួន ៦ មាត្រា ហើយក្នុង ៦ មាត្រានោះមានជគណៈតាំងនៅខាងដើមផង (ជគណៈ + ២ មាត្រា = ៦មាត្រា )។
- **ទុតិយដ្ឋាន**រៀងរគណៈ ( ᴗ ˌ ᴗ )។
- **តតិយដ្ឋាន**រៀងលហុមួយសំឡេង ( ˌ )។
- **ចតុត្ថដ្ឋាន**រៀងគរុមួយសំឡេង (ᴗ)។

ចំណែកឯ**សមចរណ**ចែកជា ៤ ឋានគឺ

- **បឋមដ្ឋាន**រៀងឱ្យបាន ៨ មាត្រា តែក្នុង ៨ មាត្រានោះ ត្រូវប្រកបដោយគរុ ( ᴗ ) មួយសំឡេងខាងដើមគេ ព្រមទាំងមានជគណៈ ( ˌ ᴗ ˌ ) រៀងបន្ទាប់គរុនោះផង និងបន្តពីជគណៈរៀងថែម ២ មាត្រាទៀត ដោយឡែក ២ មាត្រានោះអាចជា គរុ ឬលហុ២សំឡេង ក៏ស្មើនឹងចំនួន ២ មាត្រា។

---

២២ គាថានេះមិនមានក្នុងគម្ពីរវុត្តោទ័យ ដែលប្រែនិងរៀបដោយព្រះញាណបវរវិជ្ជា អែម ទេ។

២៣ គាថានេះនៅមានន័យដទៃទៀត។ ហើយចំនួនមាត្រាក៏អាចមានចំនួនខុសគ្នាផងដែរ។ ក្នុងទីនេះមិនបានលើកយកលក្ខណៈនៃបច្ចវុត្តិគាថានេះមកឱ្យអស់នោះទេ។

– **ទុតិយដ្ឋាន**រៀងគណៈ ( ᴗ ៲ ᴗ )។

– **តតិយដ្ឋាន**រៀងលហុមួយសំឡេង ( ៲ )។

– **ចតុត្ថដ្ឋាន**រៀងគរុមួយសំឡេង ( ᴗ )។

បឋមបាទមានចំនួន ១៤ មាត្រា។ ទុតិយបាទមានចំនួន ១៦ មាត្រា។ តតិយបាទមានចំនួន ១៤ មាត្រា។ ចតុត្ថបាទមានចំនួន ១៦ មាត្រា។ មួយគាថាបួនបាទស្មើ ៦០ មាត្រា។

នឹងពោលដោយសង្ខេបថា *សមចាគនិងវិសមចាគរបស់បច្ចវុត្តិគាថានិងឧជិច្ចវុត្តិគាថា* រមែងតាំងនៅខាងដើមបវត្តកគាថានេះ ព្រោះហេតុនោះ គាថានេះឈ្មោះថា *បវត្តកគាថា*។ សមដូចគាថាលេខ ៣៥ ដែលមានប្រាកដក្នុងវុត្តោទយប្បករណ៍ថា

*សមាសមាត្រាជិនំ សមា-, សំយុតា ភវតិ តំ បវត្តកំ*។[២៤]

*សមចាគ* និង*វិសមចាគ* របស់*បច្ចវុត្តិគាថា* និង*ឧជិច្ចវុត្តិគាថា* ដែលនៅខាងដើម*បវត្តកគាថា*នេះ ថាបើមានបាទដូចគ្នាក្នុងគាថាឯណា គាថានោះ ឈ្មោះថា *បវត្តកគាថា*។

## ៣.២.២០-*អបរន្តិកាគាថា*

បទថា *អបរន្តិកា* នេះមានវិគ្គហៈថា *អបរោ អន្តោ អបរន្តោ* គាថាដទៃជាទីបំផុត ឈ្មោះថា *អបរន្ត* (*អបរ* + *អន្ត* ក្នុងអត្ថវិសេសនុត្តរបទកម្មធារយ.)។ *អបរន្តេ និយុត្តា អបរន្តិកា* គាថាដែលប្រកបក្នុងគាថាដទៃ (ក្នុងសមបាទ) ឈ្មោះថា *អបរន្តិកា* (*អបរន្ត* + *ណិក*-បច្ច័យក្នុងអត្ថនិយុត្តតទ្ធិត) គាថាដែលត្រូវនាំមកប្រកបក្នុងសមបាទរបស់អបរន្តិកាគាថានេះ គឺពួក **បវត្តកគាថា** និង **វេតាលីយគាថា**។

បើតាមវិគ្គហៈខាងលើ អបរន្តិកាគាថានេះ មានលក្ខណៈ ២ តាមមតិរបស់ដីកាចារ្យ សមដូចបទបាលីដែលលោកប្រកបអត្ថទុកក្នុងឆន្ទោសារត្ថមេទិនីថា *អស្សាតិ វេតាលីយស្ស* បទថា *អស្ស* បានដល់បទថា *វេតាលីយស្ស*។ ... *អស្សាតិ បវត្តកស្សាតិបិ ដីកាចរិយា វទន្តិ*[២៥] ដីកាចារ្យទាំងឡាយខ្លះពោលថា បទថា *អស្ស* បានដល់ *បវត្តកស្ស* ក៏មានផងដែរ។ ដូច្នេះបទថា *អស្ស* ក្នុងគាថានោះ បានដល់ *វេតាលីយគាថា* និង*បវត្តកគាថា* នោះឯង។ ព្រោះហេតុនេះ ទើបក្រុមខ្ញុំធ្វើការកំណត់ថា *អបរន្តិកាគាថា*នេះ ប្រកបក្នុងសមបាទរបស់គាថាពីរ ដោយយកលក្ខណៈសមបាទណាមួយមកធ្វើជាលក្ខណៈរបស់អបរន្តិកាគាថាក៏បាន តាមមតិរបស់ដីកាចារ្យថា

– គ្រប់បាទទាំង ៤ ត្រូវយកលក្ខណៈរបស់វេតាលីយគាថាក្នុងសមបាទមកធ្វើជាលក្ខណៈរបស់ខ្លួន

---

២៤ គាថានេះមិនមានក្នុងគម្ពីរវុត្តោទ័យ ដែលប្រែនិងរៀបដោយព្រះញាណបវរវិជ្ជា អែម ទេ។

២៥ បទថា អស្ស បន្ថែមបទថា វេតាលីយស្ស, ដីកាចារ្យទាំងឡាយខ្លះថា បទថា អស្ស បន្ថែមបទថា បវត្តកស្សក៏មាន។

– គ្រប់បាទទាំង ៤ ត្រូវយកលក្ខណៈរបស់បវត្តកគាថាក្នុងសមបាទមកធ្វើជាលក្ខណៈរបស់ខ្លួន។

តាមលក្ខណៈទី ១ ក្នុងមួយគាថា ៤ បាទមានមាត្រាសរុប ៦៤ មាត្រា។ ឯលក្ខណៈទី ២ ក្នុងមួយគាថា ៤ បាទមានមាត្រាសរុប ៦៤ មាត្រាដូចគ្នា។

ចំណាំ បើរចនាតាមលក្ខណៈសមបាទរបស់វេតាលីយគាថា, ក្នុង ៨ មាត្រាហាមរៀងពួកលហុ ៦ ព្យាង្គជាប់បន្តគ្នា។

សរុបសេចក្តីមកអបរន្តិកាគាថានេះ ត្រូវរចនាដោយសមបាទរបស់វេតាលីយគាថា ឬរបស់បវត្តក-គាថាណាមួយក៏បានតាមការពេញចិត្ត។ សមដូចព្រះអាចារ្យសំដែងទុកក្នុងវុត្តោទយប្បករណ៍គាថាលេខ ៣៦ ថា

**អស្ស សា សមកាបរន្តិកា។**[២៦]

គាថាដែលអាចារ្យរចនាដោយសមបាទរបស់វេតាលីយគាថា ឬរបស់បវត្តកគាថា, គាថានោះឈ្មោះថា អបរន្តិកាគាថា។

## ៣.២.២១-ចារុហាសិនីគាថា

បទថា **ចារុហាសិនី** មានវិគ្គហៈថា **ចារុនា លក្ខណេន ហាសេតីតិ ចារុហាសិនី** គាថាឯណារមែងញុំាងជនឱ្យសើច (ឱ្យរីករាយដោយលក្ខណៈល្អស្អាត) ព្រោះហេតុដូច្នោះ គាថានោះឈ្មោះថា **ចារុហាសិនី** (**ចារុ**-សទ្ទូបបទ. + **ហស**-**ហាសេ** + **ណេ**-ការិតបច្ច័យ + **ណ**-បច្ច័យ + **ឥនី**-បច្ច័យក្នុងអត្ថហេតុកត្តុសាធនៈ)។

**ចារុហាសិនីគាថា**នេះ ក៏មានលក្ខណៈរបស់វេតាលីយគាថានិង បវត្តកគាថាចូលមកធ្វើជាលក្ខណៈរបស់ខ្លួនដូចគាថាមុនដែរ អ្វីដែលប្លែកពីគាថាមុននោះគឺ គាថានេះបាននាំយកលក្ខណៈប៉ែកខាងវិសមបាទនៃគាថាទាំងពីរណាមួយមកប្រព័ន្ធគ្រប់បាទទាំង ៤ តែប៉ុណ្ណោះ។

តាមមតិរបស់ដីកាចារ្យដែលបានសំដែងក្នុងគម្ពីរដីកាឈ្មោះ ឆន្ទោសារត្ថមេទិនី ថា **ចារុហាសិនីគាថា** ត្រូវប្រព័ន្ធដោយលក្ខណៈវិសមបាទរបស់គាថាណាមួយ បណ្តាគាថាពីរគឺ **វេតាលីយគាថា** និង **បវត្តកគាថា**។

ដូច្នេះអាចកំណត់បានថា គាថានេះប្រព័ន្ធដោយលក្ខណៈ ២ គឺ

– គ្រប់បាទទាំង ៤ ត្រូវយកលក្ខណៈរបស់វេតាលីយគាថាក្នុងវិសមបាទមកធ្វើជាលក្ខណៈរបស់ខ្លួន។

– គ្រប់បាទទាំង ៤ ត្រូវយកលក្ខណៈរបស់បវត្តកគាថា ក្នុងវិសមបាទមកធ្វើជាលក្ខណៈរបស់ខ្លួន។

ដោយហេតុតែគាថានេះ ប្រកបដោយលក្ខណៈរបស់គាថាមុនៗ លក្ខណៈ, ឋាន, និងបាទជាដើម មានទម្រង់បែបបទដូចគ្នាដោយច្រើន។ ក្នុងទីនេះមិនលើកមកពោលដល់ឋានទៀតទេ ព្រោះមាននិយាយមកក្នុងខាងដើមហើយ។

---

២៦ គាថានេះមិនមានក្នុងគម្ពីរវុត្តោទ័យ ដែលប្រែនិងរៀបដោយព្រះញាណបវរវិជ្ជា អែម ទេ។

គាថានេះ បើយកលក្ខណៈរបស់វេតាលីយគាថាខាងវិសមបាទមកប្រព័ន្ធ បាទនីមួយ ៗ មានចំនួន ១៤ មាត្រា មួយគាថាបួនបាទត្រូវជា ៥៦ មាត្រាគត់។ តែបើយកលក្ខណៈរបស់បវត្តកគាថាខាងវិសមបាទមកប្រព័ន្ធ បាទនីមួយៗមានចំនួន ១៤ មាត្រា មួយគាថាបួនបាទត្រូវជា ៥៦ មាត្រាដូចគ្នា។

សរុបមកគាថាដែលប្រព័ន្ធដោយវិសមបាទរបស់*វេតាលីយគាថា* ឬ*បវត្តកគាថា* ហៅថា ***ចារុហាសិនីគាថា***។ សមដូចបដ្ឋលេខ ៣៧ ដែលព្រះអាចារ្យបានសំដែងទុកក្នុងវុត្តោទយប្បករណ៍ថា

**តឧញ្ញជា ចារុហាសិនី។**[៣៧]

គាថាដែលរចនាដោយវិសមបាទដទៃ ចាកសមបាទរបស់វេតាលីយគាថា (ឬរបស់បវត្តក-គាថា) គាថានោះ ឈ្មោះថា **ចារុហាសិនីគាថា**។

## សរុបក្រុមវេតាលីយគាថា ៩ ប្រភេទ

- ***វេតាលីយគាថា*** វិសមបាទរៀង៦មាត្រា រគណៈ លហុ និងគរុចុងបាទ។ សមបាទរៀង ៨ មាត្រា រគណៈ លហុ និងគរុចុងបាទ។
- ***ឱបច្ឆន្ទសកគាថា*** វិសមបាទរៀង ៦ មាត្រា រគណៈ និងយគណៈចុងបាទ។ សមបាទរៀង ៨ មាត្រា រគណៈ និងយគណៈចុងបាទ។
- ***អាបាតលិកាគាថា*** វិសមបាទរៀង ៦ មាត្រា ភគណៈ និងមគណៈចុងបាទ។ សមបាទរៀង ៨ មាត្រា ភគណៈ និងមគណៈចុងបាទ។
- **ទក្ខិណន្តិកាគាថា** វិសមបាទរៀងជគណៈខាងដើមក្នុង ៦ មាត្រានោះ បន្ទាប់មករៀង រគណៈ លហុ និងគរុចុងបាទ។ សមបាទរៀងជគណៈខាងដើមក្នុង៨មាត្រានោះបន្ទាប់មករៀង រគណៈ លហុ និងគរុចុងបាទ។
- **ឧទិច្ចវុត្តិគាថា** វិសមបាទរៀងជគណៈខាងដើមក្នុង ៦ មាត្រានោះ បន្ទាប់មករៀង រគណៈ លហុ និង គរុចុងបាទ។ សមបាទរៀង ៨ មាត្រា រគណៈ លហុ និងគរុចុងបាទ។
- **បច្ចវុត្តិគាថា** វិសមបាទរៀង ៦ មាត្រា រគណៈ លហុ និងគរុចុងបាទ។ សមបាទរៀងគរុជគណៈខាងដើមក្នុង ៨ មាត្រានោះ បន្ទាប់មករៀងរគណៈ លហុ និងគរុចុងបាទ។
- **បវត្តកគាថា** វិសមបាទយកវិសមបាទរបស់ឧទិច្ចវុត្តិគាថា។ សមបាទយកសមបាទរបស់បច្ចវុត្តិគាថា។
- **អបរន្តិកាគាថា** គ្រប់បាទទាំងបួន ត្រូវយកលក្ខណៈសមបាទរបស់វេតាលីយ ឬយកលក្ខណៈសមបាទរបស់បវត្តកគាថា។

---

៣៧ គាថានេះមិនមានក្នុងគម្ពីរវុត្តោទ័យ ដែលប្រែនិងរៀបដោយព្រះញាណបវរវិជ្ជា អែម ទេ។

– **ចារុហាសិនីគាថា** គ្រប់បាទទាំងបួន ត្រូវយកលក្ខណៈវិសមបាទរបស់វេតាលីយ ឬយកលក្ខណៈវិសមបាទរបស់បវត្តកគាថា។

ក្រុមនៃវេតាលីយគាថាចប់តែប៉ុណ្ណេះ។

## ៣.២.២២-អចលធិតិគាថា

បទថា **អចលធិតិ** មានវិគ្គហៈថា **អចលា ធិតិ យស្សា សា អចលធិតិ** ការព្យាយាមមិនកម្រើកញ័ររមែងមានដល់គាថាឯណា គាថានោះ ឈ្មោះថា **អចលធិតិ** (**អចល** + **ធិតិ** + **យ** ក្នុងអត្ថទិបទចតុត្ថីតុល្យាធិករណពហុព្វីហិ) ពាក្យថា ព្យាយាមក្នុងគាថានេះ បានដល់ការព្យាយាមសូធ្យយ៉ាងមាំមួន នឹងត្រឹមត្រូវ ឈ្មោះថា ការព្យាយាមមិនកម្រើកញ័រ។

ដែលមានឈ្មោះថា **អចលធិតិ** ព្រោះវេលាបន្លឺសំឡេង ឬសូធ្យ ត្រូវព្យាយាមសូធ្យកុំឱ្យញាប់ញ័រ ឬកុំឱ្យភ្លាត់សំឡេងទៅជាគរុ។ ហេតុអ្វីបានជាមិនឱ្យភ្លាត់សំឡេងទៅជាគរុ? ព្រោះគាថានេះ ប្រាសចាកអក្សរដែលជាគរុនោះឯង។ ព្រោះហេតុនោះ ទើបគាថានេះ បានឈ្មោះថា **អចលធិតិគាថា**។

គាថានេះគ្រប់បាទសុទ្ធតែជាលហុ។ បាទនីមួយៗ មានចំនួន១៦ មាត្រាដូចគ្នាទាំងអស់ ។ មួយគាថាមានចំនួន ៦៤ មាត្រា។ សមដូចគាថាលេខ ៣៨ ដែលព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈសំដែងទុកក្នុងវុត្តោទយប្បករណ៍ថា

**ទ្វិកវិហតវសុលហុ អចលធិតិរិហ**។[២៨]

លហុ ៨ ព្យាង្គដែលគុណដោយចំនួន ២ ថាបើមានគ្រប់បាទទាំង ៤ ដែលមានចំនួន ១៦ មាត្រារបស់គាថាឯណា, គាថានោះ ឈ្មោះថា អចលធិតិគាថា រមែងមានក្នុងគម្ពីរឆន្ទនេះ។

## ៣.២.២៣-មត្តាសមកគាថា

បទថា **មត្តាសមក** មានវិគ្គហៈថា **មត្តា សមា អស្មិន្តិ មត្តាសមកំ** មាត្រាស្មើគ្នាមានក្នុងគាថានោះ ព្រោះហេតុនោះ គាថានោះ ឈ្មោះថា **មត្តាសមក** (**មត្តា** + **សមា** + **ក**-បច្ច័យ ក្នុងអត្ថទិបទសត្តមីតុល្យាធិករណពហុព្វីហិ.)។

ក្នុងគាថានេះបាទនីមួយៗមាន ១៦ មាត្រាដូចគ្នា។ មួយគាថាមានចំនួន ៦៤ មាត្រា។ បាទនីមួយៗនៃគាថានេះចែកជា ២ ឋានគឺ

– **បឋមដ្ឋាន** រៀងឱ្យបាន ៨ មាត្រា។

– **ទុតិយដ្ឋាន** រៀងលហុនៅមាត្រាទី ៩ និងរៀងគរុ១សំឡេងនៅខាងចុងបាទ។

---

២៨ គាថានេះមិនមានក្នុងគម្ពីរវុត្តោទ័យ ដែលប្រែនិងរៀបដោយព្រះញាណបវរវិជ្ជា អែម ទេ។

ចំណុចសំខាន់ដែលលោកពោលក្នុងគាថានេះគឺ គ្រប់ ៗ បាទត្រង់មាត្រាទី ៩ ត្រូវរៀងលហុ ១ សំឡេងព្រមទាំងមានគរុនៅទីបំផុតបាទផង។ សមដូចគាថាលេខ ៣៩ ក្នុងវុត្តោទយប្បករណ៍ថា

**មត្តាសមកំ នវមោ លូគ្គ។**

មាត្រាទី ៩ ជាលហុថាបើមានគ្រប់បាទដែលមានចំនួន ១៦ មាត្រារបស់មត្តាសមកគាថា ថែមទាំងមានគរុក្នុងទីបំផុតនៃបាទផង, គាថានោះ ឈ្មោះថា **មត្តាសមកគាថា។**

## ៣.២.២៤-វិសិលោកគាថា

បទថា **វិសិលោក** នេះមានវិគ្គហៈថា **វិសិដ្ឋោ សិលោកោ អស្សាតិ វិសិលោកោ** គាថាដ៏វិសេសរមែងមានដល់គាថាឯណា ព្រោះហេតុនោះ គាថានោះ ឈ្មោះថា **វិសិលោក**, (**វិ**-វិសិដ្ឋ + **សិលោក**-ទ្វិបទចតុត្ថីតុល្យាធិករណពហុព្វីហិ.) ពាក្យថា គាថាវិសេសនេះ បានដល់ វិសេសដោយការសរសើរ។

បើនឹងពោលដោយសង្ខេបតាមមេសូត្រថា ជគណៈឬនគណៈរមែងមានខាងចុងចាកមាត្រាចំនួន ៤ ដំបូងក្នុងគ្រប់ៗបាទដែលមានមាត្រា ១៦ ថែមទាំងមានគរុខាងចុងបាទផង។

(សួរថា) តើ ៤ មាត្រាដំបូងរៀងគណៈអ្វី ? ដើម្បីងាយស្រួលដល់ការសិក្សា ទើបក្នុងវុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី ដែលរចនាដោយព្រះវជិរបញ្ញត្ថេរៈ លោកបានយកបាទនីមួយ ៗ ចែកចេញជា ៤ ឋានដូចគ្នាគឺ

- **បឋមដ្ឋាន** អាចរៀងគណៈណាមួយក៏បានក្នុងបណ្តាគណៈទាំង ៤ គឺ មគណៈ សគណៈ ភគណៈ និងនគណៈ។
- **ទុតិយដ្ឋាន** អាចរៀងគណៈណាមួយក្នុងបណ្តាគណៈទាំង ២ នេះគឺ ជគណៈ និងនគណៈ។
- **តតិយដ្ឋាន** អាចរៀងគណៈបាន ២ គឺ មគណៈ ឬភគណៈ។
- **ចតុត្ថដ្ឋាន** អាចរៀងគណៈបាន ២ គឺ មគណៈ ឬសគណៈ។

គ្រប់បាទទាំងអស់មានចំនួន ១៦ មាត្រា។ មួយគាថា ៦៤ មាត្រា។ សមដូចគាថាលេខ ៤០ ដែលព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈសំដែងក្នុងវុត្តោទយប្បករណ៍ថា

**ជោ ទ្វាចវណ្ណា វិសិលោកោ។**

ជគណៈឬនគណៈរមែងមានខាងចុងចាកមាត្រាចំនួន ៤ ដំបូងក្នុងគ្រប់ៗបាទ ដែលមានមាត្រា ១៦ ថែមទាំងមានគរុខាងចុងបាទផង គាថានោះឈ្មោះថា **វិសិលោកគាថា។**

## ៣.២.២៥-វានវាសិកាគាថា

បទថា **វានវាសិកា** មានវិគ្គហៈថា **វានវេសុ និយុត្តា វានវាសិកា** គាថាដែលប្រកបហើយក្នុងគណៈមិនពិតប្រាកដ ឈ្មោះថា **វានវាសិកា** (**វានវ** + **ស**-អាគម + **ណិក**-បច្ច័យក្នុងអត្ថ-

និយុត្តតទ្ធិត)។

តាមមេសូត្រថា ប្រសិនបើជគណៈ ឬនគណៈរមែងមានខាងចុងចាក ៨ មាត្រាក្នុងបាទទាំងឡាយដែលមានចំនួន ១៦ មាត្រា ថែមទាំងមានគរុនៅខាងចុងបាទផង គាថានោះហៅថា **វានវាសិកាគាថា**។

សេចក្តីអធិប្បាយថា គាថានេះបាទនីមួយៗចែកចេញជា ៤ ឋានគឺ

- **បឋមដ្ឋាន** អាចរៀងគណៈណាមួយក៏បាន ក្នុងចំណោមគណៈទាំង៤ នេះគឺ មគណៈ សគណៈ ភគណៈ និងនគណៈ។
- **ទុតិយដ្ឋាន** អាចរៀងគណៈបាន ៣ គឺ មគណៈ ឬសគណៈ ឬភគណៈ។
- **តតិយដ្ឋាន** អាចរៀងគណៈបាន ២ គឺ ជគណៈ ឬនគណៈ។
- **ចតុត្ថដ្ឋាន** អាចរៀងគណៈបាន ២ គឺ មគណៈ ឬសគណៈ។

បាទនីមួយៗមានចំនួន ១៦ មាត្រាដូចគ្នាទាំងអស់។ មួយគាថាស្មើ ៦៤ មាត្រា។ ដូចគាថាលេខ ៤១ ដែលអាចារ្យប្រព័ន្ធទុកក្នុងវុត្តោទយប្បករណ៍ថា

**តទ្វយតោ វានវាសិកាខ្យា។**

ប្រសិនបើជគណៈ ឬនគណៈរមែងមានខាងចុងចាក ៨ មាត្រាក្នុងបាទទាំងឡាយដែលមានចំនួន ១៦ មាត្រា ថែមទាំងមានគរុនៅខាងចុងបាទផង គាថានោះហៅថា **វានវាសិកាគាថា**។

### ៣.២.២៦-ចិត្រាគាថា

បទថា **ចិត្រា** នេះមានវិគ្គហៈថា **ចិន្តេតីតិ ចិត្រា** គាថាឯណារមែងវិចិត្រ ព្រោះហេតុនោះ គាថានោះ ឈ្មោះថា **ចិត្រា** (ពាក្យនេះមិនសូវប្រើជានិប្ផន្នបាដិបទិកសព្ទទេ)។

គាថានេះ មានភាពវិចិត្រជាងគាថាមុនដោយលក្ខណៈ ឬថាមានលក្ខណៈវិចិត្រជាងគាថាមុនដោយន័យថា ក្នុងមាត្រាទី ៥ មាត្រាទី ៨ និងមាត្រាទី ៩ ឱ្យរៀងលហុ និងរៀងគរុខាងចុងបាទផង។

បើនឹងពោលដោយពិស្តារ គ្រប់បាទនៃគាថានេះចែកជា ៤ ឋានគឺ

- **បឋមដ្ឋាន** វៀរតែជគណៈចេញ នៅសល់រៀងមួយណាក៏បាន បណ្តាគណៈទាំងបួននោះ។
- **ទុតិយដ្ឋាន** រៀងជគណៈ ឬនគណៈ។
- **តតិយដ្ឋាន** រៀងសគណៈ ឬនគណៈ។
- **ចតុត្ថដ្ឋាន** រៀងមគណៈ ឬសគណៈ។

សរុបមកថា ប្រសិនបើគ្រប់បាទដែលមានមាត្រា ១៦ នោះ រៀងលហុនៅមាត្រាទី ៥ ទី ៨ ទី ៩ ថែមទាំងរៀងគរុ ១ សំឡេងខាងចុងបាទផង គាថានោះឈ្មោះថា ចិត្រាគាថា។ ដូចគាថាដែលមានប្រាកដក្នុងវុត្តោទយប្បករណ៍ថា

**បញ្ចដ្ឋនវសុ យទិ លោ ចិត្រា។**

ប្រសិនបើ លហុមានក្នុងមាត្រា ៥ និងមាត្រា ៨ និងមាត្រា ៩ គ្រប់បាទដែលមានមាត្រា ១៦ ថែមទាំងមានគរុក្នុងទីបំផុតនៃបាទផង គាថានោះឈ្មោះថា **ចិត្រាគាថា។**

## ៣.២.២៧-ឧបចិត្រាគាថា

បទថា **ឧបចិត្រា** នេះមានវិគ្គហៈថា **ចិត្រាយ សមីបេ បវត្តតីតិ ឧបចិត្រា** គាថាឯណារមែងប្រព្រឹត្តទៅក្នុងទីជិតនៃចិត្រាគាថា ព្រោះហេតុនោះ គាថានោះ ឈ្មោះថា **ឧបចិត្រាគាថា** ( ឧប + ចិត្រ-ក្នុងឆដ្ឋីអព្យយីភាវសមាស)។

បើតាមវិគ្គហៈខាងលើ ឧបចិត្រាគាថានេះ ជាគាថាមានភាពស្រដៀងគ្នានឹងចិត្រាគាថា។ អ្វីដែលខុសគ្នានោះគឺ ចិត្រាគាថាឱ្យរៀងលហុនៅមាត្រាទី ៥, ៨, ៩ និងគរុចុងបាទ តែឧបចិត្រាគាថានេះ ត្រូវរៀងលហុនៅមាត្រាទី៩ និងរៀងគរុនៅមាត្រាទី ១០ និងរៀងយគណៈនៅមាត្រាបន្ទាប់ពីមាត្រាទី ១០ នោះ។

រាល់ៗបាទរបស់គាថានេះ លោកបានចែកជា ២ ឋានគឺ

– **បឋមដ្ឋាន** រៀងឱ្យបាន ៨ មាត្រា។

– **ទុតិយដ្ឋាន** រៀងគរុ និងលហុ និងយគណៈតាមលំដាប់។

ឯលក្ខណៈដទៃទៀត គប្បីមើលលក្ខណៈរបស់ក្រុមមត្តាសមកគាថា សមដូចគាថាដែលអាចារ្យពោលទុកក្នុងគម្ពីរឆន្ទោសារត្ថទិនីថា

**សោតូនំ សុខពោធាយ, មត្តាសមកជាតិសុ;**

**គណស្ស លក្ខណេនេវ, វិកប្បោ ច កតោ មយា។**

ការកំណត់គណៈ(ក្នុងគាថានេះ) ខ្ញុំរចនាហើយដោយលក្ខណៈក្នុងក្រុមមត្តាសមកគាថា ដើម្បីឱ្យងាយស្រួលដល់អ្នកសិក្សាទាំងឡាយ។

ពាក្យថា លក្ខណៈ ដទៃទៀត គប្បីជ្រាបថា លក្ខណៈផ្សេងដែលចិត្រាគាថាមិនបានពោល។ គាថានេះបើនឹងរាប់មាត្រាក្នុងរាល់ៗបាទមានចំនួន ១៦ មាត្រា។ មួយគាថាបួនបាទមានចំនួន ៦៤ មាត្រា។

សរុបមកថា គាថាដែលបន្ទាប់ពីរៀងបាន ៨ មាត្រាហើយ មានគរុ និងលហុ និងយគណៈ គាថានោះឈ្មោះថា ឧបចិត្រាគាថា សមដូចគាថាលេខ ៤៣ ដែលព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈសំដែងទុកក្នុងវុត្តោទយប្បករណ៍ថា

**គល្យាដ្ឋហិ ចេសា វុបចិត្រា។**

គរុនិងលហុនិងយគណៈទាំងឡាយ ថាបើមានខាងចុងមាត្រាទាំងឡាយ ៨ គ្រប់បាទ ទាំងបួនដែលមានមាត្រា ១៦ នោះ និងមានគរុក្នុងទីបំផុតបាទផង គាថានោះមានឈ្មោះថា ឧបចិត្រាគាថា។

## ៣.២.២៨-ទោធកុលកគាថា

បទថា **ទោធកុលក** នេះមានវិគ្គហៈថា **ទោធេហិ អាកុលំ យស្ស តំ ទោធកុលកំ** ការលោយប្រទ្បំដោយបាទទាំងឡាយរមែងមានដល់គាថាឯណា គាថានោះ ឈ្មោះថា **ទោធកុលក**

(**ចាគ** + **អាកុល** + **យ**-ក្នុងទ្វិបទធម្មីភិន្នាធិករណពហុព្វីហិ.) ។ ការលាយច្រឡំបាទនេះ សំដៅយកការប្រកបផ្សំដោយបាទរបស់មត្តាសមកគាថាជាដើមទាំង ៥ ប្រភេទចូលគ្នា។

គាថានេះ រចនាដោយបាទរបស់គាថាទាំង ៥ មានមត្តាសមកគាថាជាដើម ដូចឧទាហរណ៍ថា បឋមបាទ យកបាទរបស់មត្តាសមកគាថាមួយមករចនា ឬថានាំយកលក្ខណៈនៃមត្តាសមកគាថាមករចនា។ ទុតិយបាទ នាំយកលក្ខណៈរបស់វិសិលោកគាថាមកតែង។ **តតិយបាទ** នាំយកលក្ខណៈរបស់**វានវាសិកាគាថា**មកតែង។ **ចតុត្ថបាទ** នាំយកលក្ខណៈរបស់វិសិលោកគាថាមកតែង។ គ្រប់បួនបាទរាប់បានថាជា **បាទាកុលកគាថា** ព្រោះគ្រប់បាទ ត្រូវតែងដោយនាំយកលក្ខណៈរបស់គាថា ៥ ខាងដើមណាមួយមកតែង។

ពោលដោយសង្ខេបថា គាថាដែលប្រកបដោយលក្ខណៈពិសេសរបស់គាថាមុន ៗ ដែលរចនាដោយបាទរបស់មត្តាសមកគាថាជាដើម ដែលមានចំនួននៃគាថាមិនទៀងទាត់ ឈ្មោះថា បាទាកុលកគាថា សមដូចគាថាលេខ ៤៤ ត្រូវអាចារ្យសំដែងទុកក្នុងវុត្តោទយប្បករណ៍ថា

**យមតីតលក្ខណវិសេសយុតំ, មត្តាសមាទិបាទាភិហិតំ;**
**អនិយតវុត្តបរិមាណសហិតំ, បថិតំ ជនេសុ បាទាកុលកំ។**

គាថាណាដែលប្រកបដោយលក្ខណៈដ៏វិសេសរបស់គាថាចំនួន ៥ ដែលលោកពោលហើយក្នុងខាងដើម ដែលលោករចនាដោយបាទនៃគាថាមានមត្តាសមកគាថាជាដើម ដែលប្រកបដោយបរិមាណៈរបស់គាថាដែលមិនប្រាកដ, គាថានោះប្រាកដហើយក្នុងជនអ្នកដឹងនូវឆន្ទទាំងឡាយថា **បាទាកុលកគាថា**។

ប្លង់សម្រាប់តែង ឬផែនទីសម្រាប់តែងគាថានេះ មិនអាចដើម្បីនឹងកំណត់បានទេ ថាបឋមបាទត្រូវតែរៀងយ៉ាងនេះ ទុតិយបាទត្រូវតែរៀងយ៉ាងនោះបានឡើយ ព្រោះលោកបានពោលហើយថា **អនិយតវុត្តបរិមាណសហិតំ** (គាថានេះ) រចនាដោយបាទនៃគាថាមានមត្តាសមកគាថាជាដើម ដែលប្រកបដោយចំនួននៃគាថាមិនទៀងទាត់។ ក្នុងដីកាឈ្មោះឆន្ទោសារត្ថមេទិនី បានចែកន័យជាច្រើនសន្ធឹកសន្ធាប់ ក្នុងទីនេះមិនបានលើកយកន័យទាំងអស់នោះមកទេ។

## សរុបក្រុមមត្តាសមកគាថា ៧ ប្រភេទ

- **អចលធិតិគាថា** រៀងលហុឱ្យបាន ១៦។
- **មត្តាសមកគាថា** មាត្រាទី ៩ ជាលហុ និងគរុចុងបាទ។
- **វិសិលោកគាថា** រៀងឱ្យបាន ៤ មាត្រា បន្ទាប់មករៀងជគណៈ ឬនគណៈ និង ៦ មាត្រា និងគរុចុងបាទ។
- **វានវាសិកាគាថា** រៀងឱ្យបាន ៨ មាត្រា បន្ទាប់មករៀងជគណៈ ឬនគណៈ និងគរុចុងបាទ។
- **ចិត្រាគាថា** មាត្រាទី ៥, ៨, ៩, ជាលហុ និងគរុចុងបាទ។

– **ឧបចិត្រាគាថា** រៀងឱ្យបាន ៨ មាត្រា បន្ទាប់មករៀងគរុ ១ លហុ ១ និងយគណៈ ចុងបាទ។
– **ចាតាកុលកគាថា** យកលក្ខណៈរបស់មត្តាសមកគាថាជាដើម រៀរតែអចលធិតិគាថា ចេញ។

ក្រុមមត្តាសមកគាថាចប់តែប៉ុណ្ណេះ។

## ៣.២.២៩-គាទិសង្ខ្យានយៈ (វិធីរកចំនួនគរុជាដើម)

វិធា វណ្ណេហិ មត្តា គា, វិធា វណ្ណា គរូហិ តុ;
វិធា លហូនិ គរវោ, ឥលេ បជ្ជាទិតោ មតា។

គរុទាំងឡាយក្នុងបុព្វទ្ធៈនិងអបរទ្ធៈនៃគាថាមានអរិយាគាថាជាដើម ត្រូវលុបដោយក្រុមព្យាង្គចេញអំពីមាត្រាដែលជាលហុ, ក្រុមព្យាង្គទាំងឡាយ ត្រូវលុបដោយក្រុមព្យាង្គ ដែលជាគរុទាំងឡាយចេញអំពីមាត្រាដែលជាលហុ, លហុទាំងឡាយត្រូវលុបដោយគរុទាំងឡាយចេញអំពីព្យាង្គ។

គាទិសង្ខ្យានយៈនេះ ជាវិធីសំដែងនូវចំនួនគរុជាដើម ពាក្យថា ជាដើម នេះបានដល់សព្វពីរគឺ វណ្ណៈ អក្ខរៈ ឬព្យាង្គ និងលហុ។ គាថានេះសំដែងអំពីវិធីរកចំនួនគរុ លហុ និង អក្ខរៈ។ បើតាមគាថានេះបឋមបាទថា **វិធា វណ្ណេហិ មត្តា គា** ដើម្បីរកចំនួនគរុ ត្រូវតាំងចំនួនមាត្រាហើយលុបដោយព្យាង្គ។ ទុតិយបាទថា **វិធា វណ្ណា គរូហិ តុ** បើរកចំនួនព្យាង្គ ត្រូវតាំងចំនួនមាត្រាហើយលុបដោយគរុ។ តតិយបាទថា **វិធា លហូនិ គរវោ** ដើម្បីរកចំនួនលហុ ត្រូវតាំងចំនួនព្យាង្គហើយលុបដោយគរុ។

តាមន័យក្នុងគាថានេះ ធ្វើឱ្យឃើញច្បាស់ថា គាទិសង្ខ្យានយៈមានលក្ខណៈ ៣ គឺ
– **គរុសង្ខ្យានយៈ** វិធីរកចំនួនគរុត្រូវតាំងចំនួនមាត្រាហើយលុបដោយចំនួនអក្ខរៈ។
– **វណ្ណសង្ខ្យានយៈ** វិធីរកចំនួនអក្ខរៈត្រូវតាំងចំនួនមាត្រាហើយលុបដោយចំនួនគរុ។
– **លហុសង្ខ្យានយៈ** វិធីរកចំនួនលហុត្រូវតាំងចំនួនអក្ខរៈហើយលុបដោយចំនួនគរុ។

# ជំពូកទី៤

# ប្លង់រចនាមត្តាគាថា និងអាគតដ្ឋាន

## ៤.១-អរិយាគាថា ឬអរិយាសាមញ្ញគាថា

### ៤.១.១-ប្លង់រចនាអរិយាគាថា

| បុព្វឌ្ឍៈ (៣០ មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| បឋមបាទ (១២មាត្រា) | | | ទុតិយបាទ (១៨មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ជ/ន. | ភ/ស/ម/ន. | គ. |

| អបរឌ្ឍៈ (២៧ មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| តតិយបាទ (១២ មាត្រា) | | | ចតុត្ថបាទ (១៥ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ល[29] | ភ/ស/ម/ន. | គ. |

### ៤.១.២-អាគតដ្ឋាន

សោឡសហារា នេត្តី, បញ្ច នយា សាសនស្ស បរិយេដ្ឋិ;
អដ្ឋារសមូលបទា, មហាកច្ចានេននិទ្ទិដ្ឋា។[៣០]

### ៤.១.៣-អនុវត្ត

ពុទ្ធោ ធម្មោ សង្ឃោ, យោគោ ចាគោ វិនាយកោ នាថោ;
មានោ មក្ខោ កាមោ, ថម្ភោ យក្ខោ នរោ ចោរោ។

---

២៩ លហុនេះ បើចាត់ជាគណៈ ឋិតក្នុងឧបចារគណៈ។

៣០ សុត្តន្តបិដកេ ខុទ្ទកនិកាយេ ជម្ពុវនវាសិនា មហាកច្ចាយនត្ថេរេន កតំ នេត្តិប្បករណំ, កម្ពុជរដ្ឋេ បញ្ញាសាស្ត្រសាកលវិទ្យាលយស្ស ពុទ្ធិកបណ្ឌិតសភាយ បកាសិតំ, អនុស្សរណីយំ ពុទ្ធសកេ ២៥៥៣ ទំព័រ ១ ។

## ៤.២-បថ្យាអរិយាគាថា

### ៤.២.១-ប្លង់រចនាបថ្យាអរិយាគាថា

| បុព្វទ្ធៈ (៣០) | | | | | | | |
|---|---|---|---|---|---|---|---|
| បឋមបាទ (១២ មាត្រា) | | | ទុតិយបាទ (១៨ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ក/ស/ម/ន. | ក/ជ/ស/ម/ន. | ក/ស/ម/ន. | ក/ជ/ស/ម/ន. | ក/ស/ម/ន. | ជ/ន. | ក/ស/ម/ន. | គ. |

| អបរទ្ធៈ (២៧មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| តតិយបាទ (១២ មាត្រា) | | | ចតុត្ថបាទ (១៥ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ក/ស/ម/ន. | ក/ជ/ស/ម/ន. | ក/ស/ម/ន. | ក/ជ/ស/ម/ន. | ក/ស/ម/ន. | ល. | ក/ស/ម/ន. | គ. |

### ៤.២.២-អាគតដ្ឋាន

ករុណាសីតលហទយំ,
បញ្ញាបជ្ជោត,វិហតមោហតមំ;
សនរាមរលោកគរុំ,
វន្ទេ សុគតំ គតិវិមុត្តំ។[៣១]

### ៤.២.៣-អនុវត្ត

សុគតោ ធីចោ វណ្ណោ,
ទេវិន្ទោ ព្រាហ្មណោ សសោ កាកោ;
គោណោ អជ្ជោ វំសោ,
កប្បោ កាយោ សុណោ វជិកោ ។

៣១ ទីឃនិកាយដ្ឋកថា សីលក្ខន្ធវគ្គ សុមង្គលវិលាសិនី បឋមភាគ, រចនាដោយ ព្រះពុទ្ធឃោសាចារ្យ, ការផ្សាយរបស់ពុទ្ធិក-បណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ព.ស. ២៥៥៥, ទំព័រ ១។

# ៤.៣-វិបុលាអរិយាគាថា

## ៤.៣.១-ប្លង់រចនាវិបុលាអរិយាគាថា

| បុព្វទ្ធៈ (៣០ មាត្រា) | | | | | | | | |
|---|---|---|---|---|---|---|---|---|
| បឋមបាទ (១៤ ឬ១៣ មាត្រា) | | | | | ទុតិយបាទ (១៦ ឬ១៧ មាត្រា) | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ∪ıı | ∪ıı | ∪ıı | ∪ | ıı | ∪ıı | ı∪ı | ∪ıı | ∪ |
| ıı∪ | ı∪ı | ıı∪ | ı | ∪ı | ıı∪ | ııı | ıı∪ | |
| ∪∪ | ıı∪ | ∪∪ | ı | ı∪ | ∪∪ | | ∪∪ | |
| ııı | ∪∪ | ııı | ∪ | ∪ | ııı | | ııı | |
| | ııı | | ı | ııı | | | | |

| អបរទ្ធៈ (២៧) | | | | | | | | |
|---|---|---|---|---|---|---|---|---|
| តតិយបាទ (១៤ ឬ១៣ មាត្រា) | | | | | ចតុត្ថបាទ (១៣ ឬ១៤ មាត្រា) | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ∪ıı | ∪ıı | ∪ıı | ∪ | ıı | ∪ıı | ı | ∪ıı | ∪ |
| ıı∪ | ı∪ı | ıı∪ | ı | ∪ı | ıı∪ | | ıı∪ | |
| ∪∪ | ıı∪ | ∪∪ | ı | ı∪ | ∪∪ | | ∪∪ | |
| ııı | ∪∪ | ııı | ∪ | ∪ | ııı | | ııı | |
| | ııı | | ı | ııı | | | | |

### ៤.៣.២-អាគតដ្ឋាន

សីហឡទីបំ បន អាភ-,　　តាថ វសិនា មហាមហិន្ទេន;
ឋបិតា សីហឡភាសាយ-, ទីបវាសីនមត្ថាយ។[៣២]

### ៤.៣.៣-អនុវត្ត

ឱឃមធកោធបុន្នាគ-,　　បដិយចម្បកាទិ,លយប,ឧសបុរិសា;
អាចរិយសារកោបិសាច-,　សុរាសុរនាគសារម្ភា ។

៣២ ទីឃនិកាយដ្ឋកថា សីលក្ខន្ធវគ្គ សុមង្គលវិលាសិនី បឋមភាគ រចនាដោយ ព្រះពុទ្ធឃោសាចារ្យ ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព.ស. ២៥៥៥, ទំព័រ ២ ។

## ៤.៤-ចបលាអរិយាគាថា

### ៤.៤.១-ឫង្ស័រចនាចបលាអរិយាគាថា

| បុព្វទ្ធៈ (៣០ មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| បឋមបាទ (១២ មាត្រា) | | | ទុតិយបាទ (១៨ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ∪∪/ıı∪ | ı∪ı | ∪∪ | ı∪ı | ∪∪/∪ıı | ı∪ı/ııı | ∪ıı/ıı∪/∪∪/ııı | ∪ |
| ម/ស. | ជ. | ម. | ជ. | ម/ភ. | ជ/ន. | ភ/ស/ម/ន. | គ. |

| អបរទ្ធៈ (២៧ មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| តតិយបាទ (១២ មាត្រា) | | | ចតុត្ថបាទ (១៥មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ∪∪/ıı∪ | ı∪ı | ∪∪ | ı∪ı | ∪∪/∪ıı | ı | ∪ıı/ıı∪/∪∪/ııı | ∪ |
| ម/ស. | ជ. | ម. | ជ. | ម/ភ. | ល. | ភ/ស/ម/ន. | គ. |

### ៤.៤.២-អាគតដ្ឋាន

សច្ចានិ បច្ចយាកា-, រទេសនា សុបរិសុទ្ធ, និបុណានយា។
អវិមុត្តតន្តិ មគ្គា, វិបស្សនា ភាវនា ចេវ។[៣៣]

### ៤.៤.៣-អនុវត្ត

វាយាមសោណសីហា, វរាហគន្ធព្វកិន្នរមនុស្សា;
អាលោកលោកតាលា, ច លោកហិត្តាលពកុលច្ឆា ។

៣៣ អង្គុត្តរនិកាយដ្ឋកថា ឯកកនិបាតវណ្ណនា មនោរថបូរណី បឋមភាគ រចនាដោយព្រះពុទ្ធឃោសាចារ្យ ការផ្សាយរបស់ពុទ្ធិក-បណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព.ស. ២៥៥៥, ទំព័រ ៣ ។

## ៤.៨-មុខចបលាអរិយាគាថា

### ៤.៨.១-ឫជ័រចនាមុខចបលាអរិយាគាថា

| បុព្វទ្ធៈ (៣០មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| បឋមបាទ (១២មាត្រា) | | | ទុតិយបាទ (១៨មាត្រា) | | | | |
| ប.រិ. | ទុ.ស. | ត.រិ. | ច.ស. | បញ្ច.រិ. | ឆ.ស. | ស.រិ. | អ.ស. |
| ∪∪/ıı∪ | ı∪ı | ∪∪ | ı∪ı | ∪∪/∪ıı | ı∪ı/ııı | ∪ıı/ıı∪/∪∪/ııı | ∪ |
| ម/ស. | ជ. | ម. | ជ. | ម/ភ. | ជ/ន. | ភ/ស/ម/ន. | គ. |

| អបរទ្ធៈ (២៧មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| តតិយបាទ (១២មាត្រា) | | | ចតុត្ថបាទ (១៥មាត្រា) | | | | |
| ប.រិ. | ទុ.ស. | ត.រិ. | ច.ស. | បញ្ច.រិ. | ឆ.ស. | ស.រិ. | អ.ស. |
| ∪ıı/ıı∪/ ∪∪/ııı | ∪ıı/ı∪ı/ıı∪/ /∪∪/ııı | ∪ıı/ıı∪/ ∪∪/ııı | ∪ıı/ı∪ı/ıı∪/ ∪∪/ııı | ∪ıı/ıı∪/ ∪∪/ııı | ı | ∪ıı/ıı∪/ ∪∪/ııı | ∪ |
| ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ល. | ភ/ស/ម/ន. | គ. |

### ៤.៨.២-អាគតដ្ឋាន

យំ ឯត្ថ វុឌ្ឍិមន្តោ, សលក្ខណា បូជិតា បរិច្ឆិន្នា;
វុត្តាធិកា ច ធម្មា, អភិធម្មោ តេន អក្ខាតោ។[៣៤]

### ៤.៨.៣-អនុវត្ត

មាតង្គ័បេតហំសា, តរច្ឆកាច្ឆបតុរង្គ័រកសប្បា;
រុក្ខបុចិមន្ទកុន្ទា, ច កឹសុកផ្ទុនការញ្ញមតា ។

---

៣៤ ទីឃនិកាយដ្ឋកថា សីលក្ខន្ធវគ្គ សុមង្គលវិលាសិនី បឋមភាគ រចនាដោយ ព្រះពុទ្ធឃោសាចារ្យ ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព.ស. ២៥៥៥, ទំព័រ ៣៨ ។

# ៤.៦-ជយនចបលាអរិយាគាថា

## ៤.៦.១-ឫជ័រចនាជយនចបលាអរិយាគាថា

| បុព្វទ្ធៈ (៣០ មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| បឋមបាទ (១២ មាត្រា) | | | ទុតិយបាទ (១៨ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ∪ıı/ıı∪/<br>∪∪/ııı | ∪ıı/ı∪ı/ıı∪/<br>/∪∪/ııı | ∪ıı/ıı∪/<br>∪∪/ııı | ∪ıı/ı∪ı/ıı∪/<br>∪∪/ııı | ∪ıı/ıı∪/<br>∪∪/ııı | ı∪ı/ııı | ∪ıı/ıı∪/<br>∪∪/ııı | ∪ |
| ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ជ/ន. | ភ/ស/ម/ន. | គ. |

| អបរទ្ធៈ (២៧ មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| តតិយបាទ (១២ មាត្រា) | | | ចតុត្ថបាទ (១៥ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ∪∪/ıı∪ | ı∪ı | ∪∪ | ı∪ı | ∪∪/∪ıı | ı | ∪ıı/ıı∪/∪∪/ııı | ∪ |
| ម/ស. | ជ. | ម. | ជ. | ម/ភ. | ល. | ភ/ស/ម/ន. | គ. |

## ៤.៦.២-អាគតដ្ឋាន

តណ្ហាញ្ច អវិជ្ជម្បិ ច, សមថេន វិបស្សនាយ[៣៥] យោ នេតិ;
សច្ចេហិ យោជយិត្វា, អយំ នយោ នន្ទិយាវដ្ដោ។[៣៦]

## ៤.៦.៣-អនុវត្ត

សញ្ញា សាលា នាវា, បរិសា វនិតា សភា លតា ជេដ្ឋា;
សទ្ធា បភា វិតណ្ហា, កលា សិលា មេខលា លីលា ។

---

៣៥ គាថានេះ ក្នុងនេត្តិប្បករណ៍ មានរូបជា **វិបស្សនា** តែក្នុងនេត្តិប្បករណដ្ឋកថាមានរូបជា **វិបស្សនាយ**, ព្រោះហេតុនោះ ដើម្បីឱ្យត្រូវតាមលក្ខណៈរបស់ជយនចបលាអរិយាគាថានេះផង ដើម្បីឱ្យសមស្របតាមនេត្តិប្បករណដ្ឋថាត្រង់ទំព័រ ៤៨ ផង និងទីឃនិកាយ សីលក្ខន្ធវគ្គអភិនវដីកា ទំព័រ ៨៦០ ផង ទើបក្រុមខ្ញុំសម្រេចយក **វិបស្សនាយ** (ច្បាប់បញ្ញាសាស្ត្រ)។

៣៦ សុត្តន្តបិដកេ ខុទ្ទកនិកាយេ ជម្ពុវនវាសិនា មហាកច្ចាយនត្ថេរេន កតំ នេត្តិប្បករណំ, កម្ពុជរដ្ឋេ បញ្ញាសាស្ត្រសាកលវិទ្យាលយស្ស ពុទ្ធិកបណ្ឌិតសភាយ បកាសិតំ, អនុស្សរណីយំ ពុទ្ធសកេ ២៥៥៣, ទំព័រ ៧ ។

# ៤-៧.គីតិគាថា

## ៤.៧.១-ប្លង់រចនាគីតិគាថា

| បុព្វទ្ធៈ (៣០ មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| បឋមបាទ (១២ មាត្រា) | | | ទុតិយបាទ (១៨ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ចវិ. | ឆ.ស. | ស.វិ. | អ.ស. |
| ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ជ/ន. | ភ/ស/ម/ន. | គ. |

| អបរទ្ធៈ (៣០មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| បឋមបាទ (១២ មាត្រា) | | | ទុតិយបាទ (១៨ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ចវិ. | ឆ.ស. | ស.វិ. | អ.ស. |
| ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ជ/ន. | ភ/ស/ម/ន. | គ. |

## ៤.៧.២-អាគតដ្ឋាន

សញ្ញា ច អភិញ្ញាយោ,
បញ្ញាសង្ក័លននិច្ឆយោ ចេវ;
ខន្ធាជាតាយតនិ-,
ន្ទ្រិយានិ អរិយានិ ចេវ ចត្តារិ។[៣៧]

## ៤.៧.៣-អនុវត្ត

មេធា វិជ្ជា បញ្ញា,
ចិន្តា មន្តា តុលា សុភា ធោលា;
វីណា តណ្ហា ឥច្ឆា,
មេត្តា ករុណា វិបស្សនា មុទិតា។

៣៧ សុត្តបិដក (អដ្ឋកថា) » មជ្ឈិមនិកាយ (អដ្ឋកថា) » មូលបណ្ណាស-អដ្ឋកថា » គន្ទារម្ភកថា (ឆដ្ឋសង្គាយនា)។

# ៤.៨-ឧបគីតិគាថា

## ៤.៨.១-ប្លង់រចនាឧបគីតិគាថា

| បុព្វឌ្ឍៈ (២៧ មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| តតិយបាទ (១២ មាត្រា) | | | ចតុត្ថបាទ (១៥ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ល. | ភ/ស/ម/ន. | គ. |

| អបរឌ្ឍៈ (២៧ មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| តតិយបាទ (១២ មាត្រា) | | | ចតុត្ថបាទ (១៥ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ល. | ភ/ស/ម/ន. | គ. |

## ៤.៨.២-អាគតដ្ឋាន

ឱរព្ភិកសូករិកា, មាគវិកា តេ ច សាកុណិកា;
ហន្ត្វា ជីវន្តេឡក-, សូករមិគបក្ខិនោ កាមតោ។[៣៨]

## ៤.៨.៣-អនុវុត្ត

ឆាយា សិក្ខា ភិក្ខា, សេនា ជាសា ខមា អាសា;
និទ្ទា គាថា ជិវ្ហា, លេខា សីមា កថា ឧក្កា។

# ៤.៩-ឧគ្គីតិគាថា

## ៤.៩.១-ប្លង់រចនាឧគ្គីតិគាថា

| បុព្វឌ្ឍៈ (២៧ មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| បឋមបាទ (១២ មាត្រា) | | | ទុតិយបាទ (១៥ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ល. | ភ/ស/ម/ន. | គ. |

៣៨ ព្រះវជិរបញ្ញត្ថេរៈ, វុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី, ជនជាតិភូមា, ព.ស. ២៤៩៧, បរិវត្តដោយ មហាធម្មកណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែភទ្របទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួន ៤ គម្ពីរ, ទំព័រ ៥៣ ។

| អបរទ្ធៈ (៣០ មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| តតិយបាទ (១២ មាត្រា) | | | ចតុត្ថបាទ (១៨ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ជ/ន. | ភ/ស/ម/ន. | គ. |

### ៤.៩.២-អាគតដ្ឋាន

អក្ខរនិយមោ ឆន្ទំ, គរុលហុនិយមោ ភវេ វុត្តិ,
ទីឃោ សំយោគាទិ-, បុព្វោ រស្សោ ច គរុ, លហុ តុ រស្សោ។[៣៩]

### ៤.៩.៣-អនុវត្ត

ឆម្មី សជ្ជី ញាណី, ហត្ថី ចក្កី ការី ចាគី;
បត្តី បក្ខី ធាជី, រជ្ជី ឆត្តី សសី គណី សាមី។

## ៤.១០-អរិយាគីតិគាថា

### ៤.១០.១-ឫ្ទំរចជាអរិយាគីតិគាថា

| បុព្វទ្ធៈ (៣២ មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| បឋមបាទ (១២ មាត្រា) | | | ទុតិយបាទ (២០ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ជ/ន. | ភ/ស/ម/ន. | ស/ម. |

| អបរទ្ធៈ (៣២ មាត្រា) | | | | | | | |
|---|---|---|---|---|---|---|---|
| បឋមបាទ (១២ មាត្រា) | | | ចតុត្ថបាទ (២០ មាត្រា) | | | | |
| ប.វិ. | ទុ.ស. | ត.វិ. | ច.ស. | បញ្ច.វិ. | ឆ.ស. | ស.វិ. | អ.ស. |
| ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ភ/ជ/ស/ម/ន. | ភ/ស/ម/ន. | ជ/ន. | ភ/ស/ម/ន. | ស/ម. |

---

៣៩ ធម្មកិត្តិមហាថេរៈ, ពាលាវតារបាលិ, (ច្បាប់ឆដ្ឋសង្គាយនា)។

### ៤.១០.២-អាគតដ្ឋាន

តមសីតិអនុព្យញ្ជន-,
សមនុព្យញ្ជិតវិចិត្តលក្ខណូបេតំ;
បជ្ជលិតកេតុមាលា-,
ជាលសមុជ្ជលិតរូបសោភំ វន្ទេ។[40]

### ៤.១០.៣-អនុវត្ត

មាលី វម្មី យោគី,
ភាគី ភោគី ធជី ពលី តេជស្សី;
ចម្មី ធម្មី វាចី,
ចាណី កុដ្ឋី សិខី យសស្សី មន្តី។

## ៤.១១-វេតាលីយគាថា

### ៤.១១.១-ប្លង់រចនាវេតាលីយគាថា

| វិសមចរណ | | | |
|---|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ៦ មាត្រា | រ. (∪ ı ∪) | ល. (ı) | គ. (∪) |
| **សមចរណ** | | | |
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ៨ មាត្រា | រ. (∪ ı ∪) | ល. (ı) | គ. (∪) |

### ៤.១១.២-អាគតដ្ឋាន

ឧទកំ ហិ នយន្តិ នេត្តិកា, ឧសុការា នមយន្តិ តេជនំ;
ទារុំ នមយន្តិ តច្ឆកា, អត្តានំ ទមយន្តិ សុព្វតា ។[41]

---

៤០ ព្រះវជិរបញ្ញត្ថេរៈ, វុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី, ជនជាតិភូមា, ព.ស. ២៤៩៧, បរិវត្តដោយ មហាធម្មកណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែភទ្របទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រ ៦០ ។

៤១ ព្រះត្រៃបិដក នឹងសេចក្ដីប្រែជាភាសាខ្មែរ, សុត្តន្តបិដក ខុទ្ទកនិកាយ បេតវត្ថុ ថេរគាថា បញ្ចមភាគ ៥៦, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០២, ទំព័រ ១៤១ ។

### ៤.១១.៣-អនុវត្ត

វេតរណី វារុណី មហី, វាបី តរុណី កិន្នរី សខី;
កទលី នារី អជី នទី, ទេវី នាគី វានរី មិគី។

## ៤.១២-ឱបច្ឆន្ទសកគាថា

### ៤.១២.១-ប្លង់រចនាឱបច្ឆន្ទសកគាថា

| វិសមបាទ | | |
|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន |
| ៦មាត្រា | រ. (∪ ɩ ∪) | យ. (ɩ ∪ ∪) |
| សមបាទ | | |
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន |
| ៨មាត្រា | រ. (∪ ɩ ∪) | យ. (ɩ ∪ ∪) |

### ៤.១២.២-អាគតដ្ឋាន

យោ ឧប្បតិតំ វិនេតិ កោធំ, វិសដំ សប្បវិសំវ ឱសធេហិ;
សោ ភិក្ខុ ជហាតិ ឱរបារំ, ឧរគោ ជិណ្ណមិវត្តចំ បុរាណំ។[៤២]

### ៤.១២.៣-អនុវត្ត

យក្ខី កាកី ឃដី កុមារី, សីហី ហំសី ព្រាហ្មណី មហេសី;
គន្ធព្វី បាដលី មនុស្សី, ឃរណី សកុណី កុក្កុដី កុវេណី។

## ៤.១៣-អាបាតលិកាគាថា

### ៤.១៣.១-ប្លង់រចនាអាបាតលិកាគាថា

| វិសមបាទ | | |
|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន |
| ៦មាត្រា | ភគណៈ (∪ ɩ ɩ) | មគណៈ (∪ ∪) |

៤២ វិនយបិដក (អដ្ឋកថា) » បាចិត្តិយ-អដ្ឋកថា » បាចិត្តិយកណ្ឌំ (ឆដ្ឋសង្គាយនា) ។

| សមចាន | | |
|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន |
| ៨មាត្រា | ភគណៈ (∪ ı ı) | មគណៈ (∪ ∪) |

### ៤.១៣.២-អាគតដ្ឋាន

ន ហិ នស្សតិ កស្សចិ កម្មំ, ឯតិ ហតំ លភតេវ សុវាមិ;
ទុក្ខំ មន្ទោ បរលោកេ, អត្តនិ បស្សតិ កិព្វិសការី។[៤៣]

### ៤.១៣.៣-អនុវត្ត

បុញ្ញផលហិរញ្ញសុសាធំ, មង្គលចីវរឥន្ទ្រិយវណ្ណំ;
អម្ពុជជនលោចនម្វូលំ, តីរការណាវនសាធនឈាធំ។

## ៤.១៤-ទក្ខិណាន្តិកាគាថា

### ៤.១៤.១-ប្លង់រចនាទក្ខិណាន្តិកាគាថា

| វិសមចាន | | | |
|---|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ជគណៈ + ២មាត្រា =៦មាត្រា | រ. (∪ ı ∪) | ល. (ı) | គ. (∪) |
| សមចាន | | | |
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ជគណៈ + ៤មាត្រា =៨មាត្រា | រ. (∪ ı ∪) | ល. (ı) | គ. (∪) |

### ៤.១៤.២-អាគតដ្ឋាន

ជិនោ ទសពលោ វិនាយកោ, នរាសភោ សុគតោ តថាគតោ;
មហាមុនិ សមន្តភទ្ទកោ, សមន្តចក្ខុ ច សត្ថវាហកោ។[៤៤]

---

៤៣ ព្រះត្រៃបិដក នឹងសេចក្ដីប្រែជាភាសាខ្មែរ, សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត តតិយភាគ ៥៤, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០២, ទំព័រ ២៣១ ។

៤៤ ព្រះវជិរបញ្ញត្ថេរៈ, វុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី, ជនជាតិភូមា, ព.ស. ២៤៩៧, បរិវត្តដោយ មហាធម្មកណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែភទ្របទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រ ៧០ ។

### ៤.១៤.៣-អនុវត្ត

អរញ្ញមុខសោតផាណិតំ, សុវណ្ណវេឍារម្មណារុជំ;
ឧទានសោចានកានឌំ, កិលិដ្ឋបឧតឧបដ្ឋការណំ។

## ៤.១៥-ឧទិច្ចវុត្តិគាថា

### ៤.១៥.១-ប្លង់រចនាឧទិច្ចវុត្តិគាថា

| វិសមបាទ | | | |
|---|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ជគណៈ + ២មាត្រា = ៦មាត្រា | រ. (∪ ι ∪) | ល. (ι) | គ. (∪) |
| សមបាទ | | | |
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ៨មាត្រា | រ. (∪ ι ∪) | ល. (ι) | គ. (∪) |

### ៤.១៥.២-អាគតដ្ឋាន

ជិនោ ទសពលោ វិនាយកោ,
ពុទ្ធោ សុគតោ លោកនាយកោ,
នរាសភោ សត្ថវាហកោ,
សម្មាសម្ពុទ្ធោ ជនេសុតោ។[៤៥]

### ៤.១៥.៣-អនុវត្ត

មហំ ចរំ ទេសយំ ឧជំ,
តិដ្ឋំ កុញ្ជំ ភាវយំ សុណំ;
បចំ ជយំ ការយំ ចរំ,
ជីវំ កុព្វំ ចោរយំ សរំ ។

៤៥ ព្រះវជិរបញ្ញត្ថេរៈ, វុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី, ជនជាតិភូមា, ព.ស. ២៤៩៧, បរិវត្តដោយ មហាធម្មកណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែភទ្របទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រ ៧១ ។

# ៤.១៦-បច្ចវុត្តិគាថា

## ៤.១៦.១-ប្លង់រចនាបច្ចវុត្តិគាថា

| វិសមបាទ | | | |
|---|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ៦មាត្រា | រ. (∪ ı ∪) | ល. (ı) | គ. (∪) |
| **សមបាទ** | | | |
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| គរុ + ជគណៈ + ២មាត្រា = ៨មាត្រា | រ. (∪ ı ∪) | ល. (ı) | គ. (∪) |

## ៤.១៦.២-អាគតដ្ឋាន

លោកជិនោ អគ្គបុគ្គលោ, លោកនាយកោ ធម្មសាមិកោ;
នរសីហោ សត្ថវាហកោ, សក្យបុង្គវោ មារភញ្ជនោ។[៨]

## ៤.១៦.៣-អនុវត្ត

មីយំ មុញ្ច សយំ ហរំ, អាចិនំ លកំ ចាលយំ វជំ;
បស្សំ នត្ថំ មរំ តុទំ, ចិន្តយំ វហំ ចាបុណំ បិវំ។

# ៤.១៧-បវត្តកគាថា

## ៤.១៧.១-ប្លង់រចនាបវត្តកគាថា

| វិសមបាទ (យកវិសមបាទរបស់ឧទិច្ចវុត្តិគាថា) | | | |
|---|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ជគណៈ + ២មាត្រា = ៦មាត្រា | រ. (∪ ı ∪) | ល. (ı) | គ. (∪) |
| **សមបាទ** (យកសមបាទរបស់បច្ចវុត្តិគាថា) | | | |
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| គរុ + ជគណៈ + ២មាត្រា = ៨មាត្រា | រ. (∪ ı ∪) | ល. (ı) | គ. (∪) |

---

៨ ព្រះវជិរបញ្ញត្ថេរៈ, វុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី, ជនជាតិភូមា, ព.ស. ២៤៩៧, បរិវត្តដោយ មហាធម្មកណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែភទ្របទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រ ៧២ ។

### ៤.១៧.២-អាគតដ្ឋាន

ជិនោ ទសពលោ វិនាយកោ,
លោកនាយកោ ធម្មសាមិកោ;
គោតមោ សត្ថវាហកោ,
សក្យបុត្តោ មារភញ្ជនោ។[៤៧]

### ៤.១៧.៣-អនុវត្ត

ន ទេតិ ឥធ មច្ឆរី វរំ, រក្ខតី ជនោ ព្រហ្មចារិនោ;
មយំ ច បូជេម នាយកំ, ធម្មសាមិកំ ចេតសា សទា។

## ៤.១៨-អបរន្តិកាគាថា

### ៤.១៨.១-ប្លង់រចនាអបរន្តិកាគាថាទី១

| វិសមចរណ (យកលក្ខណៈសមបាទរបស់វេតាលីយគាថា) | | | |
|---|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ៨មាត្រា | រ. | ល. | គ. |
| **សមចរណ** (យកលក្ខណៈសមបាទរបស់វេតាលីយគាថា) | | | |
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ៨ មាត្រា | រ. | ល. | គ. |

### ៤-២.១៨.អាគតដ្ឋាន

បដិសង្ខាយបនេតមត្ថំ, អតិកន្តា បឋមច្ចុតំ ពុធា;
សុសមុច្ឆិន្នសិនេហពន្ធនា, សមមេស្សន្តិ ចិរាយ សុព្វតា។[៤៨]

---

៤៧ ព្រះវជិរបញ្ញត្ថេរៈ, វុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី, ជនជាតិភូមា, ព.ស. ២៤៩៧, បរិវត្តដោយ មហាធម្ម-កណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែភទ្របទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រ ៧៣ ។

៤៨ ព្រះអនុរុទ្ធាចារ្យ, អភិធម្មត្ថសង្គហបាលី, វត្តតុមូលសោម លង្កាទ្វីប (សម័យបុរាណ), ប្រែជាខេមរភាសាដោយទូច សុវណ្ណមុនី, ព.ស.២៥៦១, គ.ស. ២០១៨, ទំព័រ ៩១ ។

៤.១៨.៣-អនុវត្ត

គណវា គុណវា ចេវ បណ្ណវា, យសវា ពលវា បុញ្ញវា តថា;
ភគវា ធនវា ចេវ បញ្ញវា, កុលវា សុតវា ថាមវាបិ ច ។

## ៤.១៨.២-ប្លង់រចនាអបរន្តិកាគាថាទី២

| វិសមបាទ(យកលក្ខណៈសមបាទនៃបវត្តកគាថា) | | | |
|---|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| គរុ + ជគណៈ + ២មាត្រា = ៨មាត្រា | រ. | ល. | គ. |
| សមបាទ (យកលក្ខណៈសមបាទនៃបវត្តកគាថា) | | | |
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| គរុ + ជគណៈ + ២មាត្រា = ៨មាត្រា | រ. | ល. | គ. |

៤.១៨.៣-អាគតដ្ឋាន

លោកនាយកោ ធម្មសាមិកោ, សក្យបុត្តោ មារភញ្ជនោ;
អគ្គបុគ្គលោ សត្ថវាហកោ, លោកពន្ធុ អង្គីរសោ ជិនោ។[៤៩]

# ៤.១៩-ចារុហាសិនីគាថា

## ៤.១៩.១-ប្លង់រចនាចារុហាសិនីគាថាទី១

| វិសមបាទ (យកលក្ខណៈវិសមបាទនៃវេតាលីយគាថា) | | | |
|---|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ៦ មាត្រា | រ. | ល. | គ. |
| សមបាទ (យកលក្ខណៈវិសមបាទនៃវេតាលីយគាថា) | | | |
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ៦ មាត្រា | រ. | ល. | គ. |

---

៤៩ ព្រះវជិរបញ្ញត្ថេរៈ, វុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី, ជនជាតិភូមា, ព.ស. ២៤៩៧, បរិវត្តដោយ មហាធម្មកណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែភទ្របទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រ ៧៤ ។

### ៤.១៩.២-អាគតដ្ឋាន

បដិសន្ធិភវង្គវីថិយោ, ចុតិ ចេហ តថា ភវន្តរេ;
បុន សន្ធិភវង្គមិច្ចយំ, បរិវត្តតិ ចិត្តសន្តតិ។[៥០]

### ៤.១៩.៣-អនុវត្ត

ញាតវា គតវា ច សីលវា, ជិតវា ធុតវា ច កុត្តវា;
ហិតវា ហិមវា ច វណ្ណវា, ផលវា យតវា ច ចាគវា។

### ៤.១៩.២-ប្លង់រចនាចារុហាសិនីគាថាទី២

| វិសមបាទ (យកលក្ខណៈវិសមបាទនៃបវត្តកគាថា) | | | |
|---|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ជគណៈ + ២មាត្រា = ៦មាត្រា | រ. | ល. | គ. |
| សមបាទ (យកលក្ខណៈវិសមបាទនៃបវត្តកគាថា) | | | |
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ជគណៈ + ២មាត្រា = ៦មាត្រា | រ. | ល. | គ. |

### ៤.១៩.៣-អាគតដ្ឋាន

ជិនោ ទសពលោ វិនាយកោ,
វិសុទ្ធិទេហោ តថាគតោ;
អនាសវោ សត្ថវាហកោ,
អនុត្តមោ មារភញ្ជនោ។[៥១]

---

៥០ ព្រះអនុរុទ្ធាចារ្យ, អភិធម្មត្ថសង្គហបាលី, វត្តតុមូលសោម លង្កាទ្វីប (សម័យបុរាណ), ប្រែជាខេមរភាសាដោយទូច សុវណ្ណមុនី, ព.ស.២៥៦១, គ.ស. ២០១៨, ទំព័រ ៩១ ។

៥១ ព្រះវជិរបញ្ញត្ថេរៈ, វុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី, ជនជាតិភូមា, ព.ស. ២៤៩៧, បរិវត្តដោយ មហាធម្មកណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែភទ្របទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រ ៧៦ ។

# ៤.២០-អចលធិតិគាថា

## ៤.២០.១-ប្លង់រចនាអចលធិតិគាថា

| អចលធិតិគាថា | |
|---|---|
| បឋមបាទ<br>រៀងលហុឱ្យបាន ១៦ មាត្រា | ទុតិយបាទ<br>រៀងលហុឱ្យបាន ១៦ មាត្រា |
| តតិយបាទ<br>រៀងលហុឱ្យបាន ១៦ មាត្រា | ចតុត្ថបាទ<br>រៀងលហុឱ្យបាន ១៦ មាត្រា |

## ៤.២០.២-អាគតដ្ឋាន

ឥសិ មុនិ មណិ ជនិ យតិ គិរិ រវិ ករិ,
កបិ អសិ មសិ និធិ វិធិ អហិ កិមិ បតិ;
ហរិ អរិ តិមិ កលិ ពលិ ជលធិ គហបតិ[៥២]
ឧរុធិតិ វរមតិ និរុបធិ អធិបតិ។[៥៣]

## ៤.២០.៣-អនុវត្ត

ពរិហិ ថបតិ ហរិ យតិ និធិ ជលនិធិ,
កបិ ឥសិ មណិ សុមតិ បតិ គរិ អសុចិ;
អរិ ហរិ កលិ ករិ អលិ ឧទធិ ឧបធិ,
តិមិ នមុចិ បសុបតិ មុនិ សុរភិ ពលិ ។

---

៥២ អានរូបសំឡេង គហ ជាសំឡេងតែមួយ, គហ => គ្ហៈ = លហុ ១ ព្យាង្គ ដើម្បីឱ្យត្រូវតាមអចលធិតិគាថានេះ យោងតាមសង្ឃដីការបស់លោកគ្រូ មួន សាវុឌ្ឍី ជាសាស្ត្រាចារ្យ ផ្នែកក្រោយឧត្តមសិក្សានៃពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ។

៥៣ សិរិលង្កាទីបេ, ភទន្តពុទ្ធប្បិយាចរិយត្ថេរេន វិរចិតា, បរូបសិទ្ធិ, កម្ពុរដ្ឋេ ភ្នំពេញនគរេ, សាកលវិទ្យាលយបញ្ញាសាស្ត្រាតិ នាម តក្កសិលាយ ពុទ្ធិកសក្យបុត្រអន្តរជាតីតិ នាម វិជ្ជាលយេន មុទ្ទាបិតា, ទំព័រ ៦៩។

## ៤.២១-មត្តាសមកគាថា

### ៤.២១.១-ឫដ័រចជាមត្តាសមកគាថា

| មត្តាសមកគាថា (ដូចគ្នាគ្រប់បាទ) | |
|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន |
| ៨មាត្រា | លហុ + ៥មាត្រា + គរុ |

### ៤.២១.២-អាគតដ្ឋាន

មុនិរាជវរោ នររាជវរោ, ជិរិនេវវរោ សុចិព្រហ្មវរោ;
សកចាបហរោ បរចាបហរោ, សករុទ្ធិករោ បររុទ្ធិករោ។[៥៤]

### ៤.២១.៣-អនុវត្ត

កាលិមា ពលិមា គតិមា មតិមា, ជុតិមា ថុតិមា មុតិមា រុចិមា;
សុចិមា សិរិមា ហិរិមា កសិមា, សតិមា សុតិមា យតិមា រតិមា។

## ៤.២២-វិសិលោកគាថា

### ៤.២២.១-ឫដ័រចជាវិសិលោកគាថា

| វិសិលោកគាថា (គ្រប់បាទប្លង់តែងដូចគ្នា) | | | |
|---|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ម/ស/ភ/ន. | ជ/ន. | ម/ភ. | ម/ស. |

### ៤.២២.២-អាគតដ្ឋាន

សុគតោ អនជិវរោ សម្ពុទ្ធោ, ជាថោ នរាសភោ ឆឡភិញ្ញោ;
សត្ថា វិជាយកោ សព្វញ្ញូ, លោកគរុ នរវរោ លោកជិនោ។[៥៥]

---

៥៤ ព្រះវជិរបញ្ញត្ថេរៈ, វុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី, ជនជាតិភូមា, ព.ស. ២៤៩៧, បរិវត្តដោយ មហាធម្មកណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែកទ្រូបទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រ ៧៨ ។

៥៥ វជិរបញ្ញត្ថេរៈ, វុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី, ជនជាតិភូមា, ព.ស. ២៤៩៧, បរិវត្តដោយ មហាធម្មកណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែកទ្រូបទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រ ៨០ ។

### ៤.២២.៣-អនុវត្ត

ឆាតា ឋិតា វិនេតា នេតា,    បដិសេវិតា វិចេតា ជេតា;
បដិសេធិតា សមេតា មេតា,   មគ្គា ច អភិសមេតា សោតា ។

## ៤.២៣-ភានភាសិកាគាថា

### ៤.២៣.១-ឫដ៏វចនាភានភាសិកាគាថា

| ភានភាសិកាគាថា (គ្រប់បាទឫួងតែងដូចគ្នា) | | | |
|---|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ម/ស/ភ/ន. | ម/ស/ភ. | ជ/ន. | ម/ស. |

### ៤.២៣.២-អាគតដ្ឋាន

បីត្វា មត្តា មធុ មធុចាលី,   កាលិង្គីយេ តជវនេកុញ្ជេ;
ឃរំ ភមា ផលមធុចាជា,     ជាតិក្ខេត្តាធិកជិនចក្កោ។[៥៦]

### ២.២៣.៣-អនុវត្ត

មគ្គញ្ញូ ចារគូ តថញ្ញូ,       ធម្មញ្ញូ វេទគូ កាតញ្ញូ;
លោកវិទូ អទ្ធគូ វេញ្ញូ;     បរចិត្តវិទូ វិទូ ច វិញ្ញូ។

## ៤-២៤.ចិត្រាគាថា

### ៤.២៤.១-ឫដ៏វចនាចិត្រាគាថា

| ចិត្រាគាថា (គ្រប់បាទឫួងតែងដូចគ្នា) | | | |
|---|---|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន | តតិយដ្ឋាន | ចតុត្ថដ្ឋាន |
| ម/ស/ភ/ន. | ជ/ន. | ស/ន. | ម/ស. |

---

៥៦ ព្រះវជិរបញ្ញត្ថេរៈ, វុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី, ជនជាតិភូមា, ព.ស. ២៤៩៧, បរិវត្តដោយ មហាធម្ម-ភណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែភទ្របទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រ ៨១ ។

### ៤.២៤.២-អាគតដ្ឋាន

សុទ្ធោទនិ អនឃិវហោ ពុទ្ធោ,
លោកគរុ ច អមតទទោ ថាថោ;
សក្យមុនិ ច អភយទទោ សុគតោ,
សត្ថា មុនិ អសមសមោ ភគវា។[៥៧]

### ៤.២៤.៣-អនុវត្ត

ភ្វាទិតោ អ វិហរតិ ហរតី; អាហរតិ នីហរតិ សំហរតី;
បហរតិ បរិហរតិ ចរតិ នេតី; បិវតិ ជរតិ វចតិ វសតិ នេតី។

## ៤.២៥-ឧបចិត្រាគាថា

### ៤.២៥.១-ប្លង់រចនាឧបចិត្រាគាថា

| ឧបចិត្រាគាថា (គ្រប់បាទប្លង់តែងដូចគ្នា) | |
|---|---|
| បឋមដ្ឋាន | ទុតិយដ្ឋាន |
| ៨មាត្រា[58] | គរុ + លហុ + យគណៈ |

### ៤.២៥.២-អាគតដ្ឋាន

ចក្កវត្តិតវត្តសុចាតោ, លក្ខណមណ្ឌិតអាយតបណ្ហី[៥៩]
ចាមរឆត្តវិភូសិតចាតោ, ឯស ហិ តុយ្ហ បិតា នរសីហោ។[៦០]

---

៥៧ ព្រះវជិរបញ្ញត្ថេរៈ, វុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី, ជនជាតិភូមា, ព.ស. ២៤៩៧, បរិវត្តដោយ មហាធម្ម-ភណ្ឌាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែភទ្របទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រ ៨២ ។

៥៨ ក្នុង ៨ មាត្រានេះ បើនឹងកំណត់ថាចុះគណៈអ្វីឱ្យជាក់លាក់នោះ លោកឱ្យមើលលក្ខណៈរបស់ក្រុមមត្តាសមកគាថា។ ក្រុមរបស់មត្តាសមកគាថានេះ មានទាំងអស់ ៧ គាថាមានអចលធិតិគាថាជាដើម។

៥៩ វជិរពុទ្ធិដីកា មានរូបជា ...បណ្ហិ ចំណែកឯឆន្ទោសារត្ថមេទិនី មានរូបជា ...បណ្ហី។

៦០ ព្រះវជិរពុទ្ធិត្ថេរ, វជិរពុទ្ធិដីកា, ភ្នំពេញ, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃពុទ្ធិកសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព.ស. ២៥៦៣, ទំព័រ ៦៩២ ។

### ៤.២៥.៣-អនុវត្ត

បស្សតិ បុច្ឆតិ នន្ទតិ ជេតី; ភាសតិ រោចតិ វន្ទតិ សេតី;
រក្ខតិ យាចតិ ភក្ខតិ ហោតី; តិដ្ឋតិ ពន្ធតិ ជីវតិ ឯតី។

## ៤.២៦-បាទាកុលកគាថា

### ៤.២៦.១-ប្លង់រចនាបាទាកុលកគាថា

| បឋមបាទ | ទុតិយបាទ |
|---|---|
| យកលក្ខណៈណាមួយនៃគាថាទាំង៥ខាងដើម[61] | យកលក្ខណៈណាមួយនៃគាថាទាំង៥ខាងដើម |
| **តតិយបាទ** | **ចតុត្ថបាទ** |
| យកលក្ខណៈណាមួយនៃគាថាទាំង៥ខាងដើម | យកលក្ខណៈណាមួយនៃគាថាទាំង៥ខាងដើម |

### ៤.២៦.២-អាគតដ្ឋាន

សព្វញ្ញូ លោកជិនោ នាថោ, (មត្តាសមក)
ភគវា អនធិវរោ សម្ពុទ្ធោ; (វិសិលោក)
សត្ថា ពុទ្ធោ សមន្តភទ្ទោ, (វានវាសិកា)
សម្មាសម្ពុទ្ធោ នរសីហោ។[62] (ឧបចិត្រា)

### ៤.២៦.៣-អនុវត្ត

សតិមា សុតិមា យតិមា រតិមា, (មត្តាសមក)
បដិសេវិតា វិចេតា ជេតា; (វិសិលោក)
ធម្មញ្ញូ វេទគូ កតញ្ញូ, (វានវាសិកា)
ភូវាទិតោ អវិហារតិ ហរតី។ (ចិត្រាគាថា)

---

៦១ គាថានេះ រចនាដោយបាទរបស់គាថាទាំង ៥ មានមត្តាសមគាថាជាដើម ដូចឧទាហរណ៍ថា បឋមបាទយកបាទរបស់មត្តាសមកគាថាមួយមកតែង ឬថានាំយកលក្ខណៈនៃមត្តាសមកគាថាមកតែង។ ទុតិយបាទ នាំយកលក្ខណៈរបស់វិសិលោកគាថាមកតែង។ តតិយបាទ នាំយកលក្ខណៈរបស់វានវាសិកាគាថាមកតែង។ ចតុត្ថបាទ នាំយកលក្ខណៈរបស់ឧបចិត្រាគាថាមកតែង។ គ្រប់បួនបាទរាប់បានថាជា បាទាកុលកគាថា ព្រោះគ្រប់បាទ ត្រូវតែងដោយនាំយកលក្ខណៈរបស់គាថា ៥ ខាងដើមណាមួយមកតែង។

៦២ ព្រះវជិរបញ្ញត្ថេរៈ, វុត្តោទយាភិនវដីកា ឈ្មោះ ឆន្ទោសារត្ថមេទិនី, ជនជាតិភូមា, ព.ស. ២៤៩៧, បរិវត្តដោយ មហាធម្មកណ្ឋាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែភទ្របទ ព.ស.២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រ ៩០ ។

## ៤.២៧-គានិសង្ខ្យានយៈ (វិធីរកចំនួនគរុជាដើម)

– **គរុសង្ខ្យានយ (វិធីរកចំនួនគរុ)**

ចំនួនមាត្រាដកនឹងចំនួនអក្ខរៈឬព្យាង្គស្មើនឹងចំនួនគរុ។

– **វណ្ណសង្ខ្យានយ (វិធីរកចំនួនព្យាង្គ)**

ចំនួនមាត្រាដកនឹងចំនួនគរុស្មើនឹងចំនួនអក្ខរៈ ឬព្យាង្គ

– **(លហុសង្ខ្យានយ (វិធីរកចំនួនលហុ)**

ចំនួនអក្ខរៈ ឬព្យាង្គដកនឹងចំនួនគរុស្មើនឹងចំនួនលហុ។

### ៤.២៧.១-ឧទាហរណ៍

ន ហិ នស្សតិ កស្សចិ កម្មំ, ឯតិ ហតំ លភតេវ សុវាមិ;
ទុក្ខំ មន្ទោ បរលោកេ, អត្តនិ បស្សតិ កិព្វិសការី។[៦៣]

គាថានេះឈ្មោះថា អាបាតលិកាគាថា បឋមបាទនិងតតិយបាទមានចំនួន ១៤មាត្រា ទុតិយបាទនិងចតុត្ថបាទមានចំនួន ១៦មាត្រា ។ មួយគាថាមានចំនួន ៦០មាត្រា ។

– **គរុសង្ខ្យានយៈ (វិធីរកចំនួនរកចំនួនគរុ)**

៦០មាត្រា — ៤០អក្ខរៈ ឬព្យាង្គ = ២០គរុ។

– **វណ្ណសង្ខ្យានយៈ វិធីរកចំនួន (អក្ខរៈ ឬព្យាង្គ)**

៦០មាត្រា — ២០គរុ = ៤០អក្ខរៈ ឬព្យាង្គ

– **លហុសង្ខ្យានយៈ (វិធីរកចំនួនលហុ)**

៤០អក្ខរៈ ឬព្យាង្គ — ២០គរុ = ២០លហុ

គាថាខាងលើនេះ មានចំនួនគរុ២០ មានចំនួនអក្ខរៈ៤០ និងមានចំនួនលហុ ២០ ។[៦៤]

---

៦៣ ព្រះត្រៃបិដក នឹងសេចក្តីប្រែជាភាសាខ្មែរ, សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត តតិយភាគ ៥៤, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០២, ទំព័រ ២៣១ ។

៦៤ វិធីរកចំនួនគរុ អក្ខរៈ និងលហុ អាចរកបានគ្រប់គាថា តែមុននឹងរកចំនួនគរុជាដើមក្នុងគាថាណា ត្រូវស្គាល់គាថានោះសិនទើបងាយស្រួល ដើម្បីកុំឱ្យច្រឡំគរុ និងលហុ ជាពិសេសគឺបាទន្តគរុនេះតែម្តង។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ **ឆន្ទោជោតកៈ** នេះមក បានធ្វើឱ្យក្រុមយល់ដឹងបានច្រើនពាក់ព័ន្ធនឹងឈ្មោះរបស់គាថានីមួយៗ ក្នុងនោះមានដូចជា បានស្គាល់អត្ថន័យ ឬនិមយន័យរបស់ពាក្យបច្ចេកសព្ទមួយចំនួនដូចជា គរុ, លហុ, មត្តា (មាត្រា), បុព្វទ្ធៈ, អបរទ្ធៈ វិសមបាទ, សមបាទ, វិសមដ្ឋាន, សមដ្ឋាន និងពាក្យពេចន៍ជាច្រើនទៀតដែលត្រូវប្រើក្នុងមត្តាគាថានេះ ។

មត្តាគាថានេះ ចែកជា ៤ ក្រុមធំៗគឺ អរិយាជាតិ (ក្រុមអរិយាគាថា), គីតិជាតិ (ក្រុមគីតិគាថា), វេតាលីយជាតិ (ក្រុមវេតាលីយគាថា), មត្តាសមកជាតិ (ក្រុមមត្តាសមកគាថា)។ ក្នុងចំណោមក្រុម នៃគាថាទាំង ៤ នោះ ក៏មានចែកជាបន្តទៅទៀតជាច្រើន។

មត្តាគាថានេះមានភាពស្មុកស្មាញ បើមិនគិតឱ្យល្អិតទេ មុខជាយល់ខុសមិនខាន ដោយក្រុមរបស់គាថានីមួយៗ មានភាពស្រដៀងគ្នាច្រើន ខុសគ្នាបន្តិចបន្តួចដែលធ្វើឱ្យអ្នកសិក្សាលំបាកយល់ តែទោះពិបាកយ៉ាងណាក៏ដោយ គាថានីមួយៗរមែងមានលក្ខណៈរបស់ខ្លួនឯងជានិច្ច ទាំងលក្ខណៈក្នុងការរៀងគណៈ ទាំងលក្ខណៈក្នុងការប្រើយតិ រមែងមានមេសូត្រប្រាប់យ៉ាងច្បាស់លាស់។

បើតាមមតិនៃគ្រូអាចារ្យទាំងឡាយច្រើនតែពោលថា ប្រភេទមត្តាគាថានេះ ជាគាថាដែលពិបាកសិក្សា និងពិបាកតែងជាងវណ្ណគាថា ដូច្នេះហើយទើបគាថាទាំង ៤ ក្រុមនេះ កម្រមានកវីជំនាន់ថ្មីយកមករចនាណាស់។

## អនុសាសន៍

ចំពោះការអនុវត្តតែងជាក់ស្តែងពិតជាពិបាកមែន ព្រោះវេលាតែងត្រូវរើសពាក្យពេចន៍ឱ្យត្រូវតាមគណាឆន្ទផង ឱ្យត្រូវតាមលក្ខណៈរបស់វេយ្យាករណ៍ផង។ មិនមែនគ្រាន់តែចាំមេសូត្រហើយ ចាំប្លង់តែង គឺតែងបាននោះទេ គឺទាមទារឱ្យកវី មានសមត្ថភាពខ្លាំងដូចជា៖

- ចេះលក្ខណៈរបស់វេយ្យាករណ៍ទាំង ៧ និទ្ទេសមានអក្ខរៈ, សន្ធិ, នាម, សមាស តទ្ធិតជាដើម
- ចេះសព្ទឱ្យបានច្រើន ឬចេះអភិធាន ព្រោះវេលាតែងទៅ បើដាក់មិនត្រូវគណៈក្នុងគាថានោះទេ គេត្រូវប្តូរពាក្យហ្នឹងចេញ ហើយរកពាក្យណាដែលមានន័យស្មើ ឬជាវេវចនៈនឹងគ្នា
- ជាអ្នកដែលសិក្សាទាក់ទងនិងក្បួនរចនាគាថានេះ ថែមទាំងបានចាំរាល់លក្ខណៈ ឬមេសូត្ររបស់គាថានីមួយៗច្បាស់លាស់ ។
- ដើម្បីឱ្យការរចនានោះមានភាពរណ្តំពិរោះ ព្រមទាំងមានអត្ថន័យល្អទៀតនោះ កវីត្រូវតែជាអ្នកសិក្សាច្រើន អានច្រើន ស្តាប់ច្រើន ក្នុងបិដក អដ្ឋកថា ដីកា យោជនាជាដើម។

លទ្ធផលនៃការស្រាវជ្រាវ គ្រប់គាថាទាំងអស់ក្នុងសារណានេះ ក្រុមបានធ្វើការសិក្សាស្រាវជ្រាវរាវរកឧទាហរណ៍អាគតដ្ឋានចំនួនមួយគាថា ព្រមទាំងអនុវត្តតែងឧទាហរណ៍ខ្លួនឯងចំនួនមួយគាថា។ ចំពោះ

ការអនុវត្តតែងវិញ ក្រុមមិនមានសមត្ថភាពខ្លាំងដូចការរៀបរាប់ខាងលើនោះឡើយ។ ដូច្នេះរាល់គាថាទាំងអស់ដែលក្រុមបានចែកគ្នាតែង អាស្រ័យលើសមត្ថភាពជាក់ស្តែងនិងកំរិតនៃការសិក្សារៀងៗខ្លួន។

ឆន្ទោជោតកៈនេះ សង្ឃឹមថា នឹងបានជាប្រយោជន៍ដល់សិស្សប្អូនជំនាន់ក្រោយ ដែលចូលចិត្តសិក្សាពាក់ព័ន្ធនឹងប្រធានបទនេះ។ សារណានេះទៀតសោត ទុកសម្រាប់តែពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជតែប៉ុណ្ណោះ។

# គន្ថនិទ្ទេស

១-ព្រះត្រៃបិដកបាលី និងសេចក្ដីប្រែជាភាសាខ្មែរ, សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ បឋមភាគ ២៩ កវិសូត្រទី ១០, ភ្នំពេញ ពុទ្ធសាសនបណ្ឌិត្យ, បោះពុម្ពលើកទី ២ ព.ស. ២៥០៦, (ទំព័រសរុប ៣៤៨)។

២-សុត្តន្តបិដក (ដីកា) សំយុត្តនិកាយ (ដីកា) សគាថវគ្គ (ដីកា) ទេវតាសំយុត្តំ (ឆដ្ឋសង្គាយនា)។

៣-សុត្តន្តបិដកេ ខុទ្ទកនិកាយេ ជម្ពុនេវាសិនា មហាកច្ចាយនត្ថេរេន កតំ នេត្តិប្បករណំ, កម្ពុជរដ្ឋេ បញ្ញាសាស្ត្រសាកលវិទ្យាលយស្ស ពុទ្ធិកបណ្ឌិតសភាយ បកាសិតំ, អនុស្សរណីយំ ពុទ្ធសកេ ២៥៥៣ (ទំព័រសរុប ៣៣៥)។

៤-ទីឃនិកាយដ្ឋកថា សីលក្ខន្ធវគ្គ សុមង្គលវិលាសិនី បឋមភាគ រចនាដោយព្រះពុទ្ធឃោសាចារ្យ ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព.ស. ២៥៥៥ (ទំព័រសរុប ៧៥៦)។

៥-អង្គុត្តរនិកាយដ្ឋកថា ឯកកនិបាតវណ្ណនា មនោរថបូរណី បឋមភាគ រចនាដោយព្រះពុទ្ធឃោសាចារ្យ ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព.ស.២៥៥៥ (ទំព័រសរុប ៩០៤)។

៦-សុត្តបិដក (អដ្ឋកថា) » មជ្ឈិមនិកាយ (អដ្ឋកថា) » មូលបណ្ណាស-អដ្ឋកថា » គន្ថារម្ភកថា។

៧-ព្រះត្រៃបិដក នឹងសេចក្ដីប្រែជាភាសាខ្មែរ, សុត្តន្តបិដក ខុទ្ទកនិកាយ បេតវត្ថុ ថេរគាថា បញ្ចមភាគ ៥៦, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០២, (ទំព័រសរុប ២៦៥) ។

៨-ព្រះត្រៃបិដក នឹងសេចក្ដីប្រែជាភាសាខ្មែរ, សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត តតិយភាគ ៥៤, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ ព.ស. ២៥០១, (ទំព័រសរុប ៣៨២)។

៩-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាតបាឡិ មហាវគ្គោ (ឆដ្ឋសង្គាយនា)។

១០-ព្រះវជិរពុទ្ធិត្ថេរ, **វជិរពុទ្ធិដីកា**, ភ្នំពេញ, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃពុទ្ធិកសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ព.ស. ២៥៦៣, ទំព័រសរុប ៩៤៣។

១១-ព្រះអនុរុទ្ធាចារ្យ, **អភិធម្មត្ថសង្គហចាលី**, វត្តតុមូលសោម លង្កាទ្វីប (សម័យបុរាណ), ប្រែជាខេមរភាសាដោយទូច សុវណ្ណមុនី, ព.ស.២៥៦១, គ.ស. ២០១៨, ទំព័រសរុប ១៥៧។

១២-ព្រះសង្ឃរក្ខិតមហាសាមិត្ថេរៈ, "**វុត្តោទយប្បករណ៍**"។ ព្រះវជិរបញ្ញត្ថេរ, "**ឆន្ទោសារត្ថមេជិនី**"។ ព្រះវិសុទ្ធាចារត្ថេរ, "**ឆន្ទោមញ្ជរី**"។ ព្រះញាណិន្ទត្ថេរ, "**ឆន្ទោសារត្ថមញ្ជូសា**"។

បរិវត្តដោយ មហាធម្មកណ្ឋាគារិកៈ វ៉ាន់ ចាន់សារ៉ែន, សទ្ធម្មធរជោតិកៈ, ហួយ វ៉ាន់ថន, លោក វ៉ាន់ វាសនា, ភ្នំពេញ ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, ខែភទ្របទ ព.ស. ២៥៦៤, គ.ស.២០២០, ក្នុងមួយក្បាលនោះមានចំនួនបួនគម្ពីរ, ទំព័រសរុបមានចំនួន៤១៩ ។

១៣-ព្រះសង្ឃរក្ខិតមហាសាមិ, "**វុត្តោទយប្បករណ**" ប្រែលោតប្រយោគដោយ កញ្ញា មាស ស៊ីថា, ការផ្សាយរបស់ក្រុមសិក្សាស្រាវជ្រាវភាសាបាលី, ព.ស.២០២១, គ.ស.២៥៦៥, (ទំព័រសរុប ៤៨)។

១៤-ព្រះញាណបវរវិជ្ជា អែម, "**វុត្តោទ័យ**", ភ្នំពេញ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព.ស. ២៥៤១ គ.ស. ១៩៩៨, (ទំព័រសរុប ៧៩)។

១៥-ធម្មកិត្តិមហាថេរៈ, ពាលាវតារបាលិ, (ច្បាប់ធដ្ឋសង្កាយនា)។

១៦-ព្រះកច្ចាយនមហាថេរៈ, "**កច្ចាយនព្យាករណបាលិ**" ភាគ១ ប្រែនិងប្រកបរូបតាមសូត្រដោយ ទូច សុវណ្ណមុនី ព.ស. ២៥៦១, គ.ស.២០១៨, (ទំព័រសរុប ៦៥៤)។

១៧-ពុទ្ធប្បិយត្ថេរៈ, "**បទរូបសិទ្ធិ**" (ច្បាប់ធដ្ឋសង្កាយនា)។

១៨-ព្រះញាណធជមហាថេរៈ, "**និរុត្តិទីបនី**" (ច្បាប់ធដ្ឋសង្កាយនា)។

១៩-ធម្មកិត្តិមហាថេរៈ, "**ពាលាវតារបាលិ**" (ច្បាប់ធដ្ឋសង្កាយនា)។

២០-ព្រះពុទ្ធប្បិយត្ថេរ, "**ចូឡជាតុបច្ចយជោតិកា**", បរិវត្តដោយ មហាធម្មកណ្ឋាគារិកៈ វ៉ាន់ ចាន់សារ៉ែន, ហួយ វ៉ាន់ថន, ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា, បោះពុម្ព ព.ស. ២៥៦៤ គ.ស.២០២១ (PDF)។

២១-អែម ឧត្តម, ឯកសារបង្រៀន "**តែជ័ឆន្ទបាលី**", សម្រាប់ឆមាសទី១ ឆ្នាំទី៤, ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ, ព.ស.២៥៦៣, គ.ស.២០១៩។

២២-ជោតញាណោ ជួន ណាត, "**វចនានុក្រមខ្មែរ**", ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ១៩៦៧ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
លេខ:...៧៦៤/២១...ព.ស.ស

## សូមថ្វាយបង្គំ

**ព្រះតេជព្រះគុណ មួន សាវុឌ្ឍី សាស្ត្រាចារ្យ ផ្នែកក្រោយឧត្តមសិក្សា**
**នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ**

**កម្មវត្ថុ:** សំណើសុំអនុញ្ញាតឱ្យសមណនិស្សិតជួបសម្ភាសន៍ឯកសារមួយចំនួនទាក់ទងនឹងប្រធានបទសារណាដើម្បីសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូមប្រគេន **ព្រះតេជព្រះគុណ** ជ្រាបថា: សមណនិស្សិតដូចមានរាយព្រះនាមខាងក្រោម ៖

១- សមណនិស្សិត **មៀន សុភា**
២- សមណនិស្សិត **វ៉ត ស៊ីវួន**
៣- សមណនិស្សិត **ផ្លាយ តុលី**
៤- សមណនិស្សិត **ថៃ ថេត**
៥- សមណនិស្សិត **សាយ ចាក**

សមណនិស្សិតទាំងប្រាំអង្គខាងលើនេះ សិក្សាថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ ឯកទេស ភាសាបាលី នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ កំពុងសិក្សាស្រាវជ្រាវលើប្រធានបទ: «**ឆទ្ទន្តជាតក**» ដើម្បីសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្ររបស់ខ្លួន និងបំពេញតាមលក្ខខណ្ឌរបស់ពុទ្ធិកសាកលវិទ្យាល័យ។ ក្នុងន័យនេះ សូម **ព្រះតេជព្រះគុណ** អនុញ្ញាតដល់សមណនិស្សិតខាងលើ បានជួបសម្ភាសន៍ឯកសារមួយចំនួន ដែលពាក់ព័ន្ធនឹងប្រធានបទដើម្បីឱ្យសារណាប្រកបទៅដោយគុណភាព និងស្របតាមនិយាមអប់រំ។

អាស្រ័យហេតុដូចបានប្រគេនខាងលើ សូម **ព្រះតេជព្រះគុណ** ជួយសម្រួលដោយសេចក្តីអនុគ្រោះ។

សូម **ព្រះតេជព្រះគុណ** ទទួលនូវសេចក្តីស្រឡាញ់រាប់អានពីខ្ញុំព្រះករុណា។

ថ្ងៃអង្គារ ៣ កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០២១

**ជ. ព្រះសាកលវិទ្យាធិការ**

សម្តេចព្រះមហាអរិយវង្ស
បណ្ឌិត **យី សុវណ្ណតេជា**

លេខ ៣៩៣ តិរវិថីព្រះស៊ីសុវត្ថិ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ: (៨៥៥) ២៣ ៩៩៨ ៨៤៩
Email: universitysbu@yahoo.com / Website: www.sbu.edu.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
លេខ: ២៦៩/២១ ......ព.ស.ស

## សូមចម្រើនពរ

**លោក ទូច សុវណ្ណមុនី ជាសាស្ត្រាចារ្យ និងជាសមាជិកនៅក្នុងអនុគណៈកម្មការទទួលបន្ទុកឯកទេសភាសាបាលីផ្នែកក្រោយឧត្តមសិក្សា នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ**

**កម្មវត្ថុ:** សំណើសុំអនុញ្ញាតឱ្យសមណនិស្សិតបានជួបសម្ភាសន៍ឯកសារមួយចំនួនទាក់ទងនឹងប្រធានបទសារណាដើម្បីសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ អាត្មាភាពសូមចម្រើនពរ **លោកសាស្ត្រាចារ្យ** ជ្រាបថា: សមណនិស្សិតដូចមានរាយព្រះនាមខាងក្រោម ៖

១- សមណនិស្សិត **មៀន សុភា**
២- សមណនិស្សិត **វ៉ូត ស៊ីវួន**
៣- សមណនិស្សិត **ផ្លាយ តុលី**
៤- សមណនិស្សិត **ថៃ ថេត**
៥- សមណនិស្សិត **សាយ ចាក**

សមណនិស្សិតទាំងប្រាំអង្គខាងលើនេះ សិក្សាថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ ឯកទេស បាលី នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ កំពុងសិក្សាស្រាវជ្រាវលើប្រធានបទ: «**ឆន្ទោជាតក**» ដើម្បីសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្ររបស់ខ្លួន និងបំពេញតាមលក្ខខណ្ឌរបស់ពុទ្ធិកសាកលវិទ្យាល័យ។ ក្នុងន័យនេះ អាត្មាភាព សូមចម្រើនពរ **លោកសាស្ត្រាចារ្យ** អនុញ្ញាតដល់សមណនិស្សិតខាងលើ បានជួបសម្ភាសន៍ឯកសារមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទ ដើម្បីឱ្យសារណាប្រកបទៅដោយគុណភាព និងស្របតាមនិយាមអប់រំ។

អាស្រ័យហេតុដូចបានចម្រើនពរខាងលើ សូម **លោកសាស្ត្រាចារ្យ** មេត្តាជួយសម្រួលដោយសេចក្ដីអនុគ្រោះ។

សូម **លោកសាស្ត្រាចារ្យ** ទទួលនូវសេចក្ដីស្រឡាញ់រាប់អានពីអាត្មាភាព។

ថ្ងៃ អង្គារ ៣ កើត ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០២១

**ព្រះសាកលវិទ្យាធិការ**

សម្ដេចព្រះមហាអរិយវង្ស
បណ្ឌិត **យី សុវណ្ណរតនា**

ទូច សុវណ្ណមុនី

# ឧបសម្ព័ន្ធ




រូបថតមុខពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ រាប់ពីស្ដាំទៅ លោកគ្រូ **ឃាង សុភាព**, លោកគ្រូ **អែម ឧត្ដម**, លោកគ្រូព្រឹទ្ធបុរស **ស៊ិន ស៊ី**, សមណនិស្សិត **ថៃ ថេត, រ៉ូត ស៊ីរួន, បឿន សុភា និង ផ្លាយ តុលី** ។



សកម្មភាពជួបលោកគ្រូណែនាំទាំងពីររូបគឺ លោកគ្រូ **អែម ឧត្តម** និងលោកគ្រូ
**យាង សុភាព** នៅពុទ្ធិកមហាវិទ្យាល័យបាលី-សំស្រ្កឹត និងភាសាបរទេស








សកម្មភាពធ្វើបទសម្ភាសន៍ជាមួយលោកគ្រូ **ទូច សុវណ្ណមុនី**

លើទូកមុខព្រះបរមរាជវាំង ថ្ងៃអាទិត្យ ទី១២ ខែធ្នូ ឆ្នាំ២០២១








សកម្មភាពធ្វើបទសម្ភាសន៍ជាមួយលោកគ្រូ **មួន សារុឌ្ឍី** នៅទីស្នាក់ការសមាគមទ្រទ្រង់-បាលី កុដិលេខ៣ វត្តមហាមន្ត្រី ថ្ងៃចន្ទ ទី២៧ ខែធ្នូ ឆ្នាំ ២០២១ ។








សកម្មភាពស្រាវជ្រាវក្នុងបណ្ណាល័យសម្តេច **និល ទៀង**



សកម្មភាពស្រាវជ្រាវនៅក្នុងបណ្ណាល័យនៃសមាគមទ្រទ្រង់បាលី